វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីការប្រសើរឡើង
Working Together for Positive Change

MEDICAM

# គំនូសផែនទីនៃព័ត៌មានស្តីពីថវិកា

# ក្នុងវិស័យសុខាភិបាល

**ខែមេសា ឆ្នាំ២០០៩**

**ភ្នំពេញ**

## គំនូសផែនទីនៃព័ត៌មានស្តីពីថវិកាក្នុងវិស័យសុខាភិបាល

ការសិក្សានេះត្រូវបានប្រគល់ជូន **លោក ប៉ក់ គឹមជឿន** ដោយគម្រោងថវិកាជាតិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ក្រោមកិច្ចសហប្រតិបត្តិការជាមួយអង្គការម៉េឌីខាំ ដែលគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងការជម្រុញតម្លាភាពថវិកា។

## សេចក្តីបញ្ជាក់

ទស្សនៈដែលបង្ហាញនៅក្នុងរបាយការណ៍នេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងនូវទស្សនៈរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអង្គការម៉េឌីខាំទេ។ ខ្លឹមសារនៃរបាយការណ៍នេះអាចត្រូវបានយកទៅប្រើប្រាស់បន្តដោយមានការទទួលស្គាល់នូវស្នាដៃអ្នកនិពន្ធ។

**© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា - ខែមេសា ឆ្នាំ២០០៩**

# មាតិកានុក្រម

**បញ្ជីនៃបទសម្ភាសន៍** ........ II

**សេចក្តីសង្ខេប** ........ III

**១. សេចក្តីផ្តើម** ........ 1

**២. សាវតារ** ........ 1

**៣. តើការសិក្សានឹងវាយតម្លៃព័ត៌មានអ្វីខ្លះ?** ........ 3

**៤. វិធីសាស្រ្ត និងរចនាសម្ព័ន្ធនៃរបាយការណ៍** ........ 3

**៥. ទស្សនៈរួមអំពីវិស័យ៖ គោលនយោបាយវឌ្ឍនភាព និងការរៀបចំហិរញ្ញប្បទាន** ........ 5

៥.១. គោលនយោបាយ និងការធ្វើផែនការ ........ 5

៥.២. ហិរញ្ញប្បទាន ........ 7

៥.៣. ការសម្របសម្រួលរបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យសុខាភិបាល ........ 9

៥.៤. រចនាសម្ព័ន្ធស្ថាប័ន និងប្រព័ន្ធផ្តល់សេវា ........ 11

៥.៥. វិភាជន៍ និងលំហូរមូលនិធិ ........ 12

**៦. ព័ត៌មានស្តីពីថវិកា និងការមានព័ត៌មាននេះនៅកម្រិតផ្សេងៗ** ........ 14

៦.១. នៅថ្នាក់ជាតិ ........ 15

៦.២. នៅថ្នាក់ក្រោមជាតិ ........ 21

**៧. ការមានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល៖ ការផ្លាស់ប្តូរដែលរំពឹងទុកក្នុងរយៈពេលខ្លី និងមធ្យម** ........ 23

៧.១. នៅក្នុងកំណែទម្រង់វិស័យសុខាភិបាល ........ 23

៧.២. ពីកំណែទម្រង់ទូលាយជាងផ្សេងទៀត ........ 25

**៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 27

៨.១. សម្រាប់រយៈពេលភ្លាមៗ ........ 27

៨.២. សម្រាប់រយៈពេលមធ្យម និងវែង ........ 28

**ឯកសារយោង** ........ 30

ឧបសម្ព័ន្ធ១៖ លំហូរព័ត៌មាននិងឯកសារដែលផលិតដោយកម្រិតនិងស្ថាប័នផ្សេងៗគ្នា ........ **31**

ឧបសម្ព័ន្ធ២៖ ការមានឯកសារថវិកានៅថ្នាក់ជាតិ ........ **32**

ឧបសម្ព័ន្ធ៣៖ ការមានឯកសារថវិកានៅថ្នាក់ក្រោមជាតិ ........ **35**

## បញ្ជីនៃបទសម្ភាសន៍

| ស្ថាប័ន | កាលបរិច្ឆេទនៃកិច្ចប្រជុំ |
|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - រតនាគារ | ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - នាយកដ្ឋានថវិកា | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ | ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ |
| ក្រសួងសុខាភិបាល - នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨<br>ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ |
| ក្រសួងសុខាភិបាល - នាយកដ្ឋានហិរញ្ញវត្ថុ | ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៨<br>ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ |
| ក្រសួងសុខាភិបាល - នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ | ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ |
| ក្រសួងសុខាភិបាល - មន្ទីរសុខាភិបាលខេត្ត/ស្រុកប្រតិបត្តិការ | ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩<br>ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ |
| ក្រសួងសុខាភិបាល - មណ្ឌលសុខភាព/មន្ទីរពេទ្យបង្អែក | ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៩<br>ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩ |

# សេចក្តីសង្ខេប

ការសិក្សាលើគំនូសផែនទីនៃព័ត៌មានស្តីពីថវិកាក្នុងវិស័យសុខាភិបាលនេះ ត្រូវបានធ្វើឡើងក្នុងកំឡុងពេលចាប់ពីខែធ្នូ ឆ្នាំ២០០៨ ដល់ខែកុម្ភៈ ឆ្នាំ២០០៩ ក្នុងគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅមួយស្តីពីឯកសារថវិកាដែលមានជាសាធារណៈ ដើម្បីជំនួយដល់ការយល់ដឹងបន្ថែមរបស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីដំណើរការរៀបចំផែនការ និងធ្វើថវិកានៅក្នុងវិស័យសុខាភិបាល ដែលប្រការនេះនឹងអនុញ្ញាតឲ្យកម្មវិធីអភិវឌ្ឍនានារបស់ពួកគេអាចបំពេញបន្ថែមលើការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល។

ការសិក្សានេះវាយតម្លៃលើ (១)-ព័ត៌មានឬឯកសារស្តីពីថវិកាដែលមានជាសាធារណៈតាមរយៈនីតិវិធីច្បាស់លាស់ ដែលធានាឲ្យមានការផ្សព្វផ្សាយនូវឯកសារសាធារណៈនានាដល់ភាគីដែលចាប់អារម្មណ៍ក្នុងពេលដំណាលគ្នា ក៏ដូចជា (២)-ព័ត៌មានឬឯកសារស្តីពីថវិកាទាំងឡាយណាដែលអាចទទួលបានល្គឹកណាមានការស្នើសុំ និងការអនុញ្ញាតពីអជ្ញាធរ។

ការសិក្សានេះបានបង្ហាញថា ប្រភេទព័ត៌មានថវិកាខ្លះមានជាសាធារណៈរួចជាស្រេច ខណៈដែលប្រភេទខ្លះទៀតអាចទទួលបានលុះត្រាតែមានការអនុញ្ញាតពីថ្នាក់លើតួយ៉ាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ឬតាមរយៈក្រុមការងារបច្ចេកទេសរួម ហើយដើម្បីអាចតាមដាន និងប្រើប្រាស់ព័ត៌មានថវិកាក្នុងវិស័យសុខាភិបាលបានត្រឹមត្រូវនិងទៀងទាត់ អង្គការមិនមែនរដ្ឋាភិបាលចាំបាច់ត្រូវយល់ពីការរៀបចំហិរញ្ញប្បទាន និងការផ្តល់សេវានៅក្នុងវិស័យនេះ។

ដំបូងគឺយល់ពីគោលនយោបាយ ដំណើរការរៀបចំផែនការនិងវាយតម្លៃក្នុងវិស័យសុខាភិបាល ដែលសម្រាប់ការងារនេះ ឯកសារទាក់ទងមួយចំនួនរួមមានដូចជា៖ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី១ និងទី២ ផែនការបីឆ្នាំរំកិលនិងផែនការប្រតិបត្តិការប្រចាំឆ្នាំ ស្ថិតិសុខាភិបាលប្រចាំឆ្នាំ និងរបាយការណ៍វាយតម្លៃរួម។

ការរៀបចំហិរញ្ញប្បទាន និងទំនាក់ទំនងរវាងគោលនយោបាយឬការធ្វើផែនការនិងថវិកាគឺជាទិដ្ឋភាពដ៏សំខាន់មួយផ្សេងទៀតដែលត្រូវយល់ដឹង។ ថវិកានៅក្នុងវិស័យសុខាភិបាលចែកចេញជា ចំណាយចរន្ត និងចំណាយមូលធន ដែលបច្ចុប្បន្ននេះ ប្រភពនៃចំណាយទាំងពីរប្រភេទនេះ រួមទាំងចំណាយរបស់ឃ្លាំងបរិក្ខារពេទ្យកណ្តាលដែលមានតួនាទីធ្វើលទ្ធកម្ម និងចែកចាយថ្នាំដល់មន្ទីរពេទ្យជាតិនិងអង្គភាពផ្តល់សេវាជួរមុខនៅថ្នាក់ក្រោមជាតិ គឺបានមកពីថវិកាជាតិ និងថវិការបស់ដៃគូអភិវឌ្ឍន៍និងអង្គការមិនមែនរដ្ឋាភិបាល។
ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ (មាត្រា៨៤) បានចែងថា "... *រាល់របាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ត្រូវមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ។* ទោះជាយ៉ាងណាក៏ដោយ ក៏នៅក្នុងការអនុវត្ត គេឃើញថាមានបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងការទទួលបានព័ត៌មាននេះ។ សម្រាប់ថវិកាជាតិ បញ្ហាប្រឈមគឺបណ្តាលមកពីប្រការដែលព័ត៌មានថវិកាត្រូវបានប្រមូលផ្តុំនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ហើយការបែកខ្ញែករវាងចំណាយចរន្ត (ដែលគ្រប់គ្រងដោយនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) និងចំណាយមូលធន (ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ក៏ជាបញ្ហាមួយផ្សេងទៀតដែរ។

ការបែកខ្ញែកនេះរឹតតែចោទបន្ថែមទៀតដល់ការប្រមូល និងវិភាគព័ត៌មានស្តីពីការគាំទ្ររបស់ម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យសុខាភិបាល ដែលដៃគូអភិវឌ្ឍន៍ទាំងនេះធ្វើការក្នុងផ្នែកផ្សេងៗបម្រើដល់ការផ្តល់សេវាសុខភាពរួមមាន ការផ្គត់ផ្គង់ថ្នាំសង្កូវ មូលនិធិសមធម៌សុខភាព និងផ្នែកប្រតិបត្តិការ

ផ្សេងៗទៀតនៃអង្គភាពផ្ដល់សេវាជួរមុខ។ មានការខិតខំប្រឹងប្រែងនានាក្នុងការប្រមូលព័ត៌មានស្ដីពីការគាំទ្រទាំងនេះដែលរួមមានជាអាទិ៍ ការធ្វើបច្ចុប្បន្នកម្មមូលដ្ឋានទិន្នន័យស្ដីពីជំនួយអភិវឌ្ឍន៍អន្តរជាតិរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មូលដ្ឋានទិន្នន័យរបស់អង្គការម៉េឌីខាំ និងប្រព័ន្ធព័ត៌មានដែលត្រូវបានផ្ដួចផ្ដើមគំនិតឡើង និងកំពុងត្រូវបានពង្រឹងបន្ថែមដោយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសុខាភិបាល។

ទោះបីជាមានការខិតខំប្រឹងប្រែងទាំងនេះ ក៏ការប្រមូលទុកដាក់ព័ត៌មានក្នុងកន្លែងតែមួយនៅតែជាបញ្ហា។ ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍នានា បាននឹងកំពុងលើកឡើងនូវគំនិតផ្ដួចផ្ដើមមួយចំនួនដើម្បីឆ្លើយតបនឹងបញ្ហានេះរួមមាន៖ ការប្រើប្រាស់នូវផែនការប្រតិបត្តិការប្រចាំឆ្នាំ ដែលត្រូវបានរៀបចំនិងវាយតម្លៃរួមគ្នាដោយក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលឯកសារនេះគឺមានលក្ខណៈលម្អិត និងអាចទទួលបានជាសាធារណៈ ការបង្កើតនូវក្រុមការងារបច្ចេកទេសរួមក្នុងវិស័យសុខាភិបាលដើម្បីធ្វើឲ្យប្រសើរឡើងនូវការទទួលបានព័ត៌មាន ស្ដីពីថវិកាក្នុងវិស័យ។ គំនិតផ្ដួចផ្ដើមផ្សេងៗដទៃទៀតរួមមានការពង្រឹងយន្តការផែនការបីឆ្នាំរំកិលនិងផែនការប្រតិបត្តិការប្រចាំឆ្នាំ ការធ្វើថវិកាកម្មវិធី ទីភ្នាក់ងារប្រតិបត្តិការពិសេស និងប្រព័ន្ធព័ត៌មានសុខាភិបាល។

នៅថ្នាក់ក្រោមជាតិ មន្ទីរសុខាភិបាលខេត្តទទួលខុសត្រូវក្នុងការបង្រួមចូលគ្នានូវផែនការប្រតិបត្តិការប្រចាំឆ្នាំ ពីមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងស្រុកប្រតិបត្តិការនានា ហើយបញ្ជូនទៅកាន់ក្រសួងសុខាភិបាល។ ផែនការប្រតិបត្តិការប្រចាំឆ្នាំថ្នាក់ខេត្តគឺត្រូវបានរៀបចំរួមគ្នាដោយស្ថាប័នសុខាភិបាល និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដែលនៅកម្រិតដដែលនេះ យន្តការក្រុមការងារបច្ចេកទេសរួមថ្នាក់ខេត្តត្រូវបានបង្កើតឡើង ហើយជួបប្រជុំជារៀងរាល់ខែ និងរៀងរាល់ត្រីមាស។ តាមរយៈក្រុមការងារបច្ចេកទេសរួមថ្នាក់ខេត្ត ព័ត៌មានថវិកាពាក់ព័ន្ធអាចស្នើសុំ និងត្រួតពិនិត្យបាន។ ពីមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងស្រុកប្រតិបត្តិការនានា ក៏មានរក្សាទុកប្រភេទស្ថិតិសុខាភិបាល និងព័ត៌មានថវិកាជាក់លាក់ផងដែរ តែទោះជាយ៉ាងនេះក្ដី ក៏ព័ត៌មានទាំងនេះអាចទទួលយកបានលុះត្រាតែមានការអនុញ្ញាតពីអជ្ញាធរពាក់ព័ន្ធ ឬតាមរយៈក្រុមការងារបច្ចេកទេសរួមថ្នាក់ខេត្ត។

ដើម្បីអាចតាមដានព័ត៌មានស្ដីពីថវិកាក្នុងវិស័យសុខាភិបាល ការសំខាន់គឺយល់ និងទទួលបាននូវបច្ចុប្បន្នកម្មទាក់ទងនឹងគំនិតផ្ដួចផ្ដើមទាំងឡាយខាងលើនៅក្នុងវិស័យ ប៉ុន្តែទាំងនេះមិនទាន់គ្រប់គ្រាន់ទេ ហើយគួរមានការយកចិត្តទុកដាក់លើការកែទម្រង់ឆ្លងកាត់វិស័យនានាជាពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ។ ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការណែនាំនូវប្លង់គណនីថ្មី ការកែលម្អនូវការគ្របដណ្ដប់និងភាពគ្រប់ជ្រុងជ្រោយនៃថវិកាជាតិ និងមូលដ្ឋានទិន្នន័យជំនួយមួយដែលពេញលេញជាងមុន គឺមានលក្ខណៈសមស្របជាពិសេសទៅនឹងការធ្វើមានព័ត៌មានថវិកាក្នុងវិស័យសុខាភិបាលច្រើនជាងមុន។

លើសពីនេះទៀត ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការកំពុងតែណែនាំនូវការកែទម្រង់មួយដែលមានលក្ខណៈស៊ីជម្រៅ តែបន្តិចម្ដងៗដល់របៀបដែលធនធាន និងសេវាសាធារណៈត្រូវបានបែងចែកនិងផ្ដត់ផ្គង់។ ជាមួយនឹងការមានរដ្ឋបាលថ្នាក់ក្រោមជាតិមួយដែលដំណើរការល្អ និងឆ្លើយតបបានកាន់តែប្រសើរ អង្គការមិនមែនរដ្ឋាភិបាល និងសាធារណជនទូទៅនឹងមានភាពងាយស្រួលច្រើនក្នុងការទាក់ទងជាមួយនឹងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីស្នើសុំព័ត៌មាន ដែលរបៀបនេះវានឹងមានភាពស្រួលប្រើជាងការដែលត្រូវដាក់ជាសំណើរផ្លូវការតាមរយៈឋានានុក្រមក្រសួងកណ្ដាល។ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលឆ្លើយតបបានកាន់តែប្រសើរ ក៏នឹងជួយធានាឲ្យមានការត្រួតពិនិត្យបានកាន់តែប្រសើរលើសកម្មភាពគម្រោង

របស់អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយផងដែរ ដែលលទ្ធផលមួយចេញពីនេះគឺការចែកចាយព័ត៌មានស្តីពីបញ្ហាថវិកាបានកាន់តែប្រសើរជាងមុន។

ចុងបញ្ចប់ ការធានាឲ្យបាន និងការលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានក្នុងវិស័យសុខាភិបាលគឺមិនមែនជាការងារមួយដែលអាចសម្រេចបានដោយការធ្វើការតែម្នាក់ឯងនៅក្នុងវិស័យនោះទេ ហើយក៏មិនអាស្រ័យលើសកម្មភាពមួយពេលប៉ុណ្ណោះដែរ។ ផ្ទុយទៅវិញ វាទាមទារឲ្យមានយន្តការមួយ ដែលអនុញ្ញាតឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងភាគីពាក់ព័ន្ធសំខាន់ៗនានា និងព័ត៌មានទាន់ហេតុការណ៍ស្តីពីវឌ្ឍនកម្មនៃការកែទម្រង់នានា។ យ៉ាងនេះក្តី ក៏មិនមែនមានន័យថាត្រូវបង្កើតឲ្យមាននូវយន្តការថ្មីឡើងវិញដែរ ប៉ុន្តែត្រូវពង្រឹងនូវអ្វីដែលមានរួចជាស្រាប់ (ដូចជា ក្រុមការងារបច្ចេកទេសរួម និងមូលដ្ឋានទិន្នន័យហិរញ្ញប្បទាននិងជំនួយផ្សេងៗទៀត)។

# ព័ត៌មានថវិកាដែលមានសម្រាប់វិស័យសុខាភិបាលនៅប្រទេសកម្ពុជា

| ស្ថាប័ន | ឯកសារ | កាលវេលាផ្សព្វផ្សាយ | អាចផ្សព្វផ្សាយបាន |
|---|---|---|---|
| រាជរដ្ឋាភិបាល | ច្បាប់ថវិកាជាតិ | ប្រចាំឆ្នាំ | សាធារណៈ |
| | ច្បាប់ទូទាត់ថវិកាជាតិ | ប្រចាំឆ្នាំ | សាធារណៈ |
| ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ឯកសារគ្រប់គ្រងថវិកា (៤ភាគ) | ប្រចាំឆ្នាំ | សាធារណៈ |
| | របាយការណ៍ស្ដីពីប្រតិបត្តិការថវិការដ្ឋ | ប្រចាំខែ និងប្រចាំឆ្នាំ | សាធារណៈ |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | មូលដ្ឋានទិន្នន័យជំនួយ | បច្ចុប្បន្នកម្មជាប្រចាំ | សាធារណៈ |
| | | | |
| ក្រសួងសុខាភិបាល នាយកដ្ឋានផែនការ | ស្ថិតិសុខាភិបាលប្រចាំឆ្នាំ | ប្រចាំឆ្នាំ | សាធារណៈ |
| | ផែនការប្រតិបត្តិការប្រចាំឆ្នាំ និងផែនការបីឆ្នាំរំកិល | ប្រចាំឆ្នាំ | សាធារណៈ |
| | របាយការណ៍វាយតម្លៃរួម | ប្រចាំឆ្នាំ | សាធារណៈ |
| ក្រសួងសុខាភិបាល នាយកដ្ឋានហិរញ្ញវត្ថុ | ផែនការថវិកាប្រចាំឆ្នាំ | ប្រចាំឆ្នាំ | តាមរយៈក្រុមការងារបច្ចេកទេសរួម |
| | របាយការណ៍ចំណាយ | ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ | |
| ក្រសួងសុខាភិបាល ឃ្លាំងបរិក្ខារពេទ្យកណ្ដាល | របាយការណ៍ថ្នាំសង្កូវ និងបរិក្ខារ | ប្រចាំត្រីមាស និងប្រចាំឆ្នាំ | |
| ក្រសួងសុខាភិបាល នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ | មូលដ្ឋានទិន្នន័យជំនួយក្នុងវិស័យ សុខាភិបាល | បច្ចុប្បន្នកម្មជាប្រចាំ | |
| | | | |
| មន្ទីរសុខាភិបាលខេត្ត និង ស្រុកប្រតិបត្តិការ | ប្រព័ន្ធព័ត៌មានសុខាភិបាល | បច្ចុប្បន្នកម្មជាប្រចាំ | តាមរយៈក្រុមការងារបច្ចេកទេសរួមថ្នាក់ខេត្ត |
| | ផែនការប្រតិបត្តិការប្រចាំឆ្នាំ និងផែនការបីឆ្នាំរំកិល | ប្រចាំឆ្នាំ | |
| | ផែនការថវិកា | ប្រចាំឆ្នាំ | |
| | ស្ថានភាពចំណាយ និងចំណូលប្រចាំខែ និងឆ្នាំ | ប្រចាំខែ និងប្រចាំឆ្នាំ | |
| | របាយការណ៍ស្ដីពីមូលនិធិសមធម៌សុខភាព | ប្រចាំត្រីមាស | |
| | របាយការណ៍ថ្នាំសង្កូវ និងបរិក្ខារ | ប្រចាំត្រីមាស និង ប្រចាំឆ្នាំ | |
| | របាយការណ៍ស្ដីពីក្រុមការងារបច្ចេកទេសរួមថ្នាក់ខេត្ត | ប្រចាំខែ និងប្រចាំឆ្នាំ | |
| មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែក | របាយការណ៍ស្ដីពីស្នាដៃអនុវត្តប្រចាំខែ និងឆ្នាំ | ប្រចាំខែ និងប្រចាំឆ្នាំ | |
| | របាយការណ៍ស្ដីពីការវិភាគចំណូល-ចំណាយ | ប្រចាំខែ និងប្រចាំឆ្នាំ | |
| | តារាងស្ដីពី មូលនិធិសមធម៌សុខភាព | ប្រចាំខែ | |

## ១. សេចក្តីផ្តើម

ការសិក្សានេះសំដៅវាយតម្លៃការមានព័ត៌មានហិរញ្ញវត្ថុ (ថវិកា) និងព័ត៌មានមិនមែនហិរញ្ញវត្ថុ (លទ្ធផលនៃចំណាយ) នៅក្នុងវិស័យសុខាភិបាលកម្ពុជានៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងមូលដ្ឋាន និងមាន គោលបំណងជាក់លាក់ចំនួនបីគឺ៖ ១)-កំណត់របៀបវារៈស្វែងរកការគាំទ្រមតិដើម្បីទាមទារឱ្យមានជា សាធារណៈនូវព័ត៌មានស្តីពីថវិកាកាន់តែច្រើនឡើង ២)-កំណត់ប្រភេទចំណាយក្រុមសង្គមស៊ីវិលអាចត្រួត ពិនិត្យបាន ៣)-កំណត់ក្រុមអង្គការមិនមែនរដ្ឋាភិបាលឬអង្គការសង្គមស៊ីវិលដែលចាប់អារម្មណ៍ក្នុងការធ្វើការ ទាក់ទងនឹងបញ្ហាថវិកាក្នុងវិស័យសុខាភិបាល។

## ២. សាវតារ

ការសិក្សានេះគឺជាសមិទ្ធផលមួយនៃការងាររបស់កម្មវិធីបញ្ហាអភិវឌ្ឍន៍ ក្នុងការតាមដានថវិកាជាតិ ហើយផ្សារភ្ជាប់ទៅនឹងការងាររបស់កម្មវិធី ក្នុងការតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ ការវិភាគថវិកាជាតិ ការស្រាវជ្រាវសន្ទស្សន៍ថវិកាបើកចំហ និងការចេញផ្សាយសៀវភៅណែនាំស្តីពី ថវិកាជាតិនាពេលថ្មីៗនេះ។ ការសិក្សានេះត្រូវបានធ្វើឡើងដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយនឹង ការសិក្សាស្តីពី "គំនូសផែនទីនៃព័ត៌មានស្តីពីថវិកានៅក្នុងវិស័យអប់រំ" ដែលត្រូវបានធ្វើឡើងដោយគម្រោង ប្រសិទ្ធភាពជំនួយនៃកម្មវិធីបញ្ហាអភិវឌ្ឍន៍។

ថ្វីបើជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផ្អែកលើការផ្តល់មូលនិធិដ៏ប្រកបដោយ ប្រសិទ្ធិភាព និងប្រសិទ្ធផលដល់ផែនការតាមវិស័យសំខាន់ៗ(សុខាភិបាល អប់រំ កសិកម្ម ។ល។)ក្តី ក៏គេមិន សូវឃើញមានការពិនិត្យមើលរបស់អង្គការសង្គមស៊ីវិលលើចំណាយរបស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយនៅ ក្នុងវិស័យទាំងនេះឡើយ។ កង្វះការពិនិត្យមើលរបស់អង្គការសង្គមស៊ីវិលអាចត្រូវបានពន្យល់ យ៉ាងហោច ណាស់មួយផ្នែក ដោយកង្វះសមត្ថភាពនៃអង្គការសង្គមស៊ីវិលកម្ពុជា និងកង្វះតម្លាភាព និងលទ្ធភាពរកបាន ព័ត៌មានអំពីចំណាយសាធារណៈនៅក្នុងវិស័យទាំងនេះ និងលទ្ធផលនៃចំណាយសាធារណៈ។

ដើម្បីជួយឱ្យអង្គការសង្គមស៊ីវិលអាចចូលរួមជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បាន ការសិក្សា នេះនឹងវាយតម្លៃមើលថាតើព័ត៌មានអ្វីខ្លះស្តីពីថវិកាដែលមានផ្សាយជាសាធារណៈ ព័ត៌មានអ្វីខ្លះដែលរកមិន បាន ចំណាយសាធារណៈអ្វីខ្លះដែលអាចត្រួតពិនិត្យមើលបានដោយក្រុមសង្គមស៊ីវិល ហើយអង្គការមិនមែន រដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិលណាខ្លះដែលអាចចាប់អារម្មណ៍លើការអនុវត្តការងារនេះ។

ការសិក្សាអំពីលទ្ធភាពទទួលព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាលនេះនឹងត្រូវបានត្រួតពិនិត្យ ដោយក្រុមអង្គការមួយក្រុមដែលមានសមាសភាពដូចខាងក្រោម៖

- ***ម៉េឌីខាំ (MEDiCAM)*** ជាអង្គការសមាជិកភាពឈានមុខគេនៅក្នុងវិស័យសុខាភិបាល ដែលមានសមាជិក អង្គការមិនមែនរដ្ឋាភិបាលជាង១០០ ដែលសកម្មនៅក្នុងវិស័យសុខាភិបាលនៅកម្ពុជា។ អង្គការម៉េឌីខាំ បំពេញមុខងារជាស្ពានមួយភ្ជាប់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងវិស័យសុខាភិបាល និងរាជរដ្ឋាភិបាល កម្ពុជា។ អាណត្តិរបស់អង្គការនេះគឺដើម្បីផ្លាស់ប្តូរព័ត៌មាន សម្របសម្រួលការស្វែងរកការគាំទ្រមតិ កសាងសមត្ថភាព ជូនអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងតំណាងឱ្យសម្លេងរបស់អង្គការមិនមែន រដ្ឋាភិបាល។ អង្គការម៉េឌីខាំគឺជាសមាជិកសកម្មមួយនៃក្រុមការងារបច្ចេកទេសនៃរាជរដ្ឋាភិបាល-ម្ចាស់

ជំនួយស្តីពីសុខភាព និងក្រុមការងារបច្ចេកទេសនៃរាជរដ្ឋាភិបាល-ម្ចាស់ជំនួយស្តីពីមេរោគអេដស៍ឬជម្ងឺអេដស៍។

- ***អង្គការហេល្សអាន់លីមីតធីដ (Health Unlimited)*** ជាសមាជិកសកម្មមួយនៃអង្គការម៉េឌីខាំ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាបានធ្វើការយ៉ាងសកម្មភាព ដែលនៅកម្ពុជាតាំងពីឆ្នាំ១៩៩០ មក។ អង្គការនេះមានការិយាល័យនៅក្នុងខេត្តចំនួន៤៖ ខេត្តរតនគិរី ព្រះវិហារ មណ្ឌលគិរី និងកំពត។ ការងាររបស់អង្គការរួមមានការផ្តល់សេវាសុខភាព ការងារស្វែងរកការគាំទ្រមតិ និងការផ្តល់អំណាចរួមមានសុខភាពមាតានិងទារក អនាម័យទឹក មេរោគអេដស៍ឬជម្ងឺអេដស៍ និងការបង្ការជម្ងឺគ្រុនចាញ់ សិទ្ធិជនជាតិដើមភាគតិច ការអប់រំសុខភាពសហគមន៍ និងការព្យាបាលជម្ងឺរបេងតាមសហគមន៍ ដោយការជួបប្រាស្រ័យផ្ទាល់។

- ***អង្គការឃែរកម្ពុជា (CARE Cambodia)*** ជាសមាជិកសកម្មមួយនៃអង្គការម៉េឌីខាំ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលបានធ្វើការជាមួយប្រជាជនកម្ពុជាតាំងពីឆ្នាំ១៩៥៨ លើកដំបូងក្នុងការផ្តល់បរិក្ខារពេទ្យ ហើយបានបើកការិយាល័យមួយក្នុងឆ្នាំ១៩៧៣ និងចាប់តាំងពីឆ្នាំ១៩៧៥ បានធ្វើការជាមួយប្រជាជនកម្ពុជានៅក្នុងជំរុំតាមព្រំដែនថៃ-កម្ពុជា។ នៅក្នុងឆ្នាំ១៩៩០ អង្គការឃែរបានជួយគាំទ្រការធ្វើមាតុភូមិនិវត្តន៍ប្រជាជនកម្ពុជាចំនួន ៣៥០.០០០នាក់ ឱ្យត្រឡប់មកផ្ទះវិញ។ អង្គការឃែរអនុវត្តកម្មវិធីសុខភាពនានាដ៏ទូលំទូលាយនៅកម្ពុជាដែលរួមមាន ការពង្រឹងប្រព័ន្ធសុខាភិបាល ការជួយឧត្តម្ភជាប្រចាំចំពោះប្រជាជនដែលឆ្លងឬរងផលប៉ះពាល់ដោយមេរោគអេដស៍ ការគាំទ្រដល់វិស័យអប់រំ ដែលរួមមានកម្មវិធីអប់រំក្រៅប្រព័ន្ធ និងកម្មវិធីអប់រំពីរភាសា ការអភិវឌ្ឍន៍ជនបទ រួមមានការត្រៀមលក្ខណៈទប់ទល់និងការបញ្ចៀសផលប៉ះពាល់នៃការរីករាលដាលជម្ងឺនិងគ្រោះមហន្តរាយ សន្តិសុខស្បៀង និងការដោះមីនបែបចម្រុះ ក៏ដូចជាការឆ្លើយតបទៅនឹងគ្រោះអាសន្ននៅក្នុងស្ថានភាពគ្រោះទឹកជំនន់ឬគ្រោះរាំងស្ងួត។ អង្គការឃែរមានការិយាល័យថ្នាក់ខេត្តនៅខេត្តប៉ៃលិន កោះកុង ព្រៃវែង និងរតនគិរី។

- **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា** ជាអង្គការសមាជិកភាពមួយដែលមានសមាជិកអង្គការមិនមែនរដ្ឋាភិបាលជាង ៨០ ហើយដែលធ្វើការពិភាក្សា ជជែក និងបង្ហាញការបារម្ភរបស់អង្គការមិនមែនរដ្ឋាភិបាលទាក់ទិននឹងការអភិវឌ្ឍប្រទេសកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា មានកម្មវិធីធំៗចំនួនបីរួមមានកម្មវិធីបញ្ហាអភិវឌ្ឍន៍ (គោលនយោបាយអភិវឌ្ឍន៍ និងគោលនយោបាយសេដ្ឋកិច្ចថវិកាជាតិ និងជំនួយ) កម្មវិធីបរិស្ថាន និងកម្មវិធីដីនិងជីវភាព។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាសមាជិកសកម្មមួយនៃក្រុមការងារបច្ចេកទេសនៃរាជរដ្ឋាភិបាល-ម្ចាស់ជំនួយស្តីពីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេសនៃរាជរដ្ឋាភិបាល-ម្ចាស់ជំនួយស្តីពីការធ្វើផែនការ និងការកាត់បន្ថយភាពក្រីក្រ។

- **យូ.អ.ស៊ី** (URC) គម្រោងពង្រឹងប្រព័ន្ធសុខាភិបាលនៅកម្ពុជា (ដែលត្រូវបានផ្តល់កិច្ចសន្យាអនុវត្តគម្រោងដោយទីភ្នាក់ងារអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់ក្រសួងសុខាភិបាលនៅកម្ពុជា ក្នុងការធ្វើផែនការគ្រប់គ្រង និងការអនុវត្តកម្មវិធីនានា ដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ឬជម្ងឺអេដស៍ ជម្ងឺរបេង និងសុខភាពគ្រួសារនៅក្នុងខេត្តចំនួន៧)។ ក្រុមការងារយូ.អ.ស៊ី ផ្តល់ជំនួយបច្ចេកទេសជូនក្រសួងសុខាភិបាល ដោយអនុវត្តអភិក្រមប្រព័ន្ធពេញលេញមួយ

ដើម្បីពង្រឹងសមត្ថភាពដល់ប្រព័ន្ធសុខាភិបាលកម្ពុជា ដើម្បីអាចធ្វើផែនការរៀបចំថវិកាហិរញ្ញប្បទាន និង ផ្តល់កញ្ចប់សេវាសុខភាពបន្តពូជ និងសុខភាពកុមារឱ្យបានកាន់តែប្រសើរឡើង។ ដោយអនុវត្តអភិក្រម ប្រព័ន្ធពេញលេញមួយដើម្បីកំណត់ និងដោះស្រាយបញ្ហានានាទាក់ទិននឹងស្នាដៃអនុវត្តក្នុងប្រព័ន្ធ សុខាភិបាល យូ.អ.ស៊ី ផ្តល់ជំនួយបច្ចេកទេសជូនក្រសួងសុខាភិបាល និងដៃគូរបស់ក្រសួងនៅកម្រិតមន្ទីរ សុខាភិបាលខេត្ត ស្រុកប្រតិបត្តិការ និងមណ្ឌលសុខភាពនៅក្នុងសមាសភាគបួនគឺ ការអភិវឌ្ឍសមត្ថភាព គ្រប់គ្រង ការពង្រឹងប្រព័ន្ធពង្រីកសេវាសុខភាព សមាហរណកម្មនិងការផ្សារភ្ជាប់សេវាមេរោគអេដស៍ឬជម្ងឺ អេដស៍ជាមួយមន្ទីរពេទ្យបង្អែកនិងជម្ងឺរបេង ព្រមទាំងការតាមដាននិងវាយតម្លៃកម្មវិធីនិងការស្វែងរកការ គាំទ្រមតិសម្រាប់ការកែលម្អប្រព័ន្ធសុខាភិបាលនៅកម្ពុជា។

## ៣. តើការសិក្សានឹងវាយតម្លៃព័ត៌មានអ្វីខ្លះ?

ការសិក្សានេះពិនិត្យមើលព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល និងការមានព័ត៌មាននេះទាំង នៅថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ។ ការសិក្សានេះផ្តោតលើអ្វីដែលកើតឡើងក្នុងការប្រតិបត្តិជាក់ស្តែង ជាជាងលើអ្វី ដែលបានលើកឡើងនៅក្នុងច្បាប់ឬបទប្បញ្ញត្តិ។ និយមន័យនៃការមានព័ត៌មានជាសាធារណៈ ត្រូវបានដកស្រង់ចេញពី **ភាពជាដៃគូថវិកាអន្តរជាតិ** (IBP) ដែលរួមមាន៖

- ព័ត៌មានដែលមានតាមរយៈនីតិវិធីកំណត់ច្បាស់លាស់ ដែលធានាការបញ្ចេញក្នុងពេលដំណាលគ្នា នូវឯកសារសាធារណៈជូនដល់គ្រប់ភាគីចាប់អារម្មណ៍ទាំងអស់ ក៏ដូចជា
- ព័ត៌មានឬឯកសារទាំងឡាយណាដែលមានតែតាមសំណើសុំប៉ុណ្ណោះ។

នៅកម្ពុជាការផ្តល់សេវាសុខភាពទទួលហិរញ្ញប្បទានជាចម្បងពីប្រភពហិរញ្ញប្បទានពីរគឺ៖ ថវិកាជាតិ និងថវិកាម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល។ ការសិក្សានេះនឹងពិនិត្យមើលប្រភពទាំងពីរនេះ ដោយ ផ្តោតតែលើបរិមាណនៃព័ត៌មានដែលមាន ហើយវាយតម្លៃថាតើព័ត៌មាននេះមានលក្ខណៈពេញលេញ ទាន់ ពេលវេលា និងសមស្របសម្រាប់ការវិភាគគោលនយោបាយដែរឬទេ។ ទិន្នន័យថវិកាដែលបានផលិតគឺកើត ចេញពីប្រព័ន្ធគ្រប់គ្រងថវិកាដែលបាននឹងកំពុងផ្លាស់ប្តូរជានិច្ចកាល ហើយការផ្លាស់នេះគឺបណ្តាលមកពី កំណែទម្រង់ផ្សេងៗក្នុងរាជរដ្ឋាភិបាលទាំងមូល។ ការសិក្សានេះកំណត់៖

- ព័ត៌មានដែលមានជាសាធារណៈ
- ព័ត៌មានដែលត្រូវបានផ្តល់យ៉ាងទៀងទាត់ ឧទាហរណ៍ ជូនដល់សមាជិកនៃក្រុមការងារបច្ចេកទេស នៅថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ក្នុងករណីដែលរាជរដ្ឋាភិបាលកម្ពុជាបញ្ជាក់ថាព័ត៌មាននេះអាច ផ្សព្វផ្សាយជាសាធារណៈបាន
- ព័ត៌មានដែលត្រូវបានផ្តល់យ៉ាងទៀងទាត់ជូនដល់សមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបរិក្ខារ។

## ៤. វិធីសាស្រ្ត និងរចនាសម្ព័ន្ធនៃរបាយការណ៍

ការសិក្សានេះប្រើវិធីសាស្រ្តទាំងឡាយដូចខាងក្រោមនេះ៖

- ស្រាវជ្រាវឯកសារ៖ ការសិក្សានេះចាប់ផ្តើម ដោយពិនិត្យមើលគោលនយោបាយតាមវិស័យ របាយការណ៍វាយតម្លៃ និងគោលនយោបាយ និងកំណែទម្រង់ទាក់ទិននឹងការផ្តល់សេវានានា ដូចជាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMRP) និងវិមជ្ឈការនិងវិសហមជ្ឈការ(D&D)។
- បទសម្ភាសន៍ជាមួយសមាជិកសំខាន់ៗនៃក្រុមប្រភពព័ត៌មាន៖ ការសម្ភាសន៍នេះគឺដើម្បីទទួលបានយោបល់ពីអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ដែលមានបទពិសោធន៍ធ្វើការលើវិស័យទាំងនេះ និងដើម្បីធានាផងដែរថាមិនមានការមើលរំលងឯកសារ និងរបាយការណ៍សំខាន់ៗ ក្នុងការពិនិត្យមើលលើការសិក្សាពាក់ព័ន្ធនានាដែលមានស្រាប់។
- បទសម្ភាសន៍ជាមួយស្ថាប័នកណ្តាល៖ ស្ថាប័នកណ្តាលទាំងនេះរួមមាន ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។ ជាកំណត់សម្គាល់ ក្រសួងមហាផ្ទៃគឺពាក់ព័ន្ធជាពិសេសសម្រាប់ការសិក្សា នេះដោយសារថាវិមជ្ឈការនិងសហវិមជ្ឈការ ដែលបាននឹងកំពុងកើតឡើងនឹងមានឥទ្ធិពលខ្លាំងលើការផ្តល់សេវាសុខភាព ក៏ដូចជាលទ្ធភាពទទួលបានព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុនៃការផ្តល់សេវាសុខភាព។
- បទសម្ភាសន៍នៅកម្រិតមូលដ្ឋានជាមួយតំណាងនៅថ្នាក់ខេត្ត ស្រុកប្រតិបត្តិការ និងមណ្ឌលសុខភាព កិច្ចការនេះរួមមានការធ្វើដំណើរទៅកាន់ខេត្តចំនួនពីរពោលគឺ ខេត្តកណ្តាល នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ និងខេត្តព្រះសីហនុ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩។

ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃការសិក្សា និងឆ្លុះបញ្ចាំងពីប្រភេទនៃប្រព័ន្ធផ្តល់ហិរញ្ញប្បទាននិងថវិកានៅក្នុងវិស័យនេះ ក្នុងពេលកន្លងមក និងពេលខាងមុខដែលមានការផ្លាស់ប្តូរគោលនយោបាយ របាយការណ៍នេះត្រូវបានរៀបចំដូចខាងក្រោម៖

- ការពិនិត្យមើលជារួមលើគោលនយោបាយ និងហិរញ្ញប្បទានក្នុងវិស័យ៖ ជំពូកនេះចាប់ផ្តើមដោយផ្តល់នូវទស្សនៈរួមសង្ខេបមួយអំពីបរិបទគោលនយោបាយ និងចំណាត់ការហិរញ្ញប្បទាននៅក្នុងវិស័យ។ ជំពូកនេះពិភាក្សាលើប្រភពហិរញ្ញប្បទានសំខាន់ៗ ធាតុនៃថវិកាសំខាន់ៗ និងលំហូរនៃមូលនិធិពីប្រភពទាំងនេះទៅកាន់អង្គភាពចំណាយផ្សេងៗនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ស្រុក និងកម្រិតផ្តល់សេវាកម្មផ្ទាល់។
- ឯកសារថវិកាដែលបានផលិត និងលទ្ធភាពរកបានឯកសារទាំងនេះ៖ ភ្ជាប់ទៅនឹងប្រភេទថវិកានីមួយៗគឺឯកសារថវិកាផ្សេងៗ ដែលត្រូវបានរៀបចំនិងរាយការណ៍ដោយស្ថាប័នចំណាយនៅតាមកម្រិតផ្សេងៗ។ បន្ទាប់មក ផ្នែកនេះកំណត់ និងពន្យល់ពីឯកសារថវិកាសំខាន់ៗដែលបានផលិតនៅតាមកម្រិតនីមួយៗ ពោលគឺព័ត៌មានថវិកាសំខាន់ៗអ្វីខ្លះដែលមាន ហើយឯកសារទាំងនេះអាចរកបានដោយរបៀបណា។
- ការមានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល៖ ការប្រែប្រួលដែលរំពឹងក្នុងរយៈពេលខ្លី និងមធ្យម៖ អ្វីដែលសំខាន់គឺថា ប្រព័ន្ធថវិកានៅក្នុងវិស័យសុខាភិបាល និងលទ្ធភាពរកបានឯកសារថវិកាទាំងនេះវិវត្តជាបន្តបន្ទាប់ ដែលជាលទ្ធផលនៃកំណែទម្រង់នានាទាំងនៅក្នុងវិស័យ និងទាំងនៅក្នុងការរៀបចំស្ថាប័ននិងការរៀបចំថវិកាជារួម។ បន្ទាប់មកផ្នែកនេះនឹងបង្ហាញពីការផ្លាស់ប្តូរនានាក្នុងគោលនយោបាយថវិកាដែលនឹងកើតឡើងក្នុងវិស័យទាំងនេះ ក៏ដូចជាកាលានុវត្តភាព និងបញ្ហាប្រឈមទាំងឡាយដែលអាចកើតឡើង។

- <u>អនុសាសន៍</u>៖ អនុសាសន៍មួយចំនួនត្រូវបានផ្តល់អំពីអ្វីដែលអង្គការមិនមែនរដ្ឋាភិបាលគប្បីធ្វើក្នុងការស្វែងរកការគាំទ្រមតិរបស់ខ្លួនអំពីលទ្ធភាពទទួលព័ត៌មាន ថវិកានៅក្នុងវិស័យសុខាភិបាលសម្រាប់រយៈពេលខ្លី មធ្យម និងវែង។

## ៥. ទស្សនៈរួមអំពីវិស័យ៖ គោលនយោបាយវឌ្ឍនភាព និងការរៀបចំហិរញ្ញប្បទាន

### ៥.១. គោលនយោបាយ និងការធ្វើផែនការ

ឯកសារគោលនយោបាយក្តោបរួមសម្រាប់វិស័យសុខាភិបាលរួមមាន គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គោលដៅទី៤ ៥ និង ៦) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០។ វិស័យសុខាភិបាល ក៏ជាផ្នែកមួយដែរនៃវិស័យយុទ្ធសាស្ត្រសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ (ឆ្នាំ២០០៤ និង ២០០៨) ដោយផ្តោតលើសសរស្តម្ភទី៤៖ កសាងសមត្ថភាពនិងអភិវឌ្ឍន៍ធនធានមនុស្ស។ ហេតុដូច្នេះការអភិវឌ្ឍវិស័យសុខាភិបាលចាំបាច់ត្រូវតែពន្យល់ឱ្យបានថាតើវិស័យនេះជួយសម្រេចគោលនយោបាយអភិវឌ្ឍន៍ធំៗរបស់រាជរដ្ឋាភិបាលយ៉ាងដូចម្តេច។

គោលនយោបាយលម្អិតមួយសម្រាប់វិស័យសុខាភិបាល គឺផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧ ដែលគេហៅថាផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី១។ ផែនការនេះផ្តល់ក្របខ័ណ្ឌមួយសម្រាប់ឱ្យរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល សហការគ្នាដើម្បី សម្រេចបានគោលដៅដែលបានកំណត់ច្បាស់លាស់ទាំងឡាយ។ ហើយបានអនុម័តយុទ្ធសាស្ត្រចំនួន២០ ដែលនៅក្នុងនោះយុទ្ធសាស្ត្រចំនួន៨ គឺជាស្នូលសំខាន់បំផុត។ ក្នុងចំណោមយុទ្ធសាស្ត្រស្នូលទាំងនេះ អាទិភាពកំពូលគឺត្រូវកែលម្អការផ្តល់សេវាសុខភាពដែលរួមមាន (១)-ការកែលម្អលទ្ធភាពទទួលសេវា និងវិសាលភាពផ្តល់សេវាជូនដល់ប្រជាជនក្រីក្រ (២)-ការផ្តល់នូវកញ្ចប់សកម្មភាពអប្បបរមានៅកម្រិតមណ្ឌលសុខភាព និង (៣)ការផ្តល់នូវកញ្ចប់សកម្មភាពបំពេញបន្ថែមនៅមន្ទីរពេទ្យបង្អែក។ ដែលត្រូវបានរាប់ជាយុទ្ធសាស្ត្រអាទិភាពផងដែររួមមានការផ្លាស់ប្តូរឥរិយាបថរបស់អ្នកផ្តល់សេវាសុខភាព ការកែលម្អគុណភាព ការអភិវឌ្ឍធនធានមនុស្សដោយផ្តោតលើការបណ្តុះបណ្តាលផ្ទួន និងកំណែទម្រង់ស្ថាប័នផ្សេងទៀត។ នៅចុងឆ្នាំ២០០៧ ការវាយតម្លៃផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលមួយបានរកឃើញថានៅក្នុងអំឡុងពេលនេះ ប្រទេសកម្ពុជាសម្រេចបានការកែលម្អខ្លះៗក្នុងការបង្កើនការប្រើប្រាស់សេវាសុខភាព ការកាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងអត្រាមរណភាពទារកនិងកុមារ ប៉ុន្តែសម្រាប់ការកែលម្អអត្រាមរណភាពមាតា សមិទ្ធិផលនៅមានលក្ខណៈតិចតួចនៅឡើយ (Ortendahl, Donoghue និងអ្នកផ្សេងទៀត ឆ្នាំ២០០៧)។

កាលពីខែមេសា ឆ្នាំ២០០៨ ក្រសួងសុខាភិបាលបានអនុម័តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី២សម្រាប់ឆ្នាំ២០០៨-២០១៥។ ផែនការនេះលើកឡើងនូវអាទិភាព (១)-កាត់បន្ថយការមានជម្ងឺនិងមរណភាពនៃមាតា ទារក និងកុមារ ទន្ទឹមគ្នានឹងការជម្រុញបង្កើនសុខភាពបន្តពូជ (២)-កាត់បន្ថយការមានជម្ងឺនិងមរណភាពពីមេរោគអេដស៍ឬជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ របេង និងជម្ងឺឆ្លងផ្សេងទៀត និង (៣)-កាត់បន្ថយបន្ទុកនៃជម្ងឺមិនឆ្លងនិងបញ្ហាសុខភាពដ៏ទៃទៀត។ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី២ បន្តបេសកកម្មគន្លឹះមួយចំនួនពីផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី១ ប៉ុន្តែផ្តល់នូវទស្សនៈផ្សេងមួយអំពីអាទិភាពនៃវិស័យសុខាភិបាលនាពេលអនាគត។ ទីមួយ ដូចដែលត្រូវបានលើកឡើងដោយឯកសាររបស់ធនាគារពិភពលោកផងដែរ (កម្មវិធីគាំទ្រវិស័យសុខាភិបាលទី២ ទំព័រ២៨) ប្រទេសកម្ពុជា ចាំបាច់ត្រូវផ្តោតបន្ថែមលើសុខភាពមាតា បន្តពង្រឹងសុខភាពកុមារ និងដោះស្រាយបញ្ហាជម្ងឺឆ្លងនានា។ ប្រព័ន្ធសុខាភិបាលក៏

ចាំបាច់ត្រូវត្រៀមលក្ខណៈផងដែរដើម្បីឆ្លើយតបនឹងជម្ងឺឆ្លងទើបលេចចេញនាពេលថ្មីៗនេះ និងជម្ងឺមិនឆ្លងនានា ហើយអន្តរាគមន៍អន្តរវិស័យក៏មានសារៈសំខាន់ផងសម្រាប់ការដោះស្រាយបញ្ហានានាដូចជា ការអប់រំកុមារី ការមានបង្គន់អនាម័យ និងទឹកស្អាត។

ដើម្បីអនុវត្តគោលដៅគោលនយោបាយទាំងនេះ វិស័យសុខាភិបាលបានអនុម័តនូវដំណើរការរៀបចំផែនការនិងធ្វើថវិកា ដែលមានសសរស្តម្ភពីរគឺៈ ផែនការបីឆ្នាំរំកិល និងផែនការប្រតិបត្តិការប្រចាំឆ្នាំ។ ផែនការបីឆ្នាំរំកិលគឺជាក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលត្រូវបានរៀបចំដោយអង្គភាពផ្សេងៗនៃក្រសួងសុខាភិបាល នាយកដ្ឋាន មណ្ឌលជាតិនិងខេត្ត។ ផែនការទាំងនេះគឺផ្អែកលើតម្រូវការហិរញ្ញប្បទាននានានៃវិស័យនេះ (ពីក្រោមឡើងលើ) និងការព្យាករកញ្ចប់ធនធានពីគ្រប់ប្រភពទាំងអស់ (ពីលើចុះក្រោម)។ ថ្លៃចំណាយពីក្រោមឡើងលើ និងកញ្ចប់ធនធានពីលើចុះក្រោម ត្រូវបានផ្ទូរផ្ទងគ្នានៅក្នុងបរិបទនៃដំណើរការរៀបចំផែនការនិងធ្វើថវិកាប្រចាំឆ្នាំ ដើម្បីជាព័ត៌មានសម្រាប់ការសម្រេចចិត្តស្តីពីវិភាជន៍ធនធានដល់អាទិភាពនានាទាំងនៅក្នុងវិស័យនិងអន្តរវិស័យ។ ផែនការបីឆ្នាំរំកិលទាំងនេះត្រូវបានបំបែកជា ផែនការប្រតិបត្តិការប្រចាំឆ្នាំ ដែលបញ្ជាក់ពីផែនការសកម្មភាពនិងថវិកាលម្អិត រួមនឹងសូចនាករអនុវត្តជាកលាក់នានា។ ថ្វីបើបច្ចុប្បន្ននេះមិនទាន់មានក្តី ក៏នៅទីបំផុតផែនការប្រតិបត្តិការប្រចាំឆ្នាំនឹងបញ្ចូលគ្រប់សកម្មភាពទាំងអស់ដោយមិនគិតពីប្រភពមូលនិធិ (ឧទាហរណ៍ ថវិការាជរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល) (ធនាគារពិភពលោក ឆ្នាំ២០០៨ ទំព័រ៦០)។ ប្រការសំខាន់ដែលត្រូវកត់សម្គាល់គឺថា ផែនការប្រតិបត្តិការប្រចាំឆ្នាំ គឺជាផែនការដែលត្រូវដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំការយល់ព្រម ឬធ្វើការចរចារ ហើយផែនការនេះមិនមានវិភាជន៍ ឬសិទ្ធិទទួលវិភាជន៍ជាក់ស្តែងទេ។ សម្រាប់ព័ត៌មានបន្ថែមស្តីពីផែនការប្រតិបត្តិការប្រចាំឆ្នាំ សូមមើលផ្នែក៦.១. (ស្តីពីព័ត៌មានស្តីពីថវិកានៅថ្នាក់ជាតិ)។

ដំណើរការរៀបចំផែនការនិងធ្វើថវិកា ចាប់ផ្តើមក្នុងខែមករា ជាមួយនឹងការធ្វើបច្ចុប្បន្នកម្មផែនការបីឆ្នាំរំកិល ហើយបន្ទាប់មកមានការធ្វើមហាសន្និបាតសុខាភិបាលប្រចាំឆ្នាំក្នុងខែមីនា ដើម្បីវាយតម្លៃសកម្មភាពវិស័យជាទូទៅ ហើយមហាសន្និបាតនេះមានការចូលរួមពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។ បន្ទាប់ពីមហាសន្និបាតនេះ មានការពិនិត្យឡើងវិញរួមគ្នាលើស្នាដៃអនុវត្តប្រចាំឆ្នាំ ដែលនៅក្នុងនោះ (ក)-ក្រុមភាគីពាក់ព័ន្ធដ៏ធំមួយធ្វើការពិភាក្សាលើគោលនយោបាយសុខាភិបាលនានា (ខ)-មានការវាស់វែងវឌ្ឍនភាពប្រៀបធៀបទៅនឹងសូចនាករស្នូល និង (គ)-មានការកំណត់គោលដៅថ្នាក់ជាតិនានាសម្រាប់ផ្នែកអាទិភាពទាំងឡាយនៃវិស័យសុខាភិបាលដែលត្រូវបានកំណត់សម្រាប់វគ្គបន្ទាប់។ ការពិនិត្យឡើងវិញនេះ រៀបចំមូលដ្ឋានសម្រាប់ការរៀបចំផែនការប្រតិបត្តិការប្រចាំឆ្នាំនៃឆ្នាំបន្ទាប់។ ផែនការប្រតិបត្តិការប្រចាំឆ្នាំត្រូវបានរៀបចំដោយមណ្ឌលសុខភាព មន្ទីរពេទ្យ ស្រុកប្រតិបត្តិការ មន្ទីរសុខាភិបាលខេត្ត និងនាយកដ្ឋានកណ្តាលនៃក្រសួងសុខាភិបាល គ្រឹះស្ថានបណ្តុះបណ្តាល និងមជ្ឈមណ្ឌលជាតិទាំងអស់ ហើយបូកសរុបបញ្ចូលគ្នានៅថ្នាក់ខេត្តនិងថ្នាក់ជាតិ។ នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលប្រើប្រាស់ផែនការនេះក្នុងការចរចារថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងខែកក្កដា ហើយធ្វើការពិនិត្យមើលឡើងវិញ និងវាយតម្លៃលើផែនការនេះក្នុងខែសីហា និងខែកញ្ញា រួមទាំងវាយតម្លៃរួមដោយក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍។ បន្ទាប់ពីថវិការដ្ឋត្រូវបានអនុម័តដោយច្បាប់រួច ផែនការប្រតិបត្តិការប្រចាំឆ្នាំដែលបានបញ្ចប់នេះ ត្រូវបានដាក់ជូនគណៈកម្មាធិការដឹកនាំវិស័យសុខាភិបាល ដើម្បីសុំការយល់ព្រម (ធនាគារពិភពលោក ឆ្នាំ២០០៨ ទំព័រ៦០)។

## ៥.២. ហិរញ្ញប្បទាន

វិស័យសុខាភិបាលនៅកម្ពុជាទទួលហិរញ្ញប្បទានពីប្រភពផ្សេងៗរួមមាន (១)-ចំណាយចេញពីហោប៉ៅរបស់គ្រួសារ (២)-ថវិកាជាតិ និង (៣)-ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលជួយគាំទ្រ និងធ្វើការនៅក្នុងវិស័យនេះ។ ដូចនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍផ្សេងទៀតជាច្រើនដែរ ហិរញ្ញប្បទានវិស័យសុខាភិបាលកម្ពុជាគឺ គ្របដណ្តប់ដោយចំណាយចេញពីហោប៉ៅ។ ប្រៀបធៀបទៅនឹងប្រទេសជិតខាង ចំណែកដ៏ធំនៃចំណាយសុខភាពរបស់ប្រទេសកម្ពុជាគឺបានមកពីក្រុមគ្រួសារឯកជន (រូបទី១)។ ក្នុងឆ្នាំ២០០៥ ជាមួយប្រាក់ចំណូលប្រចាំឆ្នាំក្នុងប្រជាជនម្នាក់ចំនួន ៤៣០ដុល្លារអាមេរិក ចំណាយក្នុងប្រជាជនម្នាក់លើសុខភាពត្រូវបានប៉ាន់ស្មានថាមានចំនួន ៣៧ដុល្លារអាមេរិក ដែលនៅក្នុងនោះ ៦៨% គឺជាចំណាយចេញពីហោប៉ៅផ្ទាល់ ២២% បានមកពីម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល និង ១០% បានមកពីក្រសួងសុខាភិបាល។

**រូបទី១៖** ចំណាយលើសុខភាពក្នុងប្រជាជនម្នាក់ក្នុងឆ្នាំ ២០០៥ (ដុល្លារអាមេរិក)




ប្រភព៖ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី២

**រូបទី២៖** ហិរញ្ញប្បទានវិស័យសុខាភិបាលសម្រាប់ឆ្នាំ ២០០៨




ប្រភព៖ ផែនការប្រតិបត្តិការប្រចាំឆ្នាំ ២០០៨

ដោយមិនគិតពីចំណាយចេញពីហោប៉ៅ ចំណែកនៃចំណាយថវិកាជាតិបានកើនឡើងជាប្រចាំពីមួយឆ្នាំទៅមួយឆ្នាំ។ ប្រៀបធៀបទៅនឹងឆ្នាំ២០០៧ ថវិកាជាតិសម្រាប់វិស័យនេះកើនឡើងបាន ២០% ក្នុងឆ្នាំ ២០០៨ បើយោងតាមច្បាប់ថវិកាជាតិឆ្នាំ២០០៧ និង២០០៨។ ម៉្យាងទៀត ដោយយោងតាមផែនការប្រតិបត្តិការប្រចាំឆ្នាំ២០០៨ ដូចដែលមានបង្ហាញជូនក្នុងរូបទី២ ថវិកាជាតិរួមចំណែក ៦២%នៃហិរញ្ញប្បទានសរុបចំនួន ១៦៥លានដុល្លារអាមេរិក ហើយវិភាគទានរបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលរួមចំណែកជិត ៣៥% ដែលនៅក្នុងនោះ ១៥% បានមកពីកម្មវិធីធនធានរួមដែលមានឈ្មោះថា កម្មវិធីគាំទ្រវិស័យសុខាភិបាល ដែលគឺជាប្រភេទអភិក្រមទូទាំងវិស័យមួយ (Sector Wide Approach) មួយនៃហិរញ្ញប្បទានដោយជំនួយបរទេស។ យ៉ាងណាក្តី ផែនការប្រតិបត្តិការប្រចាំឆ្នាំទទួលស្គាល់ថា ហិរញ្ញប្បទានពីម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលអាចមិនត្រូវបានរាប់បញ្ចូលបានពេញលេញទេ ដោយសារព័ត៌មានហិរញ្ញប្បទានដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលមានលក្ខណៈមិនពេញលេញ។

ដូចបានលើកឡើងខាងដើម ផែនការប្រតិបត្តិការប្រចាំឆ្នាំឬផែនការបីឆ្នាំរំកិលគឺជា ឯកសាររៀបចំផែនការនិងធ្វើថវិកាចម្បងគេនៃវិស័យសុខាភិបាល។ ឯកសារទាំងនេះបង្ហាញទាំងប្រភពហិរញ្ញប្បទានសំខាន់ៗ (តួយ៉ាងថវិកាជាតិ និងថវិកាម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល) ព្រមទាំងកម្មវិធី និងអនុកម្មវិធីដែលត្រូវទទួលមូលនិធិនេះ។ ឧទាហរណ៍ នៅក្នុង

**រូបទី៣៖** វិភាជន៍មូលនិធិតាមកម្មវិធី និងក្រៅកម្មវិធី




ប្រភព៖ ផែនការប្រតិបត្តិការប្រចាំឆ្នាំ ២០០៨

ឆ្នាំ២០០៨ មានកម្មវិធីចំនួន៤ និងមិនមែនកម្មវិធីចំនួន១ ដែលត្រូវផ្តល់មូលនិធិ ហើយកម្មវិធីទាំង៤នោះរួមមាន (១)-អភិវឌ្ឍន៍ស្ថាប័ន (២)-សុខភាពមាតានិងកុមារ (៣)-ជម្ងឺឆ្លង និង (៤)-ជម្ងឺមិនឆ្លង។ មិនមែនកម្មវិធីគឺសំដៅជាចម្បងដល់ការផ្គត់ផ្គង់ថ្នាំនិងសម្ភារៈពេទ្យ។ ដើម្បីផ្តល់ជារូបភាពងាយយល់មួយនៃរបៀបដែលហិរញ្ញប្បទានសរុបត្រូវបានបែងចែកសម្រាប់ឆ្នាំ២០០៨ រូបទី៣បង្ហាញពីសំណើថវិកា[1] ចំនួនប្រហែល ២០១លានដុល្លារអាមេរិក (ប្រៀបធៀបនឹងមូលនិធិចំនួនតែ ១៦៥លានដុល្លារអាមេរិក ប៉ុណ្ណោះដែលត្រូវបានអនុម័ត ដូចដែលបានបង្ហាញជូនខាងលើ) ដែលត្រូវបានបែងចែកសម្រាប់កម្មវិធី និងមិនមែនកម្មវិធីនានា ហើយដូចដែលបានបង្ហាញ ចំណាយមិនមែនកម្មវិធីគឺជាចំណែកធំបំផុតនៃសំណើថវិកាទាំងអស់។

ហិរញ្ញប្បទានដោយថវិកាជាតិត្រូវបានគ្រប់គ្រងតាមប្រព័ន្ធហិរញ្ញវត្ថុជាតិ ដែលខុសគ្នាពីប្រព័ន្ធដែលត្រូវអនុវត្តលើថវិការបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល។ យោងតាមអនុក្រឹត្យលេខ ១៧០ អនក្រ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៦ ថវិកាជាតិមានសមាភាគដូចខាងក្រោម៖

**ចំណាយចរន្ត**

- ការទិញទំនិញ (ជំពូក៦០ - ជំពូកនេះរាប់បញ្ចូលមួយផ្នែកធំនៃជំពូក១១ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៧ និងអនុជំពូករងចំនួន ២១)។ ខ្ទង់ចំណាយធំៗក្រោមសមាសភាគនេះរួមមានចំណាយប្រតិបត្តិការទូទៅនិងថែទាំ ចំណាយលើគ្រឿងសង្ហារឹមនិងទឹកភ្លើង។
- ការទិញសេវា (ជំពូក៦១ - ជំពូកនេះរាប់បញ្ចូលផ្នែកខ្លះៗនៃជំពូក១១ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៨ និងអនុជំពូករងចំនួន ១១)។ ខ្ទង់ចំណាយធំៗក្រោមសមាសភាគនេះរួមមានការបណ្តុះបណ្តាល ជួសជុល ធានារ៉ាប់រង និងមធ្យោបាយដឹកជញ្ជូន។
- សេវាផ្សេងទៀត (ជំពូក៦២ - ជំពូកនេះរាប់បញ្ចូលផ្នែកខ្លះៗនៃជំពូក១១ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៨ និងអនុជំពូករងចំនួន ១៨) នៅក្នុងសមាសភាគនេះ ខ្ទង់ចំណាយសំខាន់ៗរួមមាន ប្រាក់កម្រៃសម្រាប់បុគ្គលិកជាប់កិច្ចសន្យា ចំណាយ"ទទួលភ្ញៀវ" ចំណាយពិធីផ្សេងៗមួយចំនួន និងចំណាយលើការផ្សាយតាមសារព័ត៌មាន។
- ចំណាយបុគ្គលិក (ជំពូក៦៤ - ជំពូកនេះរាប់បញ្ចូលមួយផ្នែកធំនៃជំពូក១០ នៃប្លង់គណនីចាស់ ហើយមានជំពូករងចំនួន ៥ និងអនុជំពូករងចំនួន ៣០)។ ខ្ទង់ចំណាយធំៗក្រោមសមាសភាគនេះរួមមានប្រាក់ខែមូលដ្ឋាន ប្រាក់ឧបត្ថម្ភ កន្សោមអាទិភាព និងសង្គមកិច្ច (ឧទាហរណ៍ ប្រាក់សោធននិវត្តន៍)។

**ចំណាយមូលធន**

- វិនិយោគមិនមានរូបរាង (ជំពូក២០) ភាគច្រើនរួមមាន ការស្រាវជ្រាវនិងអភិវឌ្ឍន៍។
- វិនិយោគមានរូបរាង (ជំពូក២១) រួមមាន ការសាងសង់ ការជួសជុលអាគារ យានយន្ត និងទ្រព្យប្រើបានយូរដទៃទៀត។

[1]ព័ត៌មានអំពីរបៀបដែលមូលនិធិចំនួន ១៦៥លានដុល្លារអាមេរិក ត្រូវបានបែងចែកជាក់ស្តែងគឺមិនអាចរកបាន។

គេគប្បីគួរកត់សម្គាល់ថាដូចករណីនៃវិស័យផ្សេងទៀតដែរ មានតែថវិកាចរន្តប៉ុណ្ណោះដែលត្រូវបានវិភាជទៅឱ្យវិស័យសុខាភិបាល រីឯចំណាយមូលធនដែលទទួលហិរញ្ញប្បទានពីថវិកាជាតិត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថវិកាចរន្តដែលបានវិភាជទាំងនោះ ត្រូវបានប្រើជាចម្បងលើថ្លៃបុគ្គលិក ប្រតិបត្តិការ និងសម្ភារៈប្រើប្រាស់។

នៅក្នុងចំណាយចរន្តនេះ វិស័យសុខាភិបាលក៏មានការធ្វើថវិកាតាមកម្មវិធីផងដែរ ដែលគឺជាគំនិតផ្តួចផ្តើមកំណែទម្រង់ថ្មីមួយ ផ្អែកលើបទពិសោធន៍ពីគំនិតផ្តួចផ្តើមគ្រប់គ្រងហិរញ្ញវត្ថុចំនួន២គឺ ពន្លឿនការប្រើប្រាស់ចំណាយថ្នាក់ស្រុក (Accelerated District Disbursement) ដែលបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩៦ និងកម្មវិធីសកម្មភាពអាទិភាព ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០០០ និងបញ្ចប់ក្នុងឆ្នាំ២០០៦។ យ៉ាងណាក្តី ខុសពីវិស័យអប់រំ វិសាលភាពនៃការធ្វើថវិកាតាមកម្មវិធីក្នុងវិស័យសុខាភិបាលគឺនៅមានកម្រិតហើយធ្វើបានត្រឹមតែ ១០% ប៉ុណ្ណោះនៃចំណាយចរន្តសរុបក្នុងឆ្នាំ២០០៨ និងត្រូវបានអនុវត្តតែនៅថ្នាក់ជាតិប៉ុណ្ណោះ។

ថវិកាជាតិ ក៏រួមចំណែកផងដែរដល់មូលនិធិសមធម៌ និងធានារ៉ាប់រងសុខភាព ដែលចាប់ផ្តើមឡើងពីឆ្នាំ២០០៧ ប៉ុន្តែនៅក្នុងឆ្នាំនោះ វិភាគទានរបស់រាជរដ្ឋាភិបាលចំពោះមូលនិធិនេះគឺមានត្រឹមតែ ២៧% ប៉ុណ្ណោះ ហើយចំណែកដែលនៅសេសសល់ទាំងបុន្មានទទួលហិរញ្ញប្បទានពីម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល (របាយការណ៍របស់ក្រសួងសុខាភិបាលស្តីពីវឌ្ឍនភាពសុខាភិបាលពីឆ្នាំ២០០៣-២០០៧ ដែលត្រូវបានចេញផ្សាយក្នុងឆ្នាំ២០០៨)។

## ៥.៣. ការសម្របសម្រួលរបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យសុខាភិបាល

**រូបទី៤៖** ការជួយគាំទ្ររបស់ម្ចាស់ជំនួយចំពោះវិស័យសុខាភិបាល




ប្រភព៖ របាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយឆ្នាំ ២០០៨

កម្ពុជាគឺជាប្រទេសមួយដែលពឹងផ្អែកលើជំនួយបរទេសជាច្រើន សម្រាប់ផ្គត់ផ្គង់វិស័យផ្សេងៗរបស់ខ្លួន។ សុខាភិបាលគឺជា វិស័យមួយក្នុងចំណោមវិស័យទាំងឡាយដែលទទួលបានការជួយគាំទ្រខ្ពស់បំផុតពីមូលនិធិទាំងនេះ ហើយម្ចាស់ជំនួយផ្តល់ហិរញ្ញប្បទានដល់វិស័យនេះ តាមវិធីផ្សេងៗជាច្រើនរួមមាន ការដាក់ធនធានរួម គម្រោងដាច់ដោយឡែក និងតាមរយៈអង្គការមិនមែនរដ្ឋាភិបាល។ ចំណាត់ការហិរញ្ញប្បទានមានលក្ខណៈដាច់ដោចខ្លាំង ហើយគេមិនដឹងទេថា តើមានការជួយគាំទ្រប៉ុន្មានសម្រាប់ឆ្នាំនីមួយៗ។ របាយការណ៍ស្តីប្រសិទ្ធិភាពជំនួយដែលទើបចេញនៅពេលថ្មីៗនេះ (ដែលប្រហែលគឺជាប្រភពអាចទុកចិត្តបានជាងគេបំផុត) បង្ហាញថា វិស័យសុខាភិបាល រាប់បញ្ចូលទាំងការជួយគាំទ្រដាក់លាក់សម្រាប់វិស័យមេរោគអេដស៍ គឺជាស្ថាប័នទទួលជំនួយបរទេសធំជាងគេបំផុតមកដល់ពេលនេះ ដូចដែលមានបង្ហាញជូនក្នុងរូបទី៤។

ចំណែកដ៏ធំនៃមូលនិធិរបស់ម្ចាស់ជំនួយ ក៏បង្ហាញផងដែរពីសកម្មភាពដ៏ច្រើនរបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល។ នៅក្នុងចំណោមដៃគូអភិវឌ្ឍន៍ចំនួន ៣២ ដែលធ្វើការនៅកម្ពុជា ដៃគូអភិវឌ្ឍន៍

ចំនួន ២២ បាននឹងកំពុងធ្វើការនៅក្នុងវិស័យនេះ ដោយដំណើរការគម្រោងចំនួន ១០៩ ហើយក្នុងចំណោមមូលនិធិចំនួន ១៨៣,៥លានដុល្លារអាមេរិក ដែលបានមកពីអង្គការមិនមែនរដ្ឋាភិបាល មូលនិធិប្រហែល ២៥% ត្រូវបានវិភាជទៅឱ្យវិស័យសុខាភិបាល។ ម៉្យាងទៀត យោងតាមបទសម្ភាសន៍ជាមួយមន្ត្រីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសុខាភិបាល មានអង្គការមិនមែនរដ្ឋាភិបាលចំនួនប្រហែល ១២០ ដែលឥឡូវនេះកំពុងធ្វើការនៅក្នុងវិស័យ។

ប្រាក់របស់ម្ចាស់ជំនួយត្រូវបានប្រើប្រាស់សម្រាប់ចំណាយគ្រប់ប្រភេទទាំងអស់ដូចជា ចំណាយបុគ្គលិក ប្រតិបត្តិការ ឱសថ និងចំណាយដទៃទៀត ហើយហិរញ្ញប្បទានសម្រាប់ចំណាយទាំងនេះគឺមានរបៀបខុសគ្នាច្រើន។ ថវិកាម្ចាស់ជំនួយ ត្រូវបានផ្តល់ជូនទាំងខាងផ្នែកផ្គត់ផ្គង់ (ដូចជា សម្រាប់កែលម្អសេវាសុខភាព) និងខាងផ្នែកតម្រូវការ (ដូចជា មូលនិធិសមធម៌សុខភាព និងហិរញ្ញប្បទានធានារ៉ាប់រងដទៃទៀត)។ គេក៏កត់សម្គាល់ឃើញផងដែរថា ម្ចាស់ជំនួយបាននឹងកំពុងគាំទ្រវឹតតែច្រើនដល់កម្មវិធីជាតិផ្សេងៗដូចជា មេរោគអេដស៍ឬជម្ងឺអេដស៍ ជម្ងឺគ្រុនចាញ់ ជម្ងឺរបេង និងជម្ងឺផ្សេងៗទៀត ជាជាងដល់ការថែទាំសុខភាពបឋម (ក្រសួងសុខាភិបាល ឆ្នាំ២០០៨)។

ទំហំនៃការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងរបៀបហិរញ្ញប្បទានផ្សេងៗដែលម្ចាស់ជំនួយបានប្រើចោទជាបញ្ហាប្រឈមធំមួយសម្រាប់សុខុដុមនីយកម្មនិងការតម្រឹមតាមផែនការប្រទេស។ សុខុដុមនីយកម្មនិងការតម្រឹមតាមផែនការប្រទេស នៅក្នុងវិស័យសុខាភិបាល មានន័យថាគ្រប់ហិរញ្ញប្បទានទាំងអស់ដែលមានត្រូវបានប្រើប្រាស់ក្នុងលក្ខណៈចុះសម្រុងនឹងគ្នា ដើម្បីជួយគាំទ្រដល់អាទិភាពជាតិតែមួយ (ក្រសួងសុខាភិបាល ឆ្នាំ២០០៨)។ មានវិធានការផ្សេងៗ ដែលត្រូវបានគេអនុវត្តដើម្បីសម្រេចបានគោលដៅនេះនៅក្នុងវិស័យសុខាភិបាល (កម្មវិធីគាំទ្រវិស័យសុខាភិបាលទី២ ទំព័រ៦២):

- អនុម័តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី១ និងផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី២ ដែលកំណត់អាទិភាពនានារបស់វិស័យដែលម្ចាស់ជំនួយនិងការគាំទ្រងទៀតចាំបាច់ត្រូវសម្របតាម។
- ប្រើប្រាស់អភិក្រមទូទាំងវិស័យឬការគ្រប់គ្រងទូទាំងវិស័យ (SWAp/SWiM) ដើម្បីប្រមូលធនធានរបស់ម្ចាស់ជំនួយដាក់រួមគ្នា ដើម្បីគាំទ្រដល់វិស័យនេះ (បច្ចុប្បន្ននេះ មានម្ចាស់ជំនួយតែមួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវបានរាប់បញ្ចូលក្នុងកម្មវិធីគាំទ្រវិស័យសុខាភិបាលទី២ និង SWiM ដែលរួមមាន ធនាគារពិភពលោក ទីភ្នាក់ងារអូស្ត្រាលីសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (AusAID) និងអង្គការ DFID)។
- បង្កើតក្រុមការងារបច្ចេកទេសរួមផ្នែកសុខាភិបាល និងយន្តការស្រដៀងគ្នានៅថ្នាក់ខេត្ត ដែលមានឈ្មោះថាក្រុមការងារបច្ចេកទេសរួមផ្នែកសុខាភិបាលថ្នាក់ខេត្ត។
- បង្កើតវេទិកាផ្សេងទៀត ដែលរួមបញ្ចូលទាំងក្រុមដៃគូវិស័យសុខាភិបាល និងក្រុមការងាររាជរដ្ឋាភិបាលស្តីពីសុខុដុមនីយកម្ម និងការតម្រឹមតាមផែនការប្រទេស។
- ធ្វើការវាយតម្លៃរួមលើស្នាដៃអនុវត្តប្រចាំឆ្នាំ វាយតម្លៃផែនការប្រតិបត្តិការប្រចាំឆ្នាំ ព្រមទាំងពិនិត្យឡើងវិញ និងវាយតម្លៃវដ្តនៃការរៀបចំផែនការ និងធ្វើថវិការបស់ក្រសួងសុខាភិបាល ។ល។
- អនុម័តផែនការប្រតិបត្តិការប្រចាំឆ្នាំ (សូមមើលខាងលើ)។

### ៥.៤. រចនាសម្ព័ន្ធស្ថាប័ន និងប្រព័ន្ធផ្តល់សេវា

ក្រសួងសុខាភិបាលគឺជាស្ថាប័នចម្បង ទទួលបន្ទុកលើការផ្តល់សេវាសុខភាព ហើយត្រូវបានរៀបចំជារចនាសម្ព័ន្ធខ្សែបណ្តោយមួយដែលមានស្ថាប័ននានាដូចខាងក្រោម៖

- ថ្នាក់កណ្តាល៖ ក្រសួងសុខាភិបាល កម្មវិធីថ្នាក់ជាតិ និងមន្ទីរពេទ្យជាតិ
- ថ្នាក់ខេត្ត៖ (មន្ទីរសុខាភិបាលខេត្ត)
- ថ្នាក់ស្រុក៖ (ស្រុកប្រតិបត្តិការ)
- អង្គភាពផ្តល់សេវាជួរមុខ (មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិសុខភាព)
- អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការជាអ្នកម៉ៅការផ្តល់សេវា
- គណៈកម្មាធិការសុខភាពសហគមន៍ និង
- ប្រជាជន

ចាប់តាំងពីដំណាក់កាលដំបូងនៃការអភិវឌ្ឍស្ថាប័នរបស់ខ្លួន វិស័យសុខាភិបាលបានផ្តោតលើសារៈសំខាន់នៃថ្នាក់ "ស្រុក" ពោលគឺ ស្រុកប្រតិបត្តិការ។ យុត្តាធិការនៃស្រុកប្រតិបត្តិការមួយមិនមែនសុទ្ធតែត្រូវគ្នាជាមួយស្រុករដ្ឋបាលមួយឡើយ ដោយសារតែព្រំដែនរបស់វាត្រូវបានគូសដោយផ្អែកលើចំនួនប្រជាជន ពោលគឺ មិនមែនផ្អែកលើព្រំដែនរដ្ឋបាលតាមទម្លាប់ឡើយ។ នៅក្នុងប្រព័ន្ធបច្ចុប្បន្ន (ឆ្នាំ២០០៧) យោងតាមផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី២ (ក្រសួងសុខាភិបាល ឆ្នាំ២០០៨ ទំព័រ១៦) ប្រជាជនចំនួនប្រហែល ២២% ស្វែងរកសេវាសុខភាពពីស្ថាប័នសាធារណៈ និងបានទទួលសេវានេះពីបណ្តាញមួយ ដែលភាគច្រើនរួមមាន៖

- ស្រុកប្រតិបត្តិការចំនួន ៧៧ ដែលនៅក្នុងនោះមាន
- មណ្ឌលសុខភាពចំនួន ៩៥៦ និង
- មន្ទីរពេទ្យបង្អែកចំនួន ៧៤

ផែនការផ្តល់សេវាសុខភាពមួយ ដែលត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៦ បានប្រែក្លាយឱ្យទៅជាប្រព័ន្ធនូវការស្ថាបនាឡើងវិញ និងការបំពាក់បុគ្គលិកសម្រប់បណ្តាញមន្ទីរពេទ្យសាធារណៈ ឲ្យស្របតាមបទដ្ឋានដែលផ្អែកលើចំនួនប្រជាជន ហើយបានកំណត់នូវកញ្ចប់សេវាដែលគប្បីត្រូវបានផ្តល់នៅកម្រិតនីមួយៗ។ មណ្ឌលសុខភាពដែលផ្តល់នូវកញ្ចប់សកម្មភាពអប្បបរមាមួយ ត្រូវបានរំពឹងថាបម្រើដល់ប្រជាជនចំនួនប្រហែល ១០.០០០នាក់ និងស្ថិតនៅក្នុងចម្ងាយប្រមាណ ១០គីឡូម៉ែត្រ ឬចម្ងាយដើរប្រហែល ២ម៉ោងពីក្រុមប្រជាជនដែលមណ្ឌលសុខភាពនេះបម្រើ។ កញ្ចប់សកម្មភាពអប្បបរមា ផ្តោតភាគច្រើនលើសកម្មភាពបង្ការជម្ងឺប្រកបដោយប្រសិទ្ធភាពចំណាយ និងសេវាសុខភាពមាតានិងកុមារ។ ផ្ទុយទៅវិញ មន្ទីរពេទ្យបង្អែកផ្តល់កញ្ចប់សេវាបំពេញបន្ថែម ក្នុងកម្រិតសេវាកម្មចំនួន ៣កម្រិត (កញ្ចប់សកម្មភាពបំពេញបន្ថែម ១ ២ និង ៣) និងត្រូវបានរំពឹងថាបម្រើដល់ប្រជាជនចំនួន ១០០.០០០-២០០.០០០ នាក់ ហើយស្ថិតនៅក្នុងចម្ងាយប្រមាណ ២០-៣០គីឡូម៉ែត្រ ពីក្រុមប្រជាជនដែលខ្លួនបម្រើ ឬចម្ងាយធ្វើដំណើរតាមរថយន្តឬទូកយ៉ាងយូរបំផុត ៣ម៉ោង។ សេវាកម្មនៃកញ្ចប់សកម្មភាពបំពេញបន្ថែមកម្រិតខ្ពស់ជាងនេះត្រូវបានផ្តល់នៅថ្នាក់ខេត្ត

នៅក្នុងខេត្តទាំង ២៤ និងនៅកម្រិតតំបន់ នៅតាមមណ្ឌលតំបន់ចំនួន៨។ លើសពីនេះទៀត មន្ទីរពេទ្យជាតិផ្តល់សេវាលំដាប់ទី២ និងទី៣ ហើយដែលមន្ទីរពេទ្យខ្លះមានផ្តល់ផងដែរនូវការបណ្តុះបណ្តាលព្យាបាលរោគរួមទាំងការបណ្តុះបណ្តាលឯកទេសពេទ្យ។ មន្ទីរពេទ្យជាតិមានការរីកលូតលាស់លឿនជាងគេក្នុងចំណោមសកម្មភាពមន្ទីរពេទ្យសាធារណៈទាំងអស់ ដោយកើនឡើងពី ២៩% នៃអ្នកជម្ងឺចេញពីមន្ទីរពេទ្យក្នុងឆ្នាំ២០០២ ដល់ ៤៤% ក្នុងឆ្នាំ២០០៦ (ធនាគារពិភពលោក ឆ្នាំ២០០៨)។

ក្រសួងបានអនុវត្តចំណាត់ការចុះកិច្ចសន្យាចូល និងចេញ (contracting-in & contracting-out) មួយចំនួននៅតាមស្រុកប្រតិបត្តិការ និងមណ្ឌលសុខភាព។ នៅក្នុងចំណាត់ការទាំងនេះ អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានផ្តល់ឆន្ទានុសិទ្ធិលើថវិកា បុគ្គលិក និងទិដ្ឋភាពបច្ចេកទេសក្នុងការគ្រប់គ្រងប្រចាំថ្ងៃ។ មេរៀនដែលបានទទួលពីចំណាត់ការចុះកិច្ចសន្យាជាមួយអង្គការមិនមែនរដ្ឋាភិបាលនេះ បាននាំឱ្យមាននូវគំនិតច្នៃប្រឌិតថ្មីមួយទៀតនៅក្នុងវិស័យនេះ ពោលគឺផែនការបង្កើត "ទីភ្នាក់ងារប្រតិបត្តិការពិសេស"។ អនុលោមតាមច្បាប់ថ្មី ទីភ្នាក់ងារប្រតិបត្តិការពិសេស មានស្វ័យភាពច្រើនក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនហើយខណៈដែលប្រាក់ខែបុគ្គលិកត្រូវផ្អែកលើកម្រិតកំណត់របស់រាជរដ្ឋាភិបាល ក៏ប្រាក់ខែពួកគេអាចត្រូវបានបំពេញបន្ថែមដោយប្រាក់ចំណូលផ្សេងទៀត ដែលមួយផ្នែកបានមកពីថ្លៃមើលជម្ងឺ និងមូលនិធិជំនួយ។ ទីភ្នាក់ងារប្រតិបត្តិការពិសេសនៅក្នុងវិស័យសុខាភិបាល ក៏នឹងត្រូវបានអនុញ្ញាតផងដែរឱ្យកំណត់ថ្លៃសេវារបស់ខ្លួន ដោយគោរពតាមគោលការណ៍ណែនាំ និងការតាមដានរបស់ក្រសួងសុខាភិបាល ហើយប្រាក់ចំណូលពីការផ្តល់សេវាអាចបែងចែកទៅលើចំណាយប្រតិបត្តិការ និងប្រាក់ខែ។ យ៉ាងណាក្តី គេមិនដឹងច្បាស់ទេថាតើទីភ្នាក់ងារប្រតិបត្តិការពិសេសនេះនឹងត្រូវបានដាក់ឱ្យអនុវត្តបានលឿនប៉ុណ្ណា ទោះបីជាមានផែនការអនុវត្តក្នុងស្រុកប្រតិបត្តិការចំនួន ១១ ក្នុងឆ្នាំ២០០៩ ក្តី។

បន្ថែមលើសេវាសុខភាពធម្មតារបស់ខ្លួន ក្រសួងក៏មានកម្មវិធីមួយចំនួនសម្រាប់គោលបំណងពិសេសៗផងដែរ ដូចជាការបង្ការនិងព្យាបាលជម្ងឺគ្រុនឈាម ជម្ងឺគ្រុនចាញ់ និងមេរោគអេដស៍ឬជម្ងឺអេដស៍។ កម្មវិធីទាំងនេះភាគច្រើនទទួលមូលនិធិពីម្ចាស់ជំនួយ និងដំណើរការក្នុងលក្ខណៈឯករាជ្យ ដោយមានគោលការណ៍ណែនាំសម្រាប់ការផ្តល់សេវា និងនីតិវិធីសម្រាប់ការធ្វើផែនការ ធ្វើហិរញ្ញប្បទាន ផ្តល់គ្រឿងលើកទឹកចិត្តដល់បុគ្គលិក តាមដាននិងត្រួតពិនិត្យរបស់ម្ចាស់ជំនួយផ្ទាល់។ ភាគច្រើននៃកម្មវិធីទាំងនេះសហការដោយផ្ទាល់ជាមួយស្រុកប្រតិបត្តិការ និងមណ្ឌលសុខភាព ប៉ុន្តែរបៀបប្រតិបត្តិការផ្សេងគ្នានៃកម្មវិធីទាំងនេះធ្វើឱ្យមានការលំបាកដល់ស្រុកប្រតិបត្តិការ និងមណ្ឌលសុខភាពក្នុងការសម្របសម្រួលសកម្មភាព និងដាក់បញ្ចូលសកម្មភាពទាំងនេះទៅក្នុងការធ្វើកម្មវិធីជាប្រចាំ។ រដ្ឋបាលបែបមជ្ឈការលើកម្មវិធីទាំងនេះក៏ធ្វើឱ្យខូចខាតផងដែរដល់គណនេយ្យភាពក្នុងមូលដ្ឋាន។

## ៥.៥. វិភាជន៍ និងលំហូរមូលនិធិ

ការផ្តល់មូលនិធិពីប្រភពផ្សេងៗគ្នា (ដូចដែលត្រូវបានពិភាក្សានៅក្នុងផ្នែកហិរញ្ញប្បទាន) ហូរតាមរយៈរចនាសម្ព័ន្ធស្ថាប័នដែលបានរៀបរាប់ ហើយហិរញ្ញប្បទានពីប្រភពទាំងអស់ (រាជរដ្ឋាភិបាល ថ្លៃសេវា ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល) ត្រូវបានវិភាជនិងចាយលើចំណាយគ្រប់ប្រភេទ (ឧទាហរណ៍ ប្រាក់ខែ ប្រតិបត្តិការ)។ ដូចរូបទី៥ បានបង្ហាញ ការគាំទ្រភាគច្រើន ដែលមានចំនួនជាង ៤០% ត្រូវបានផ្តល់ទៅឱ្យក្រសួងសុខាភិបាល និងកម្មវិធីថ្នាក់ជាតិ ក្នុងឆ្នាំ២០០៤ ហើយ រូបទី៦ ក៏បង្ហាញផងដែរថាម្ចាស់ជំនួយបាននឹងកំពុងផ្តោតការជួយគាំទ្ររបស់ខ្លួនយ៉ាងច្រើនលើកម្មវិធីជាតិទាំងនោះដែរ។

***រូបទី៥៖*** វិភាជន៍មូលនិធិសម្រាប់ឆ្នាំ២០០៤




ប្រភព៖ អង្កេតតាមដានចំណាយសាធារណៈ*(PETS)* ឆ្នាំ២០០៤

***រូបទី៦៖*** ភាគរយប្រភពផ្ដល់មូលនិធិ និងការប្រើប្រាស់




ប្រភព៖ ផែនការប្រតិបត្តិការប្រចាំឆ្នាំ ២០០៧

ឌីយ៉ាក្រាមមួយទៀតខាងក្រោមបង្ហាញនូវលំហូរមូលនិធិពីថ្នាក់ជាតិទៅថ្នាក់មន្ទីរពេទ្យ។ ជារួមដូចបានបង្ហាញជូន ប្រភពហិរញ្ញប្បទានអាចមកពីថវិកាជាតិផង និងម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលផង ហើយអាចហូរទៅកាន់កម្រិតផ្សេងៗនៃប្រតិបត្តិការរបស់ក្រសួងសុខាភិបាល រួមទាំងអង្គការមិនមែនរដ្ឋាភិបាលជាប់កិច្ចសន្យា ដែលធ្វើការលើមូលនិធិសមធម៌សុខភាព និងទម្រង់ផ្សេងទៀតនៃការធានារ៉ាប់រងសុខាភិបាល។ ចំណុចមួយដែលគប្បីលើកឡើងគឺថាឱសថ និងបរិក្ខារពេទ្យជាច្រើនផ្សេងទៀតត្រូវបានធ្វើលទ្ធកម្មបែបមជ្ឈការដោយក្រសួងសុខាភិបាល និងទុកដាក់នៅក្នុងឃ្លាំងបរិក្ខារពេទ្យកណ្ដាល។ ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល ក៏ចូលរួមផ្គត់ផ្គង់ផងដែរនូវបរិក្ខារទាំងនេះដល់ក្រសួងសុខាភិបាល ដែលត្រូវរក្សាទុកនៅឃ្លាំងបរិក្ខារពេទ្យកណ្ដាល ហើយឃ្លាំងបរិក្ខារពេទ្យកណ្ដាលចែកចាយឱសថ និងបរិក្ខារពេទ្យជូនដល់កម្រិតផ្សេងៗនៃប្រតិបត្តិការសុខាភិបាល។

កំណត់សម្គាល់សំខាន់មួយទៀតគឺថា ថវិកាជាតិភាគច្រើនបំផុតត្រូវបានប្រើប្រាស់ដើម្បីធ្វើហិរញ្ញប្បទានលើចំណាយចរន្ត ជាជាងលើចំណាយមូលធន។ ផ្ទុយទៅវិញ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ដោយសារការជួយគាំទ្រដ៏ច្រើនរបស់ពួកគេ បានរួមវិភាគទានជាច្រើនដល់ទាំងចំណាយចរន្ត (ឧទាហរណ៍ ឱសថ និងបរិក្ខារពេទ្យ) និងចំណាយមូលធន (ឧទាហរណ៍ សាងសង់មន្ទីរពេទ្យ)។ យ៉ាងណាក្ដីក៏ការសិក្សានេះមិនអាចរកបានព័ត៌មានថាតើចំណាយចរន្តប៉ុន្មាន និងចំណាយមូលធនប៉ុន្មាន ត្រូវបានធ្វើហិរញ្ញប្បទានដោយម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល។ សូមមើលផ្នែកទី៦ សម្រាប់ការអធិប្បាយបន្ថែមទៀតអំពីរបៀបដែលព័ត៌មានស្ដីពីថវិកា ទាំងថវិកាជាតិនិងថវិការបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលត្រូវបានចងក្រងជាឯកសារ និងរបៀបដែលឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយ។

***រូបទី៧៖*** លំហូរនៃមូលនិធិ និងការជួយគាំទ្រ




** ចំណាយមូលធនត្រូវបានចាត់ទុកថាជាចំណាយមិនទាន់បែងចែក ដោយស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ។ វិស័យសុខាភិបាលដូចជាវិស័យផ្សេងទៀតជាច្រើនដែរ ត្រូវលើកសំណើរគម្រោង និងទទួលបានការយល់ព្រមពីនាយករដ្ឋមន្ត្រីដោយផ្ទាល់តាមរយៈនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ដើម្បីអាចចាយថវិកាមូលធន។

ប្រភព៖ បទសម្ភាសន៍ និងការសិក្សាឯកសារ

## ៦. ព័ត៌មានស្ដីពីថវិកា និងការមានព័ត៌មាននេះនៅកម្រិតផ្សេងៗ

នៅក្នុងជំពូកនេះ របាយការណ៍នេះចាប់ផ្ដើមពីថ្នាក់ជាតិរហូតដល់ថ្នាក់មណ្ឌលសុខភាពឬសហគមន៍ ដោយកំណត់ថាតើឯកសារនិងព័ត៌មានអ្វីខ្លះស្ដីពីថវិកាត្រូវបានផលិត ហើយអាចរកបានដែរឬទេ។ ព័ត៌មានស្ដីពីថវិកានេះត្រូវបានចែកចេញជាថវិកាជាតិ និងហិរញ្ញប្បទានរបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល។ សម្រាប់ឯកសារស្ដីពីថវិកានីមួយៗដែលបានផលិត នឹងមានការកំណត់ថាតើឯកសារនេះត្រូវបានផលិត៖

- យ៉ាងទៀងទាត់ឬទេ? បើទៀងទាត់ តើញឹកញាប់ប៉ុណ្ណា?
- សម្រាប់តែគោលបំណងប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ ពោលគឺមិនមែនផ្សព្វផ្សាយជាសាធារណៈ?
- សម្រាប់ផ្សព្វផ្សាយជាសាធារណៈ តែក្នុងករណីមានសំណើផ្លូវការប៉ុណ្ណោះ? និង
- សម្រាប់ផ្សព្វផ្សាយជាសាធារណៈ ដោយមិនចាំបាច់ត្រូវការសំណើផ្លូវការ?

បើអាចធ្វើបាន ការពិភាក្សានេះនឹងបង្ហាញឲ្យបានច្បាស់ថា តើប្រភេទព័ត៌មានជាក់លាក់ណាអាចផ្សព្វផ្សាយបាន៖

- ជូនសាធារណជនទូទៅ
- យ៉ាងទៀងទាត់ជូនសមាជិកនៃក្រុមការងារបច្ចេកទេសនៅថ្នាក់ជាតិឬថ្នាក់ក្រោមជាតិ ប្រសិនបើរាជរដ្ឋាភិបាលបញ្ជាក់ថាព័ត៌មាននេះអាចផ្សព្វផ្សាយបានជាសាធារណៈបាន និង
- យ៉ាងទៀងទាត់ជូនសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងបរិក្ខាររូបវន្ត និងក្រុមប្រឹក្សាមូលដ្ឋានផ្សេងទៀត ប្រសិនបើរាជរដ្ឋាភិបាលបញ្ជាក់ថាព័ត៌មាននេះអាចផ្សព្វផ្សាយបានជាសាធារណៈបាន

## ៦.១. នៅថ្នាក់ជាតិ

ស្តីពីថវិកាជាតិ (ជាចម្បង)

មានស្ថាប័នផ្សេងៗដែលផលិត និងផ្សព្វផ្សាយឯកសារស្តីពីថវិកាជាតិជារួម និងដោយឡែកសម្រាប់វិស័យសុខាភិបាល។ រដ្ឋសភាអនុម័ត និងផ្សព្វផ្សាយ**ច្បាប់ថវិកាជាតិ**។ ចាប់តាំងពីឆ្នាំ២០០៧ មក ច្បាប់នេះបានដាក់បញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធនដែលត្រូវបានឧបត្ថម្ភមូលនិធិដោយម្ចាស់ជំនួយ និងដែលត្រូវបានចែកតាមវិស័យឬក្រសួង។ ថវិកាចរន្ត បង្ហាញបរិមាណវិភាជន៍តាមស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ (និងវិភាជន៍សម្រាប់ថ្នាក់ជាតិ និងថ្នាក់ខេត្ត) ហើយផ្នែកថវិកាមូលធនបង្ហាញនូវបញ្ជីមួយ នៃគម្រោងនានារបស់ស្ថាប័នរាជរដ្ឋាភិបាលនីមួយៗ។ ជារៀងរាល់ឆ្នាំ ក្នុងរវាងខែមីនា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ចេញផងដែរនូវឯកសារគ្រប់គ្រងថវិកាជាតិមួយឈុត ដែលមានចំនួនបួនក្បាល ដែលផ្តល់ព័ត៌មានលម្អិតអំពីរបៀបដែលថវិកាត្រូវបានវិភាជតាមវិស័យ និងតាមខេត្ត[2]។ សម្រាប់វិស័យសុខាភិបាល គេអាចរកបាននូវព័ត៌មានដូចខាងក្រោម៖

- សៀវភៅទី១៖ ថវិកាជាតិ ដែលដាក់បញ្ចូលទាំងតួលេខថវិកាជាតិ ដូចដែលត្រូវបានអនុម័តដោយរដ្ឋសភា និងការវិភាគសាវតារលើស្ថានភាពសេដ្ឋកិច្ច ការព្យាករណ៍ របៀបវារៈកំណែទម្រង់ផ្សេងៗសម្រាប់ឆ្នាំ និងលិខិតបទដ្ឋានគតិយុត្តិឯទៀតៗដែលត្រូវបានចេញផ្សាយនៅក្នុងឆ្នាំ ទាក់ទិននឹងបញ្ហាគ្រប់គ្រងថវិកា។
- សៀវភៅទី២៖ ការវិភាជថវិកាសម្រាប់ក្រសួងកណ្តាល ដែលលម្អិតព័ត៌មាននៃការវិភាជនេះតាមកម្រិតថ្នាក់កណ្តាល និងថ្នាក់ខេត្ត និងសម្រាប់ខេត្តនីមួយៗ ប៉ុន្តែឯកសារនេះបញ្ចូលតែចំណាយចរន្តសម្រាប់ឆ្នាំប៉ុណ្ណោះ។
- សៀវភៅទី៣៖ ការវិភាជថវិកាតាមខេត្ត ដែលលម្អិតព័ត៌មានអំពីការវិភាជតាមមន្ទីរពាក់ព័ន្ធ ហើយដូចគ្នាដែរ ឯកសារនេះបញ្ចូលតែចំណាយចរន្តប៉ុណ្ណោះ។
- សៀវភៅទី៤៖ ការវិភាជថវិកាទៅឱ្យអាជ្ញាធរខេត្ត ដែលជាធម្មតាគេហៅថាសាលាខេត្ត ដែលលម្អិតព័ត៌មានតាមខេត្ត។ គេគប្បីកត់សម្គាល់ថាមូលនិធិនេះ (ពោលគឺសម្រាប់សាលាខេត្ត) គឺបញ្ចូលទាំងចំណាយចរន្ត និងមួយចំណែកតូចនៃចំណាយមូលធន។

ឯកសារដែលបានលើកឡើងខាងលើនេះ អាចត្រូវបានប្រើរួមជាមួយកម្មវិធីវិនិយោគសាធារណៈដែលជាផែនការវិនិយោគបីឆ្នាំរំកិលរ សម្រាប់ឱ្យគ្រប់វិស័យទាំងអស់ទទួលបាននូវទិដ្ឋភាពទាំងមូលអំពីថវិកា

[2] ការជួបប្រជុំជាមួយមន្ត្រីនៃនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩។

ចរន្ត និងថវិកាមូលធនសម្រាប់វិស័យ។ កម្មវិធីវិនិយោគសាធារណៈត្រូវបានបោះផ្សាយដោយ (និងអាចរកបានពី) ក្រសួងផែនការ ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មរៀងរាល់ឆ្នាំ និងបោះផ្សាយនៅដើមឆ្នាំ។ នៅក្នុងកម្មវិធីវិនិយោគសាធារណៈនេះ វិស័យសុខាភិបាលត្រូវបានចាត់ថ្នាក់នៅក្នុងវិស័យសង្គមកិច្ច ជាមួយគ្នានឹងវិស័យអប់រំ។ ឯកសារនេះក៏បង្ហាញផងដែរនូវបញ្ជីនៃគម្រោងនានាដែលត្រូវបានបែងចែកជា គម្រោងអាទិភាពកំពុងដំណើរការ និងបម្រុង។ នៅក្នុងប្រភេទគម្រោងទាំងពីរនេះ មានការធ្វើចំណាត់ថ្នាក់បន្ថែមទៀតទៅតាមគម្រោងវិនិយោគមូលធន និងគម្រោងជំនួយបច្ចេកទេស។ គេគប្បីគួរកត់សម្គាល់ផងដែរ ថាគម្រោងនានានៃកម្មវិធីវិនិយោគសាធារណៈ ត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែកមូលធន (តារាង គ និង ឃ) នៃច្បាប់ថវិកាជាតិ។

ទាក់ទងនឹងការអនុវត្តថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានព័ត៌មានពីរតនាគារជាតិ ចេញរបាយការណ៍ប្រចាំខែមួយស្ដីពីការអនុវត្តថវិការដ្ឋ ដែលគេស្គាល់ថាជា តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ[3] ហើយតារាងនេះអាចទិញបានពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ឯកសារនេះគឺជា ឯកសារយោងដ៏ល្អមួយអំពីការអនុវត្តប្រចាំខែនូវថវិកាជាតិ និងការជួយគាំទ្ររបស់ម្ចាស់ជំនួយ។

ប្រភពព័ត៌មានពីរផ្សេងទៀតស្ដីពីហិរញ្ញប្បទានវិស័យសុខាភិបាលគប្បីត្រូវបានលើកឡើងនៅទីនេះ។ សម្រាប់ការជួយគាំទ្ររបស់ម្ចាស់ជំនួយ មូលដ្ឋានទិន្នន័យស្ដីពីជំនួយអភិវឌ្ឍន៍អន្តរជាតិរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគឺជាប្រភពទិន្នន័យល្អមួយ ថ្វីបើមិនល្អបំផុតក្ដី។ ដោយត្រូវបានធ្វើបច្ចុប្បន្នកម្មយ៉ាងទៀងទាត់ និងផ្សព្វផ្សាយជាសាធារណៈមូលដ្ឋានទិន្នន័យនេះផ្ដល់ព័ត៌មានអំពីការបញ្ចេញមូលនិធិប្រចាំឆ្នាំពីម្ចាស់ជំនួយផ្សេងៗ ប៉ុន្តែមូលដ្ឋានទិន្នន័យនេះមានលក្ខណៈពិបាកប្រើ។ លើសពីនេះទៀត មានតែព័ត៌មានស្ដីពីការបញ្ចេញសាច់ប្រាក់ដោយម្ចាស់ជំនួយទៅក្នុងគម្រោងឬកម្មវិធីប៉ុណ្ណោះទេដែលអាចរកបាន រីឯព័ត៌មានអំពីមូលនិធិដែលត្រូវបានបញ្ចេញចេញពីគម្រោងឬកម្មវិធីនីមួយៗវិញគឺមិនមានទេ។[4] មូលដ្ឋានទិន្នន័យស្ដីពីជំនួយអភិវឌ្ឍន៍អន្តរជាតិរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចចូលមើលបាននៅលើគេហទំព័រ: http://cdc.khmer.biz/។

ថ្វីបើមានជាសាធារណៈបង្គួរ ឯកសារថវិកាដែលបានលើកឡើងខាងលើភាគច្រើនផ្ដល់តែទិន្នន័យសរុបដែលសម្រាប់គោលបំណងតាមដាន និងវិភាគវិភាជន៍និងការអនុវត្តថវិកានៅក្នុងវិស័យជាក់លាក់មួយដូចជាវិស័យសុខាភិបាលជាដើមគឺទាមទារចាំបាច់ឲ្យមានទិន្នន័យលម្អិត។ ព័ត៌មានសរុបមិនអនុញ្ញាតឲ្យអ្នកវិភាគផ្សារភ្ជាប់អ្វីដែលត្រូវបានចាយ ទៅនឹងអ្វីដែលសម្រេចបានជាមួយចំណាយទាំងនេះឡើយ ហើយវាក៏មិនអនុញ្ញាតឱ្យមានការវិភាគលម្អិតបន្ថែមទៀតដែរលើ ចំណុចដូចជា អតុល្យភាពភូមិសាស្ត្រនៅក្នុងរបៀបដែលថវិកាត្រូវបានវិភាជ។

ព័ត៌មានសរុបបន្ថែមស្ដីពីថវិកាត្រូវបានផលិតដោយក្រសួងសុខាភិបាល។ ព័ត៌មានដែលពេញលេញ និងមានប្រយោជន៍ជាងគេគឺ ផែនការប្រតិបត្តិការប្រចាំឆ្នាំឬផែនការបីឆ្នាំរំកិល ដែលគឺជាឯកសារដែលទាមទារឲ្យរៀបចំដោយស្ថាប័នសុខភាពនៅគ្រប់កម្រិតទាំងអស់។ ឯកសារនេះបង្ហាញពីអ្វីដែលគឺជាតម្រូវការស្នើសុំដោយគ្រប់ស្ថាប័នសុខភាពទាំងអស់ (ពីក្រោមឡើងលើ) និងថាតើមានធនធានប៉ុន្មានត្រូវបានផ្ដល់ដើម្បីបំពេញសេចក្ដីត្រូវការទាំងនេះ (ពីលើចុះក្រោម)។ យោងតាមប្រតិទិនវិស័យសុខាភិបាល ផែនការប្រតិបត្តិការប្រចាំឆ្នាំនៅតាមស្ថាប័ននីមួយៗត្រូវបានរៀបចំនៅដើមខែមីនា ហើយសេចក្ដីព្រាងផែនការ

---

[3] តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ។

[4] Lienert, I. J. Helis និង អ្នកដទៃ (២០០៨)។ កម្ពុជា៖ កែលម្អគណនេយ្យរបស់រាជរដ្ឋាភិបាល។ ភ្នំពេញ, មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

ប្រតិបត្តិការប្រចាំឆ្នាំក្នុងទូទាំងវិស័យត្រូវបានបញ្ចប់ក្នុងខែធ្នូ។ ការបូកសរុបលើកទីមួយនៃផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងស្រុកប្រតិបត្តិការ ត្រូវបានធ្វើឡើងនៅថ្នាក់ខេត្ត ហើយនៅពេលត្រូវបានបញ្ជូនទៅឱ្យថ្នាក់ជាតិ នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាលនឹងបញ្ចូលគ្នាបន្ថែមនូវផែនការថ្នាក់ខេត្ត និងកម្មវិធីថ្នាក់ជាតិឬនាយកដ្ឋាន។ នៅក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំ គេអាចឃើញនូវឧបសម្ព័ន្ធពោរពេញដោយព័ត៌មាន ដែលរួមមានតារាងផ្សេងៗដូចជា ចំណាយតាមកម្មវិធីមណ្ឌលគ្រប់គ្រងថវិកា លេខកូដថវិកា និងកម្មវិធីរង ប្រភពផ្តល់មូលនិធិ និងចំណាត់ថ្នាក់សកម្មភាព។

ផែនការប្រតិបត្តិការប្រចាំឆ្នាំ ត្រូវបានរៀបចំរួមគ្នារវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងដៃគូវិស័យសុខាភិបាលផ្សេងទៀត ហើយក៏ត្រូវបានវាយតម្លៃរួមគ្នាផងដែរ ដោយភាគីពាក់ព័ន្ធទាំងនេះ។ ជារៀងរាល់ឆ្នាំក្នុងរវាងខែមីនា មានមហាសន្និបាតសុខាភិបាលថ្នាក់ជាតិមួយ ដែលប្រព្រឹត្តទៅទន្ទឹមគ្នានឹងការវាយតម្លៃរួមលើស្នាដៃអនុវត្តប្រចាំឆ្នាំ និងការវាយតម្លៃរួមគ្នាលើផែនការបីឆ្នាំរំកិល។ របាយការណ៍ទាំងនេះលើកឡើងពីសមិទ្ធផល និងបរាជ័យនៃឆ្នាំកន្លងទៅ ដោយផ្តោតលើវិស័យគន្លឹះមួយចំនួនដូចជា ស្ថានភាពផ្តល់សេវាសុខភាព ការផ្លាស់ប្តូរឥរិយាបថនិងការប្រាស្រ័យទាក់ទង ការកែលម្អគុណភាព ការអភិវឌ្ឍន៍ធនធានមនុស្ស ហិរញ្ញប្បទានសុខាភិបាល និងការអភិវឌ្ឍស្ថាប័ន។ យ៉ាងណាក្តី ទម្រង់នៃរបាយការណ៍ពីមួយឆ្នាំទៅមួយឆ្នាំអាចប្រែប្រួលបន្តិចបន្តួច[5]។

គេគប្បីកត់សម្គាល់ជាថ្មីថាផែនការប្រតិបត្តិការប្រចាំឆ្នាំ បង្ហាញប្រភពមូលនិធិពីថវិកាជាតិផង និងការជួយគាំទ្ររបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលផង។ ចំពោះចំណែកថវិកាជាតិ ការទទួលខុសត្រូវលើការរៀបចំគឺស្ថិតនៅក្រោមនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល ហើយមានជំហានមួយចំនួនដែលការងារនេះត្រូវបានអនុវត្ត។ ទីមួយ នាយកដ្ឋាននេះរៀបចំផែនការថវិកាសម្រាប់ឆ្នាំនីមួយៗ ជាផ្នែកមួយនៃផែនការប្រតិបត្តិការប្រចាំឆ្នាំ ហើយផ្នែកខ្លះនៃផែនការថវិកានេះធ្វើតាមទម្រង់នៃផែនការប្រតិបត្តិការប្រចាំឆ្នាំ លើកលែងតែថាសម្រាប់របាយការណ៍នេះ ការផ្តោតគឺទៅលើតែថវិកាជាតិប៉ុណ្ណោះ។ បន្ថែមលើនេះផែនការនេះក៏បង្ហាញផងដែរនូវថវិកាវិស័យគោរពទៅតាមប្លង់គណនេយ្យ ដែលមានន័យថាចែកតាម ប្រាក់បៀវត្សរ៍ (ជំពូក៦៤) ទំនិញ និងសេវា (ជំពូក ៦០ ៦១ ៦២ និង ៦៣)។ ដោយសារវិស័យសុខាភិបាលក៏បានអនុម័តការធ្វើថវិកាតាមកម្មវិធីផងដែរនោះ ផែនការនេះបែងចែករវាងការធ្វើថវិកាតាមកម្មវិធី និងការធ្វើថវិកាមិនមែនតាមកម្មវិធី។ ផែនការថវិកានេះ ដែលត្រូវបានរៀបចំស្របតាមប្លង់គណនេយ្យ ត្រូវដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើការចរចារ និងអនុម័ត ដោយគោរពតាមប្រតិទិនរៀបចំថវិកាជាតិ។

នាយកដ្ឋានហិរញ្ញវត្ថុ ក៏រក្សាទុកផងដែរនូវឯកសារអនុវត្តថវិកាប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ (ដែលនៅពេលនេះសូមហៅថាថវិកាជាតិ)។ ប្រៀបធៀបនឹងផែនការថវិកាដែលបានអនុម័ត ឯកសារនេះបង្ហាញពីការអនុវត្តតាមខ្ទង់ថវិកា រវាងការធ្វើថវិកាតាមកម្មវិធី និងការធ្វើថវិកាមិនមែនតាមកម្មវិធី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យោងតាមបទសម្ភាសន៍ជាមួយនាយកដ្ឋានហិរញ្ញវត្ថុ និងនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ ព័ត៌មាននេះត្រូវបានចែកជូនជារៀងរាល់ត្រីមាសដល់ក្រុមការងារបច្ចេកទេសរួម និងវេទិកា

---

[5] ក្រៅពីរបាយការណ៍ប្រចាំឆ្នាំទាំងនេះ អាចមានរបាយការណ៍វាយតម្លៃពិសេសផងដែរដូចជារបាយការណ៍ស្តីពីការពិនិត្យវាយតម្លៃការជួលសេវាសុខភាពកម្ពុជា (ខែកុម្ភៈ ឆ្នាំ២០០៧) ការគ្រប់គ្រងទូទាំងវិស័យ (SWiM) (ខែមីនា ឆ្នាំ២០០៧) ការពិនិត្យវាយតម្លៃវិស័យសុខាភិបាល ឆ្នាំ២០០៣-២០០៧ (ខែសីហា ឆ្នាំ២០០៧) ។ល។ តាមការរំពឹងទុក ដោយសារវិស័យសុខាភិបាលពឹងអាស្រ័យច្រើនលើជំនួយ ការវាយតម្លៃផ្សេងៗត្រូវបានធ្វើដើម្បីជាផលប្រយោជន៍របស់ម្ចាស់ជំនួយទាំងនោះ។

ម្ចាស់ជំនួយ-រាជរដ្ឋាភិបាលផ្សេងទៀត ដូចជាវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) ជាដើម។ ការរាយការណ៍អំពីការអនុវត្តថវិកាជាតិ គឺជាការសន្យារបស់ក្រសួងសុខាភិបាលចំពោះដៃគូរបស់ខ្លួន ដើម្បីបង្ហាញថារៀងរាល់ឆ្នាំ វិស័យនេះអនុវត្តយ៉ាងហោចណាស់ក៏បាន ៩៥% នៃថវិកាជាតិដែលបានអនុម័តដែរ។ មន្ត្រីក្រសួងសុខាភិបាលបានឲ្យដឹងថា ដោយសារតែតំណាងអង្គការមិនមែនរដ្ឋាភិបាលមួយ (អង្គការម៉េឌីខាំ) ក៏ចូលរួមក្នុងកិច្ចប្រជុំនេះដែរ អង្គការមិនមែនរដ្ឋាភិបាលគប្បីទទួលបានព័ត៌មានយ៉ាងទៀតទាត់អំពីស្ថានភាពនៃការអនុវត្តថវិកាជាតិរបស់ក្រសួងសុខាភិបាល។

ប្រភពព័ត៌មានដ៏សំខាន់មួយទៀតគឺ ឃ្លាំងបរិក្ខារពេទ្យកណ្តាល។ ឃ្លាំងបរិក្ខារពេទ្យកណ្តាលធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្តីពីការផ្ទេរចេញចូលនៃឱសថនិងបរិក្ខារពេទ្យនានា។ សម្រាប់ការផ្ទេរចូល របាយការណ៍នេះបង្ហាញតម្លៃនៃការផ្ទេរចូលពីរាជរដ្ឋាភិបាល ធនាគារពិភពលោក និងម្ចាស់ជំនួយដទៃទៀត ហើយសម្រាប់ការផ្ទេរចេញវិញ ឯកសារនេះបង្ហាញថាតើស្រុកប្រតិបត្តិណាទទួលបានការផ្ទេរចូលប៉ុន្មាន។ បទសម្ភាសន៍ ជាមួយមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ និងមន្ត្រីនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការបង្ហាញថា ព័ត៌មានខាងលើជាធម្មតាត្រូវបានបង្ហាញជូនក្រុមការងារបច្ចេកទេសរួមរៀងរាល់ត្រីមាស តាមការសន្យារបស់ក្រសួងសុខាភិបាលចំពោះដៃគូវិស័យសុខាភិបាលរបស់ខ្លួន។

ចំណាយមូលធននៅក្នុងវិស័យសុខាភិបាលមាន២ផ្នែកគឺៈ មួយផ្នែកទទួលហិរញ្ញប្បទានក្នុងស្រុក និងមួយផ្នែកទៀតទទួលជំនួយពីបរទេស។ នៅក្នុងប្រព័ន្ធបច្ចុប្បន្ន ចំណាយមូលធនទាំងមូល ដែលត្រូវបានបំបែកចេញជាគម្រោងឬកម្មវិធីអភិវឌ្ឍន៍រាប់រយ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថ្វីបើនាយកដ្ឋាននេះមិនបានផលិតឯកសារសាធារណៈស្តីពីគម្រោងឬការអនុវត្តថវិកា ក៏នាយកដ្ឋាននេះមានផ្តល់ព័ត៌មានសម្រាប់ដាក់បញ្ចូលក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ[6]ដែរ។ ហិរញ្ញប្បទានក្នុងស្រុកទាំងអស់ និងផ្នែកខ្លះនៃចំណាយមូលធនដែលបានទទួលមូលនិធិពីបរទេសត្រូវបានចាយ(បញ្ចេញ) តាមរយៈប្រព័ន្ធរតនាគារជាតិ ដូច្នេះការអនុវត្តចំណាយទាំងនេះត្រូវបានកត់ត្រាទុកដោយរតនាគារជាតិ និងបញ្ជូនទៅឱ្យនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការរៀបចំតារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋប្រចាំខែ។ សម្រាប់មូលនិធិបរទេសដែលមិនបានផ្តល់តាមប្រព័ន្ធរតនាគារជាតិ ព័ត៌មានស្តីពីការអនុវត្តមូលនិធិទាំងនេះអាចរកបានពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ យ៉ាងណាក្តី ដូចដែលបានពិភាក្សាខាងលើ ឯកសារស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយ (ដែលមួយចំនួនត្រូវបាន ធ្វើឡើងតាមរយៈអង្គការមិនមែនរដ្ឋាភិបាល) នៅមិនទាន់មានលក្ខណៈពេញលេញនៅឡើយ ទាំងនៅក្នុងករណីនៃមូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងមូលដ្ឋានទិន្នន័យដែលទើបបានបង្កើតឡើងថ្មីៗរបស់នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៃក្រសួងសុខាភិបាល[7]។

ព័ត៌មានដែលមាននៅក្នុងមូលដ្ឋានទិន្នន័យខាងលើ និងឯកសារនិងរបាយការណ៍ថវិកាមួយចំនួនគឺមានលក្ខណៈសម្បូរណ៍បែបណាស់។ តាមពិតទៅឯកសារទាំងនោះគឺតម្រូវសម្រាប់ការវាយតម្លៃឬតាមដានផ្ទៃក្នុងវិស័យផង និងសម្រាប់សកម្មភាពសវនកម្មនានាដែលជាធម្មតាត្រូវបានធ្វើដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នសវនកម្មផ្សេងទៀតផងដែរ។ យោងបទសម្ភាសន៍ជាមួយមន្ត្រីថ្នាក់ថ្នាក់ជាតិ ឯកសារនិងព័ត៌មានទាំងអស់នេះអាចផ្សព្វផ្សាយបានលុះត្រាតែមានការយល់ព្រមជាផ្លូវការពីថ្នាក់លើ ពោលគឺថ្នាក់

---

[6] ការជួបប្រជុំជាមួយមន្ត្រីនៃនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩។

[7] ផ្អែកលើបទសម្ភាសន៍ជាមួយមន្ត្រីរតនាគារជាតិ (ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៨)។

ក្រសួង ហើយចាំបាច់ត្រូវមានការដាក់ជូននូវលិខិតស្នើសុំតាមរយៈនីតិវិធីរដ្ឋបាល ដែលនីតិវិធីនេះអាចចំណាយពេលរាប់សប្តាហ៍មុនពេលគេដឹងថាតើសំណើត្រូវបានយល់ព្រមឬទេ។ បើមានការយល់ព្រមនេះ គេអាចទទួលបានទិន្នន័យយ៉ាងច្រើនតាមដែលគេអាច។ ហេតុដូច្នេះការស្នើសុំព័ត៌មានបែបនេះគឺជាស្ថានភាពមួយដែលមានលក្ខណៈ "បានទាំងអស់ ឬមិនបានសោះ"។

យ៉ាងណាក្តី គេបានដឹងថាភាគច្រើននៃព័ត៌មានខាងលើត្រូវបានផ្តល់ជូនក្រុមការងារបច្ចេកទេសរួម ដែល ជាការប្តេជ្ញាមួយរបស់ក្រសួងសុខាភិបាលចំពោះដៃគូវិស័យសុខាភិបាលរបស់ខ្លួន ហើយក៏មានការបញ្ជាក់ផងដែរថាព័ត៌មានភាគច្រើនដែលបានស្នើសុំនិងផ្តល់ជូនក្រុមការងារបច្ចេកទេសរួម អាចចែករំលែកបន្តជាមួយភាគីពាក់ព័ន្ធដទៃទៀតបាន។ ពេលសួរថាតើព័ត៌មានទាំងនេះអាចផ្សព្វផ្សាយជូន "សាធារណជន" បានឬទេ មន្ត្រីដែលត្រូវបានសម្ភាសន៍សួរត្រឡប់មកវិញថា តើចង់និយាយអំពីផ្នែកណាខ្លះនៃសាធារណជន។ ប្រការនេះមានន័យថានៅក្នុងស្ថានភាពបច្ចុប្បន្ន ពាក្យ "សាធារណជន" ក្នុងបរិបទនេះគប្បីគួរត្រូវកំណត់ឱ្យបានជាក់លាក់។

## ស្ថិតិសុខភាព

ព័ត៌មានកាន់តែលម្អិត ត្រូវបានរៀបចំដោយក្រសួងសុខាភិបាល ជាពិសេសនាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល នាយកដ្ឋានហិរញ្ញវត្ថុ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។ ទីមួយ នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល ផលិតនិងរក្សាទុកស្ថិតិសុខាភិបាលប្រចាំឆ្នាំ ដែលផ្អែកលើប្រព័ន្ធព័ត៌មានសុខាភិបាលផ្ញើមកពីថ្នាក់ខេត្ត ហើយដែលផ្តល់ព័ត៌មានផ្សេងៗជាច្រើន រួមទាំងទិន្នន័យប្រជាសាស្ត្រ ការប្រើប្រាស់សេវាសុខភាព ដោយគិតតាមសូចនាករសុខភាពខេត្ត។ល។ ស្ថិតិនេះគួរត្រូវចេញជារៀងរាល់ឆ្នាំ ប៉ុន្តែអាចយឺតយ៉ាវដោយសារមូលហេតុផ្សេងៗ ដែលរួមមានតាំងពីសមត្ថភាពរហូតដល់ការយឺតយ៉ាវក្នុងការផ្ទេរទិន្នន័យពីប្រភពផ្សេងៗ។ គេបានដឹងតាមរយៈបទសម្ភាសន៍ជាមួយមន្ត្រីក្រសួងសុខាភិបាល[8] ថាក្រសួងផែនការកំពុងបញ្ចប់ "ការកំណត់ជាមុននូវអត្តសញ្ញាណគ្រួសារក្រីក្រ" ដែលមានលក្ខណៈដូចជាជំរឿនមួយដែរ ហើយលទ្ធផលពីការងាររបស់ក្រសួងផែនការនេះនឹងត្រូវបានប្រើសម្រាប់ចែកចាយប័ណ្ណធានាសុខភាពជូនដល់គ្រួសារទាំងឡាយណាដែលត្រូវបានកំណត់អត្តសញ្ញាណថាក្រ។

## ការជួយគាំទ្រពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល

ផ្អែកលើការពិភាក្សាខាងលើ ព័ត៌មានស្តីពីថវិកាជាតិសម្រាប់វិស័យសុខាភិបាលច្រើនគ្រាន់បើត្រូវបានផលិត ប៉ុន្តែការមានព័ត៌មានទាំងនេះមានលក្ខណៈមជ្ឈការខ្លាំង ដែលតម្រូវឱ្យមានសំណើផ្លូវការ និងការយល់ព្រមពីថ្នាក់លើ។ សម្រាប់ព័ត៌មានស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល រូបភាពគឺខុសស្រលះ៖ ព័ត៌មាននេះមានលក្ខណៈរប៉ាត់រប៉ាយ។ តាមផ្លូវការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងផែនការ និងក្រសួងសុខាភិបាលគឺជាស្ថាប័នពាក់ព័ន្ធក្នុងការសម្របសម្រួលការជួយគាំទ្ររបស់ម្ចាស់ជំនួយ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរៀបចំ និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់នូវមូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការ ដើម្បីតាមដានការជួយគាំទ្ររបស់ម្ចាស់ជំនួយដល់រាជរដ្ឋាភិបាល

[8] ការជួបជាមួយមន្ត្រីនាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល នៃក្រសួងសុខាភិបាល និងនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៅថ្ងៃទី១២ ខែវិច្ឆិកា និងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩។

ទាំងមូល និងតាមវិស័យ។ មូលដ្ឋានទិន្នន័យនេះ ដាក់ឲ្យអ្នកដែលមានចំណាប់អារម្មណ៍លើប្រធានបទនេះ អាចប្រើប្រាស់បាន ហើយគុណភាពរបស់វាបាននឹងកំពុងកែលម្អជាប្រចាំ។

យ៉ាងណាក៏ដោយ ក៏ផ្នែកមួយចំនួននៅត្រូវការកែលម្អបន្ថែមទៀត។ ទីមួយ មូលដ្ឋានទិន្នន័យស្តីពីជំនួយអភិវឌ្ឍន៍ផ្លូវការនៅមិនទាន់មានលក្ខណៈងាយប្រើនៅឡើយ ពោលគឺមានតែអ្នកដែលមានចំណេះដឹងជាក់លាក់អំពីមូលដ្ឋានទិន្នន័យ និងការគ្រប់គ្រងព័ត៌មានវិទ្យាប៉ុណ្ណោះដែលអាចប្រើបានស្រួល។ ទីពីរ មូលដ្ឋានទិន្នន័យនេះ ពឹងផ្អែកលើព័ត៌មានដែលត្រូវបានផ្ញើជូនតាមការស្ម័គ្រចិត្តដោយម្ចាស់ជំនួយ ហើយម្ចាស់ជំនួយទាំងអស់នៅ មិនទាន់បានសហការឱ្យបានពេញលេញនៅឡើយលើចំណុចនេះ។ ទីបី មូលដ្ឋានទិន្នន័យនេះទៀតសោតនៅ មិនទាន់មានលក្ខណៈពេញលេញនិងត្រឹមត្រូវគ្រប់គ្រាន់នៅឡើយ។ គេឃើញមានបញ្ហារាប់ត្រួតគ្នា និងចំណាត់ ថ្នាក់ទិន្នន័យដែលគ្មានសង្គតិភាព[៩]។

ចំពោះអង្គការមិនមែនរដ្ឋាភិបាលវិញ គេឃើញមានមូលដ្ឋានទិន្នន័យមួយនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលត្រូវបានគ្រប់គ្រងដោយឡែកពីមូលដ្ឋានទិន្នន័យស្តីពីម្ចាស់ជំនួយ។ យ៉ាងណាក្តី ដូចដែលមន្ត្រីនាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការបានលើកឡើង (ថ្ងៃទី២៨ ខែវិច្ឆិកា) ព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យនេះនៅត្រូវការកែលម្អបន្ថែមទៀត ហើយសំខាន់ជាងនេះទៅទៀតវាផ្តល់ភាគច្រើនតែព័ត៌មានសរុបដែលប្រការនេះតម្រូវឱ្យក្រសួងសុខាភិបាលបង្កើតមូលដ្ឋានទិន្នន័យមួយផ្សេងទៀត សម្រាប់រក្សាទុកព័ត៌មានលម្អិតជាងនេះស្តីពីអង្គការមិនមែនរដ្ឋាភិបាល សកម្មភាព និងស្ថានភាពហិរញ្ញវត្ថុរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ។ នៅឯក្រសួងមហាផ្ទៃ ក៏មាននាយកដ្ឋានមួយដែរ ដែលទទួលបន្ទុកលើការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែសូម្បីតែនៅទីនោះ ក៏កិច្ចសហការពីអង្គការមិនមែនរដ្ឋាភិបាលមានលក្ខណៈមិនស្មើគ្នាដែរ។ ប្រភពព័ត៌មានមួយទៀតគឺអង្គការម៉េឌីខាំ ដែលអង្គការនេះមានមូលដ្ឋានទិន្នន័យមួយស្តីពីអង្គការមិនមែនរដ្ឋាភិបាលជាង ១២០ ធ្វើការនៅក្នុងវិស័យសុខាភិបាល។ មូលដ្ឋានទិន្នន័យអន្តរកម្មនេះ គូសផែនទីវត្តមាននៃអង្គការមិនមែនរដ្ឋាភិបាល តាមអនុវិស័យសុខាភិបាលរហូតដល់ថ្នាក់ឃុំ ហើយមានតែសមាជិកអង្គការម៉េឌីខាំប៉ុណ្ណោះដែលត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យនេះ យ៉ាងនេះក្តីក៏មូលដ្ឋានទិន្នន័យនេះតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងសុខភាពភាគច្រើន ហើយរាប់បញ្ចូលអង្គការមិនមែនរដ្ឋាភិបាលធំៗទាំងអស់ផងដែរ។

នៅក្នុងក្រសួងសុខាភិបាល នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិទទួលបន្ទុកលើការសម្របសម្រួលនិងតាមដានព័ត៌មានស្តីពីជំនួយពីម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាល។ ចាប់តាំងពីដើមឆ្នាំ២០០៨ មកនាយកដ្ឋាននេះ ដែលគឺជានាយកដ្ឋានមួយនៅក្មេងខ្ចីនៅឡើយបានសាកល្បងបង្កើតមូលដ្ឋានទិន្នន័យមួយដោយប្រើព័ត៌មានដែលបានផ្តល់មកពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែយោងតាមបទសម្ភាសន៍ជាមួយមន្ត្រីនាយកដ្ឋាន[10] មូលដ្ឋានទិន្នន័យនេះនៅមិនទាន់ពេញលេញនៅឡើយ ដោយសារតែអត្រាឆ្លើយតបពីម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលមិនទាន់គ្រប់គ្រាន់។ ការលំបាកនេះ ក៏ត្រូវបានបង្ហាញឲ្យឃើញច្បាស់ផងដែរនៅក្នុងរបាយការណ៍របស់នាយកដ្ឋាន ស្តីពីជំនួយបរទេសសម្រាប់វិស័យ

---

[៩] ឧទាហរណ៍ ដូចដែលបានបង្ហាញនៅក្នុងបទសម្ភាសន៍របស់យើង ប្រការដែលថាតើអង្គភាពគ្រប់គ្រងគម្រោងត្រូវបានកំណត់យ៉ាងដូចម្តេចនៅមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ។ គេឃើញមានលទ្ធភាពរាប់ត្រួតគ្នាខ្ពស់ ដោយសារស្ថាប័នលើសពីមួយអាចរាយការណ៍អំពីវត្តមាននៃអង្គភាពគ្រប់គ្រងគម្រោងតែមួយ។ បញ្ហាទាំងនេះត្រូវបានទទួលស្គាល់ដោយក្រុមការងារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលធ្វើការលើបញ្ហាសម្របសម្រួលជំនួយ ហើយពួកគេកំពុងចាត់វិធានការដើម្បីដោះស្រាយបញ្ហាទាំងនេះ។

[10] ការជួបនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩។

សុខាភិបាល (ឆ្នាំ២០០៧-២០០៩) ចុះខែមីនា ឆ្នាំ២០០៨។ គេក៏បានកត់សម្គាល់ឃើញផងដែរថា ព័ត៌មានដែលក្រសួងសុខាភិបាលបានទទួលមកដល់ពេលនេះអំពីការជួយគាំទ្ររបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលអាចមានភាពខុសគ្នាច្រើនពីព័ត៌មានដែលត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ឧទាហរណ៍ ដូចជាភាពខុសគ្នាស្រលះរវាងចំណាយ និងការព្យាករណ៍អំពីជំនួយបរទេសសម្រាប់វិស័យសុខាភិបាល ដែលបានបង្ហាញនៅក្នុងចម្លើយទៅនឹងកម្រងសំណួររបស់ក្រសួងសុខាភិបាល និងការព្យាករណ៍និងបញ្ចេញសាច់ប្រាក់ ដែលបានប្រមូលដោយមូលដ្ឋានទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់ឆ្នាំ២០០៧៖ កម្រងសំណួររបស់ក្រសួងសុខាភិបាលបង្ហាញចំនួន ១០៤លានដុល្លារអាមេរិក ខណៈដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបង្ហាញចំនួន ៣៩,៥លានដុល្លារអាមេរិក។ យ៉ាងណាក្តី គេរំពឹងថាមូលដ្ឋានទិន្នន័យនេះនឹងត្រូវបានកែលម្អឡើង ខណៈដែលក្របខ័ណ្ឌគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីប្រតិបត្តិការ (ចុះខែសីហា ឆ្នាំ២០០៧) សម្រាប់សម្របសម្រួលដៃគូអភិវឌ្ឍន៍នៅត្រូវបានគេបន្តអនុវត្ត។ ផ្នែកបន្ទាប់នឹងពិភាក្សាកាន់តែលម្អិតបន្ថែមទៀតអំពីអ្វីដែលអាចរំពឹងបាន ប្រសិនបើក្របខណ្ឌគោលនយោបាយត្រូវបានបន្តអនុវត្តប្រកបដោយជោគជ័យ។

### ៦.២. នៅថ្នាក់ក្រោមជាតិ

នៅក្នុងរចនាសម្ព័ន្ធផ្តល់សេវាសុខភាពបច្ចុប្បន្ន ថ្នាក់ក្រោមជាតិរួមមាន មន្ទីរសុខាភិបាលខេត្ត ស្រុកប្រតិបត្តិការ មន្ទីរពេទ្យបង្អែកឬមណ្ឌលសុខភាព និងកម្រិតសហគមន៍។ ព័ត៌មានដែលបានផលិតនៅកម្រិតទាំងនេះទាក់ទិននឹងស្នាដៃការងារនិងថវិកាវិស័យបានប្រែប្រួលជាហូរហែរ ដែលប្រការនេះឆ្លុះបញ្ចាំងពីកំណែទម្រង់ជាបន្តបន្ទាប់នៅក្នុងវិស័យសុខាភិបាលទាំងមូល។ មន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិការ រក្សាទុកឯកសារថវិកាស្រដៀងគ្នា ហើយមន្ទីរសុខាភិបាលខេត្តគឺជាកម្រិតខ្ពស់ជាងគេបំផុតនៅថ្នាក់ក្រោមជាតិដែលដាក់បញ្ចូលគ្នានូវរបាយការណ៍ និងស្ថិតិផ្ញើមកពីស្រុកប្រតិបត្តិការ និងកម្រិតទាបជាងនេះ។ ឯកសារទាំងនោះរួមមាន[11]៖

- ផែនការប្រតិបត្តិការខេត្តប្រចាំឆ្នាំ ដែលភាគច្រើនមានផែនការប្រតិបត្តិការប្រចាំឆ្នាំរបស់ ស្រុកប្រតិបត្តិការ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពផ្សេងៗ។ សូមមើលផ្នែក ៥.១ ស្តីពីផែនការប្រតិបត្តិការប្រចាំឆ្នាំ និងដំណើរការរៀបចំផែនការនេះ។ ផែនការប្រតិបត្តិការខេត្តប្រចាំឆ្នាំ បង្ហាញពីកម្មវិធីនិងកម្មវិធីរងផ្សេងៗ ដែលវិស័យសុខាភិបាលចង់សម្រេចបាននៅក្នុងឆ្នាំខាងមុខ ព្រមទាំងប្រភពមូលនិធិមកពី (១)-ថវិកាជាតិ និង (២)-ថវិកាដែលបានសន្យារួចហើយពីអង្គការមិនមែនរដ្ឋាភិបាល ដែលមានផែនការធ្វើប្រតិបត្តិការនៅក្នុងខេត្តពាក់ព័ន្ធនៅក្នុងឆ្នាំថវិកាបន្ទាប់។
- ផែនការប្រតិបត្តិការប្រចាំឆ្នាំ វាយតម្លៃលើការអនុវត្តផែនការ។ ឯកសារទីមួយ តំណាងឱ្យការអនុវត្តនេះគឺ ប្រព័ន្ធព័ត៌មានសុខាភិបាលដែលត្រូវបានផលិត និងផ្ញើមកពីស្រុកប្រតិបត្តិការជារៀងរាល់ខែមិនឱ្យហួសពីថ្ងៃទី១០ នៃខែបន្ទាប់ឡើយ។ ព័ត៌មាននេះត្រូវបានដាក់បញ្ចូលគ្នា និងផ្ញើទៅឱ្យក្រសួងសុខាភិបាល មិនឱ្យហួសពីថ្ងៃទី២០ ឡើយ ប៉ុន្តែក៏អាចមានការយឺតយ៉ាវខ្លះដែរនៅក្នុងការផ្ញើ

[11] ផ្អែកលើបទសម្ភាសន៍ជាមួយមន្ត្រីមន្ទីរសុខាភិបាលខេត្តមួយរូប នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ និងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩។ សំណាកគំរូនៃឯកសារទាំងអស់ដែលបានលើកឡើងខាងក្រោមអាចផ្តល់ជូនបាន។

របាយការណ៍ទាំងនេះ។ ប្រព័ន្ធព័ត៌មានសុខាភិបាល រួមមានព័ត៌មានសម្បូរណ៍បែបស្តីពីសកម្មភាពនៃការផ្តល់សេវាសុខភាព ដូចដែលមានរាប់បញ្ចូលក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំ។

- ប្រព័ន្ធព័ត៌មានសុខាភិបាល មានលក្ខណៈដូចជារបាយការណ៍ស្នាដៃអនុវត្តមួយ។ រីឯរបាយការណ៍ស្តីពីការអនុវត្តថវិកា ដូចដែលបានលើកឡើងច្រើនដងរួចមកហើយ ចាំបាច់ត្រូវមានការបែងចែករវាងព័ត៌មានស្តីពីថវិកាជាតិនិងព័ត៌មានស្តីពីថវិកាម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល។ សម្រាប់ថវិកាជាតិ គេឃើញមាន***របាយការណ៍ប្រចាំខែ*** និង ***ប្រចាំឆ្នាំស្តីពីការអនុវត្តថវិកា*** ផ្ញើមកពី ស្រុកប្រតិបត្តិការ និងត្រូវបានដាក់បញ្ចូលគ្នាបន្តទៀត សម្រាប់ផ្ញើជូនក្រសួងសុខាភិបាល។ របាយការណ៍ទាំងនេះបញ្ចូលខ្ទង់ថវិកា (ជាតិ) គ្រប់ប្រភេទទាំងអស់ តាំងពីប្រាក់បៀវត្សរ៍ ប្រតិបត្តិការនិងការថែទាំ ថ្លៃសេវា មូលនិធិសមធម៌ សុខភាព និងខ្ទង់ផ្សេងទៀត។ គួរកត់សម្គាល់ថា មានតែមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពប៉ុណ្ណោះ ដែលមានរាយការណ៍អំពីថ្លៃសេវានៅក្នុងសកម្មភាពរបស់ខ្លួន ដោយសារមានតែកម្រិតទាំងពីរនេះទេ ដែលចូលរួមដោយផ្ទាល់ក្នុងការផ្តល់សេវាសុខភាព ហើយគួរកត់សម្គាល់ផងដែរនោះគឺ នៅក្នុងវិស័យសុខាភិបាល ពុំមានការអនុវត្តការធ្វើថវិកាតាមកម្មវិធីនៅថ្នាក់ខេត្តទេ ដូច្នេះមិន មានព័ត៌មានស្តីពីថវិកាសម្រាប់ចំណុចនេះឡើយ។
- របាយការណ៍ស្តីពីការផ្ទេរឱសថនិងបរិក្ខារពេទ្យពីថ្នាក់ជាតិ និងការប្រើប្រាស់ឱសថនិងបរិក្ខារពេទ្យទាំងនេះ ត្រូវបានផលិតប្រចាំត្រីមាសនិងប្រចាំឆ្នាំ។ បទសម្ភាសន៍ផ្ទាល់បង្ហាញថា ឱសថនិងបរិក្ខារពេទ្យ សុទ្ធតែត្រូវបានធ្វើលទ្ធកម្ម និងរក្សាទុកនៅឃ្លាំងបរិក្ខារពេទ្យកណ្តាល។ បន្ទាប់មក ឱសថ និងបរិក្ខារពេទ្យទាំងនេះត្រូវបានផ្ទេរដោយផ្ទាល់ទៅឱ្យ ស្រុកប្រតិបត្តិការផ្សេងៗរៀងរាល់ត្រីមាស។ មន្ទីរសុខាភិបាលខេត្តរក្សាទុកតែឯកសារស្តីពីការផ្ទេរទាំងនោះប៉ុណ្ណោះ។ ស្រុកប្រតិបត្តិការ ទទួលបន្ទុកក្នុងការរៀបចំរបាយការណ៍ប្រចាំត្រីមាសស្តីពីការប្រើប្រាស់ឱសថនិងបរិក្ខារពេទ្យទាំងនោះ ហើយផ្ញើរបាយការណ៍ទាំងនោះទៅឲ្យមន្ទីរសុខាភិបាលខេត្ត សម្រាប់ដាក់បញ្ចូលគ្នា និងផ្ញើបន្តទៅឱ្យក្រសួងសុខាភិបាលឬឃ្លាំងបរិក្ខារកណ្តាល។ របាយការណ៍ទាំងនោះមានបញ្ជីលម្អិតស្តីពីប្រភេទឱសថ និងបរិក្ខារនីមួយៗ ព្រមទាំងបរិមាណដែលបានផ្ទេរនិងប្រើប្រាស់។

អង្គការមិនមែនរដ្ឋាភិបាលធ្វើសកម្មភាពច្រើននៅថ្នាក់ក្រោមជាតិក្នុងការអនុវត្តគម្រោងរបស់ខ្លួន។ នៅតាមខេត្តដែលបានចុះសិក្សា អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនបានចុះបញ្ជីជាមួយក្រសួងសុខាភិបាល និងធ្វើការលើបញ្ហាទាក់ទិននឹងមេរោគអេដស៍ឬជម្ងឺអេដស៍។ ដោយសារការរួមចំណែកដ៏សំខាន់របស់ពួកគេ វាគឺជាការសំខាន់ដែលសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលត្រូវសម្របសម្រួល និងគិតពិចារណាឱ្យបានល្អ។ សម្រាប់គោលបំណងទាំងនេះ យន្តការមួយដែលមានឈ្មោះថាក្រុមការងារបច្ចេកទេសរួមផ្នែកសុខាភិបាលថ្នាក់ខេត្តត្រូវបានបង្កើតឡើង ដើម្បីឱ្យមន្ត្រីសុខាភិបាលថ្នាក់ក្រោមជាតិ ដែលដឹកនាំដោយមន្ទីរសុខាភិបាលខេត្តអាចជួបជាមួយអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលធ្វើការនៅក្នុងដែនដីរបស់ខ្លួន ជារៀងរាល់ខែ ឬរៀងរាល់ពីរខែម្តង (អាស្រ័យលើពេលវេលា និងកម្រិតនៃភាពបន្ទាន់ចាំបាច់)។ របៀបវារៈត្រូវបានកំណត់សម្រាប់ កិច្ចប្រជុំនីមួយៗ ហើយជាធម្មតា បទបង្ហាញមួយត្រូវបានធ្វើពីខាងរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការអនុវត្តថវិកាជាតិ។ អង្គការមិនមែនរដ្ឋាភិបាល ក៏ត្រូវបានស្នើផងដែរឱ្យរាយការណ៍អំពីសកម្មភាព និងស្ថានភាពថវិការបស់ខ្លួន ប៉ុន្តែដូចដែលប្រធានមន្ទីរសុខាភិបាលខេត្តបានលើកឡើង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនមិនចង់ រាយការណ៍អំពីស្ថានភាពថវិការបស់ខ្លួនឡើយ។

នៅកម្រិតសហគមន៍ មណ្ឌលសុខភាពគឺជាអង្គភាពសំខាន់ជាងគេក្នុងការផ្តល់សេវាសុខភាព។ មណ្ឌលសុខភាពនីមួយៗត្រូវបានសន្មតថាបម្រើដល់ប្រជាជនពី ៨.០០០ ទៅ ១៥.០០០នាក់។ ចំណុចនេះមានន័យថាមណ្ឌលសុខភាពនីមួយៗ អាចមានវិសាលភាពលើដែនដីលើសពីឃុំរដ្ឋបាលចំនួនមួយ អាស្រ័យលើទំហំចំនួនប្រជាជនរបស់ឃុំរដ្ឋបាល ហើយសម្រាប់មណ្ឌលសុខភាពនីមួយៗ គណៈកម្មាធិការទ្រទ្រង់មណ្ឌលសុខភាពមួយ ត្រូវបានបង្កើតឡើងដោយមានសមាជិកភាពពី ៧ ទៅ ១១នាក់ រួមទាំងមេឃុំពាក់ព័ន្ធផងដែរ។ គណៈកម្មាធិការត្រូវបានសន្មតថាគឺជាយន្តការ ដែលតាមរយៈនោះមេឃុំអាចទទួលបានព័ត៌មាន (រួមទាំងព័ត៌មានស្តីពីថវិកាផងដែរ) អំពីមណ្ឌលសុខភាព និងលើកសំណើអំពីរបៀបដែលសេចក្តីត្រូវការខាងសុខភាពរបស់ប្រជាជនអាចត្រូវបានឆ្លើយតបប្រកបដោយប្រសិទ្ធភាព។ ដូចបានចែងក្នុងវិធាន ព័ត៌មានថវិការបស់មណ្ឌលសុខភាពចាំបាច់ត្រូវផ្តល់ជូនមេឃុំតាមការទាមទារ។

ដូចដែលបានរៀបរាប់ ព័ត៌មានថវិកាជាច្រើនត្រូវបានផលិតនៅថ្នាក់ក្រោមជាតិ ប៉ុន្តែព័ត៌មាននេះភាគច្រើនគឺដើម្បីគោលបំណងធ្វើសវនកម្មនិងអធិការកិច្ចដោយស្ថាប័នកណ្តាលនានា (ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នសវនកម្ម) និងម្ចាស់ជំនួយ មិនមែនសម្រាប់ចែករំលែកជាមួយសាធារណជនឡើយ ថ្វីបើអាចត្រូវបានផ្តល់ជូនអាជ្ញាធរមូលដ្ឋានដូចជាមេឃុំជាដើមក្តី។ នៅពេលសួរថា តើព័ត៌មាននេះអាចផ្សព្វផ្សាយជូនសាធារណជនឬទេ ចម្លើយគឺថា ដោយសារប្រព័ន្ធបច្ចុប្បន្នមានលក្ខណៈមជ្ឈការខ្លាំងនៅក្នុងទិដ្ឋភាពជាច្រើន ការផ្សព្វផ្សាយបែបនេះអាចធ្វើបានលុះត្រាតែមានការយល់ព្រមជាផ្លូវការពីក្រសួងសុខាភិបាល ឬស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធដូចជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប៉ុណ្ណោះ ហើយប្រសិនបើមានការអនុញ្ញាតបែបនេះ ថ្នាក់ក្រោមជាតិរីករាយក្នុងការចែករំលែកព័ត៌មានណាដែលត្រូវការ។ និយាយម៉្យាងទៀត វាគឺជាស្ថានភាពមួយដែលមានលក្ខណៈ "បានទាំងអស់ ឬមិនបានសោះ"។

## ៧. ការមានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល៖ ការផ្លាស់ប្តូរដែលរំពឹងទុកក្នុងរយៈពេលខ្លី និងមធ្យម

នៅក្នុងទិដ្ឋភាពជាច្រើន ប្រព័ន្ធធ្វើថវិកានៅក្នុងវិស័យសុខាភិបាល និងជារួមគឺនៅទន់ខ្សោយ ហើយវាប្រែប្រួលជានិច្ចតាមរយៈកំណែទម្រង់ផ្សេងៗ។ កំណែទម្រង់ខ្លះមានលក្ខណៈផ្តែក្នុងចំពោះវិស័យ ខណៈដែលកំណែទម្រង់ខ្លះទៀតគឺជាលទ្ធផលនៃកំណែទម្រង់ធំទូលាយមួយចំនួន ដែលនៅក្នុងនោះកំណែទម្រង់លេចធ្លោជាងគេគឺ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ។ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារថវិកាក្នុងវិស័យសុខាភិបាលចាំបាច់ត្រូវតាមដានកំណែទម្រង់ខាងក្នុង និងខាងក្រៅទាំងនេះ។ ខាងក្រោមនេះ គឺជាកំណែទម្រង់គន្លឹះៗ ដែលនឹងមានផលប៉ះពាល់រយៈពេលខ្លី និងមធ្យមលើការទទួលព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល។

### ៧.១. នៅក្នុងកំណែទម្រង់វិស័យសុខាភិបាល

ផែនការប្រតិបត្តិការប្រចាំឆ្នាំនិងផែនការបីឆ្នាំរំកិល៖ ផ្នែក ៥.១ ខាងលើបានពិពណ៌នារួចមកហើយនូវផែនការទាំងនេះ។ ផែនការប្រតិបត្តិការប្រចាំឆ្នាំត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៥ មក តែទោះជាយ៉ាងណាក្តី ក៏បទសម្ភាសន៍ជាមួយមន្ត្រីថ្នាក់កណ្តាលបង្ហាញថា ផែនការប្រតិបត្តិការប្រចាំឆ្នាំនៅត្រូវការការកែលម្អបន្ថែមដើម្បីបញ្ចូលឲ្យកាន់តែបានពេញលេញ គ្រប់ប្រភពមូលនិធិសក្តានុពលទាំងអស់។ ដោយមានការសន្យាពីក្រសួងនិងដៃគូអភិវឌ្ឍន៍ ផែនការប្រតិបត្តិការប្រចាំឆ្នាំឬផែនការបីឆ្នាំរំកិល មានសក្តានុពលក្នុងការក្លាយជា

ប្រភពព័ត៌មានមួយដ៏មានប្រយោជន៍ ដែលប្រសិនជាមិនត្រូវបានផ្ដល់ឱ្យដោយរដ្ឋសភាទេនោះ ក៏អាចស្នើសុំបានពីក្រសួងសុខាភិបាលដែរ។ ព័ត៌មាននឹងរាប់បញ្ចូលការជួយគាំទ្ររបស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលផង ព្រមទាំងរបៀបដែលការគាំទ្រនេះត្រូវបានផ្សារភ្ជាប់ទៅនឹងសូចនាករស្នាដៃអនុវត្តមួយចំនួន។ ម៉្យាងទៀត ដោយសារផែនការប្រតិបត្តិការប្រចាំឆ្នាំមានទាំងសមាសភាគពីក្រោមឡើងលើ និងពីលើចុះក្រោម ផែនការនេះអាចនឹងក្លាយជាប្រភពនៃព័ត៌មានស្ដីពីស្នាដៃអនុវត្តនិងថវិកាដ៏ពេញលេញមួយ (រួមទាំងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាល) សម្រាប់ប្រតិបត្តិការសុខភាពនៅថ្នាក់ក្រោមឯទៀតៗ។ ទោះបីជានៅពេលបច្ចុប្បន្ន ផែនការប្រតិបត្តិការប្រចាំឆ្នាំ នៅមិនទាន់មានលក្ខណៈពេញលេញក្ដី ក៏វាជាឯកសារដ៏មានប្រយោជន៍មួយរួចទៅហើយ ជាពិសេសនៅពេលប្រើរួមជាមួយនឹងរបាយការណ៍ ឬវេទិកាតាមដាននិងវាយតម្លៃផ្សេងទៀត ដូចជាការពិនិត្យវាយតម្លៃរួមលើស្នាដៃអនុវត្តប្រចាំឆ្នាំ និងមហាសន្និបាត សុខាភិបាលប្រចាំឆ្នាំ។

ការផ្លាស់ប្ដូរទៅកាន់ការធ្វើថវិកាតាមកម្មវិធី និងទីភ្នាក់ងារប្រតិបត្តិការពិសេស៖ វិស័យសុខាភិបាលត្រូវបានជ្រើសរើស រួមជាមួយវិស័យអប់រំ និងវិស័យផ្សេងទៀតចំនួនប្រាំ ឱ្យដំណើរការការធ្វើថវិកាតាមកម្មវិធី។ ថ្វីបើការធ្វើថវិកាតាមកម្មវិធីត្រូវបានអនុវត្តតែលើ ចំណាយប្រតិបត្តិការមិនមែនប្រាក់ខែតែនៅថ្នាក់ជាតិ និងអនុវត្តបានត្រឹមតែ ៦% ក្នុងឆ្នាំ២០០៧ និង ៩,៦% ក្នុងឆ្នាំ២០០៨ (ច្បាប់ថវិកាឆ្នាំ ២០០៧ និង ២០០៨) ក៏វាគឺជាអនាគតដែលការធ្វើថវិកាក្នុងវិស័យសុខាភិបាលកម្ពុជាកំពុងសំដៅឆ្ពោះទៅរក។ ការផ្លស់ប្ដូរស្របគ្នាមួយទៀតគឺ ការដាក់ឱ្យប្រើប្រាស់ទីភ្នាក់ងារប្រតិបត្តិការពិសេស។ និយាយដោយខ្លី ទីភ្នាក់ងារប្រតិបត្តិការពិសេសគឺជា ទីភ្នាក់ងារផ្ដល់សេវាផ្អែកលើស្នាដៃអនុវត្ត ដែលបំពេញការងារក្រោមកិច្ចសន្យាគ្រប់គ្រងមួយជាមួយក្រសួងមេ។ ទីភ្នាក់ងារនេះរៀបចំថវិកាផ្ទាល់ខ្លួន និងទទួលហិរញ្ញប្បទានពីថវិកាជាតិ ថវិកាម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងថ្លៃសេវា។ ទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវបានបង្កើតដោយព្រះរាជក្រម ដូច្នេះមានឋានៈស្របច្បាប់ដ៏រឹងមាំដើម្បីបន្តដំណើរការទៅមុខ (ព្រះរាជក្រមលេខ៣៤៦ ចុះខែមីនា ឆ្នាំ២០០៨)។ ឥទ្ធិពលនៃការធ្វើថវិកាតាមកម្មវិធី និងទីភ្នាក់ងារប្រតិបត្តិការពិសេសគឺមានដូចតទៅនេះ។ មួយវានឹងផលិតព័ត៌មាន ដែលអាចផ្សារភ្ជាប់រវាងធាតុ ចូលនិងធាតុចេញ ដែលគឺជាប្រធានបទមួយដ៏គួរឱ្យចាប់អារម្មណ៍សម្រាប់អង្គការសង្គមស៊ីវិល និងប្រជាជនដែលទទួលសេវាសាធារណៈ។ មួយទៀតគឺថាការធ្វើថវិកាតាមកម្មវិធី និងទីភ្នាក់ងារប្រតិបត្តិការពិសេស ធ្វើឱ្យមានប្រព័ន្ធថវិកាមួយដែលមានលក្ខណៈវិមជ្ឈការជាងមុន ដែលខុសពីប្រព័ន្ធថវិកាបែបមជ្ឈការបច្ចុប្បន្ន។ ឧទាហរណ៍ ជាមួយនឹងការមានវិមជ្ឈការកាន់តែខ្លាំងឡើង គណនេយ្យភាពរបស់ទីភ្នាក់ងារប្រតិបត្តិការពិសេស នឹងមិនមានត្រឹមតែខ្សែបណ្ដោយឡើងត្រង់ទៅលើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានខ្សែឆ្ពោះទៅកាន់ក្រុមប្រឹក្សាខេត្ត ស្រុក និងឃុំ និងប្រជាជនថែមទៀតផង (សូមមើលបន្ថែមនៅខាងក្រោមស្ដីពីក្រុមប្រឹក្សាខេត្ត និងស្រុកក្រោមវិមជ្ឈការ និងវិសហមជ្ឈការ)។

ប្រព័ន្ធព័ត៌មានសុខាភិបាល៖ កាលពីខែសីហា ឆ្នាំ២០០៨ ក្រសួងសុខាភិបាលបានអនុម័តជាលើកទីមួយនូវផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាល (HISSP) សម្រាប់ឆ្នាំ២០០៨-២០១៥។ ចក្ខុវិស័យនេះផែនការនេះគឺ *"ត្រូវមានព័ត៌មានសុខាភិបាល និងព័ត៌មានដែលទាក់ទងទៅនឹងសុខាភិបាល ដែលមានលក្ខណៈពាក់ព័ន្ធទាន់ពេលវេលា និងមានគុណភាពខ្ពស់ សម្រាប់ធ្វើគោលនយោបាយ ធ្វើការសម្រេចចិត្តដោយផ្អែកទៅលើភស្តុតាងជាក់ស្ដែង ការអនុវត្តកម្មវិធី និងការត្រួតពិនិត្យតាមដាន និងការវាយតម្លៃដើម្បីចូលរួមចំណែកធ្វើឲ្យសុខភាពប្រជាជនបានល្អប្រសើរឡើង។"* ផែនការយុទ្ធសាស្ត្រនេះនឹងមានសមាសភាគសំខាន់ៗចំនួនប្រាំ រួមទាំងព័ត៌មានស្ដីពីធនធាន និងហិរញ្ញប្បទាន។ យុទ្ធសាស្ត្រនេះត្រូវបានស្នើឡើង ដើម្បី

ជាចម្លើយតបមួយទៅនឹងព័ត៌មានសុខាភិបាល បច្ចុប្បន្នដែលនៅមានកម្រិតនៅឡើយ ជាពិសេសទាក់ទិននឹងព័ត៌មានស្តីពីការមានធនធាន។ គេមិនដឹងប្រាកដទេថាតើនៅពេលណាទើបប្រព័ន្ធព័ត៌មានសុខាភិបាលនឹងត្រូវបានអភិវឌ្ឍឲ្យបានគ្រប់គ្រាន់ ប៉ុន្តែគោលបំណងនៃ ប្រព័ន្ធព័ត៌មាននេះគឺសំដៅធ្វើឱ្យព័ត៌មានអាចត្រូវប្រមូលបានជាប្រព័ន្ធមិនត្រឹមតែសម្រាប់បម្រើដល់អ្នកធ្វើគោលនយោបាយប៉ុណ្ណោះទេថែមទាំងសាធារណជនរួមទាំងអង្គការមិនមែនរដ្ឋាភិបាលថែមទៀតផង។ ការធ្វើបច្ចុប្បន្នកម្មលើការរៀបចំប្រព័ន្ធព័ត៌មាននេះ អាចធ្វើបានតាមរយៈការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធសំខាន់ៗរួមមាន នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាលនៃក្រសួងសុខាភិបាល វិទ្យាស្ថានជាតិស្ថិតិ និងម្ចាស់ជំនួយមួយចំនួនដូចជា អង្គការសុខភាពពិភពលោក (WHO) និងបណ្តាញម៉ែត្រសាស្ត្រសុខភាព (Health Metrics Networks) (ក្រសួងសុខាភិបាលឆ្នាំ២០០៨)។

គំនិតផ្តួចផ្តើមនិងមូលដ្ឋានទិន្នន័យរបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសុខាភិបាល៖ ដូចបានលើកឡើងខាងដើម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងសុខាភិបាល កំពុងធ្វើឲ្យជឿនលឿនឡើងនូវមូលដ្ឋានទិន្នន័យថ្មីមួយ ដោយធ្វើឱ្យវាមានលក្ខណៈពេញលេញតាមដែលអាចធ្វើទៅបាន ហើយនាយកដ្ឋាននេះក៏មានបំណងផ្សារភ្ជាប់មូលដ្ឋានទិន្នន័យនេះជាមួយនឹងមូលដ្ឋានទិន្នន័យរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ។ ក្រោយពេលកែលម្អហើយ មូលដ្ឋានទិន្នន័យនេះនឹងមានប្រយោជន៍ខ្លាំងសម្រាប់ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកដែលចាប់អារម្មណ៍អំពីហិរញ្ញប្បទានសុខាភិបាលរបស់ម្ចាស់ជំនួយ។ លទ្ធភាពទទួលបានទិន្នន័យនេះដើម្បីប្រើប្រាស់ទំនងជាអាចទៅរួច ដោយសារនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយ។

## ៧.២. ពីកំណែទម្រង់ទូលាយជាងផ្សេងទៀត

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨៖ កំណែទម្រង់នេះមានផលប៉ះពាល់ខ្លាំងបំផុតលើលទ្ធភាពទទួលបានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល និងជារួម។ មុនពេលអនុម័តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ប្រព័ន្ធថវិកាអនុវត្តតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៣ ដែលផ្តោតលើមជ្ឈការអំណាច និងអនុលោមភាព។ យោងតាមច្បាប់ឆ្នាំ១៩៩៣ ការធ្វើថវិកាគឺភាគច្រើនផ្តោតលើការគ្រប់គ្រងផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល ដោយមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារជាតិ បំពេញមុខងារជាតួអង្គកណ្តាល និងតួអង្គសំខាន់។ ច្បាប់ឆ្នាំ១៩៩៣នេះ មិនមានចែងពីតួនាទីរបស់សាធារណជននៅក្នុងកិច្ចការធ្វើថវិកាទេ។ ផ្ទុយទៅវិញ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បើនិយាយជារួម និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ បើនិយាយដោយឡែក ចែងពីការចូលរួមរបស់សាធារណជន និងសង្គមស៊ីវិល។ មាត្រា៨៤ នៃច្បាប់ថ្មីនេះចែងដូចខាងក្រោម៖

> "រាល់ការអនុវត្តចំណូល និងចំណាយនៃថវិការដ្ឋ ត្រូវធ្វើឡើងទៅតាមបទប្បញ្ញត្តិ និងសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រាល់ការកត់ត្រា ចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគោរពទៅតាមប្លង់គណនេយ្យ និងមាតិការថវិកា ហើយរាល់របាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ**<u>ត្រូវមានតម្លាភាព និងផ្សព្វផ្សាយជាសាធារណៈ</u>**។"

ប្បញ្ញត្តិច្បាប់ថ្មីនេះបើកទូលាយនូវឱកាសសម្រាប់ឱ្យអង្គការសង្គមស៊ីវិលសុំចូលរួម និងកសាងវិធីសាស្ត្រ អំពីរបៀបចូលរួមដោយសុទ្ធចិត្តក្នុងកិច្ចការធ្វើថវិការបស់រដ្ឋ។

កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - កែលម្អប្រព័ន្ធគណនេយ្យរបស់រាជរដ្ឋាភិបាល៖ ទោះបីជាមានការដាក់ឱ្យអនុវត្តប្លង់គណនីថ្មី និងការដាក់បញ្ចូលគម្រោងផ្តល់មូលនិធិដោយម្ចាស់ជំនួយទៅក្នុងច្បាប់ថវិកាចាប់តាំងពីឆ្នាំ២០០៧ មកក្តី ក៏ព័ត៌មានស្តីពីថវិកានៅកម្ពុជានៅតែមានលក្ខណៈមជ្ឈការ (សម្រាប់ព័ត៌មានស្តីពីថវិកាជាតិ) និងរប៉ាត់រប៉ាយ (សម្រាប់ព័ត៌មានស្តីពីជំនួយរបស់ម្ចាស់ជំនួយ) និងភាគច្រើនមិនមានទាន់ពេលវេលា។ កំណែទម្រង់នេះសំដៅ៖ (១)-អនុវត្តប្លង់គណនីចំពោះចំណាយមូលធនដែលទទួលហិរញ្ញប្បទានក្នុងប្រទេស (មកដល់ពេលនេះប្លង់គណនីអនុវត្តតែចំពោះចំណាយចរន្តប៉ុណ្ណោះ) (២)-ផ្តល់ព័ត៌មានជំនួយដែលត្រូវបានបញ្ចេញ និងចំណាយដែលត្រូវបានចាយចេញពីគណនីនៃគម្រោងម្ចាស់ជំនួយផងដែរ (៣)-កាត់បន្ថយការយឺតយ៉ាវក្នុងការរៀបចំតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ (៤)-អនុវត្តឲ្យបានពេញលេញនូវប្រព័ន្ធកុំព្យូទ័រនៅក្នុងប្រព័ន្ធរតនាគាជាតិ (៥)-ណែនាំឱ្យអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុនៅតាមអង្គភាពមួយចំនួនឱ្យបានមុនដំណាច់ឆ្នាំ២០១១ និង (៦)-ដាក់ចេញចំណាត់ថ្នាក់ថវិកាកាន់តែលម្អិតទៅតាមខេត្តនិងស្ថាប័នវិសហមជ្ឈការ[12]។ ជាមួយនឹងប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ កំណែទម្រង់នេះនឹងផ្តល់ឱ្យអង្គការសង្គមស៊ីវិលយ៉ាងមានប្រសិទ្ធិភាពនូវលទ្ធភាពកាន់តែច្រើនឡើង ក្នុងការទទួលបានទិន្នន័យថវិកាកាន់តែពេញលេញ និងបំបែកលម្អិតទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ៖ កំណែទម្រង់នេះ គឺធ្វើនៅក្នុងរាជរដ្ឋាភិបាលទាំងមូល។ ដោយមានច្បាប់អង្គការអនុម័តរួច (ខែឧសភា ឆ្នាំ២០០៨) និងការគាំទ្រជាសាធារណៈពីសម្តេចនាយករដ្ឋមន្ត្រីផ្ទាល់ កំណែទម្រង់នេះនឹងបោះជំហានទៅមុខ។ កម្មវិធីជាតិមួយកំពុងត្រូវបានរៀបចំសម្រាប់ការអនុវត្តក្នុងរយៈពេលដប់ឆ្នាំខាងមុខ (ឆ្នាំ២០១០-២០១៩)។ កំណែទម្រង់នេះនឹងមានផលប៉ះពាល់ដល់វិស័យផ្សេងៗ រួមទាំងវិស័យសុខាភិបាល និងរបៀបដែលសេវាសាធារណៈត្រូវបានផ្តល់តាមរយៈសមាសភាគប្រជាធិបតេយ្យឬដោយមានការចូលរួមច្រើនជាងមុន។ ក្នុងខែឧសភា ឆ្នាំ២០០៩ ក្រុមប្រឹក្សារាជធានី ខេត្ត ស្រុក និងក្រុង នឹងត្រូវបានបោះឆ្នោតជ្រើសរើស (ដោយប្រយោលដោយសមាជិកក្រុមប្រឹក្សាឃុំ)។ ក្រុមប្រឹក្សានេះ នឹងមានរដ្ឋបាលនិងថវិកាឯកភាពមួយ។ ថវិកាត្រូវបានកំណត់ឱ្យផ្សព្វផ្សាយជាសាធារណៈ និងគ្របដណ្តប់ផងដែរលើស្ថាប័នវិសហមជ្ឈការមួយចំនួន នេះបើយោងតាមច្បាប់អង្គការ និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

[12] សូមមើល Lienert, I. J. Helis និង អ្នកដទៃ (២០០៨)។ កម្ពុជា៖ កែលម្អគណនេយ្យរបស់រាជរដ្ឋាភិបាល។ ភ្នំពេញ, មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

## ៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

របាយការណ៍នេះសន្និដ្ឋានថាបញ្ហានៃការមានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាលមិនមានលក្ខណៈងាយយល់ដូចដែលគេគិតនោះទេ។ វាមិនមែនត្រឹមតែជាបញ្ហានៃបទប្បញ្ញត្តិច្បាប់ប៉ុណ្ណោះទេ ថែមទាំងជាបញ្ហាអនុវត្ត មិនមែនត្រឹមតែជាបញ្ហារបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ថែមទាំងជាបញ្ហារបស់ម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាលថែមទៀតផង ហើយវាមិនមែននៅទ្រឹងទេ ប៉ុន្តែប្រែប្រួលជារឿយៗ ដែលតម្រូវឱ្យអង្គការមិនមែនរដ្ឋាភិបាលដែលចាប់អារម្មណ៍ត្រូវតែតាមដានឲ្យបានជាប់នូវបច្ចុប្បន្នកម្មរបស់ព័ត៌មានថវិកា និងកែសម្រួលជាប្រចាំនូវយុទ្ធសាស្ត្រដែលខ្លួនប្រើដើម្បីទទួលព័ត៌មាន និងមានឥទ្ធិពលលើការសម្រេចចិត្តនានា។ យ៉ាងណាក្តី ជាមួយនឹងកំណែទម្រង់ដែលកំពុងតែដំណើរការទៅមុខ ព័ត៌មានស្តីពីថវិកាសម្រាប់វិស័យសុខាភិបាល (និងសម្រាប់ទូទាំងរាជរដ្ឋាភិបាល) នឹងត្រូវបានផ្សព្វផ្សាយ ដែលប្រការនេះផ្តល់ឱកាសដ៏ល្អមួយដល់អង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យនេះ។

របាយការណ៍នេះផ្តល់អនុសាសន៍ថាអង្គការសង្គមស៊ីវិលដែលចាប់អារម្មណ៍ចាំបាច់ត្រូវសម្រេចយកយុទ្ធវិធីជាក់លាក់មួយចំនួន និងបង្កើតភាពជាដៃគូចាំបាច់ដើម្បីទទួលបានទិន្នន័យគ្រប់គ្រាន់ ជាពិសេសនៅចំពោះមុខភាពរប៉ាត់រប៉ាយនៃប្រព័ន្ធបច្ចុប្បន្ន។ យុទ្ធវិធីទាំងនេះចាំបាច់ត្រូវតាក់តែងឡើងសម្រាប់រយៈពេលភ្លាមៗ រយៈពេលមធ្យម និងរយៈពេលវែង ហើយយុទ្ធវិធីទាំងនេះចាំបាច់ត្រូវឆ្លុះបញ្ចាំងនូវការប្រែប្រួលនានាដែលបណ្តាលមកពីកំណែទម្រង់ផ្សេងៗ។

### ៨.១. សម្រាប់រយៈពេលភ្លាមៗ

ប្រើប្រាស់យន្តការក្រុមការងារបច្ចេកទេសរួម និងក្រុមការងារបច្ចេកទេសខេត្តឱ្យបានកាន់តែប្រសើរឡើង ដើម្បីទទួលបានទិន្នន័យស្តីពីការអនុវត្តថវិកានៅក្នុងវិស័យសុខាភិបាល។ ព័ត៌មានស្តីពីស្នាដៃអនុវត្តវិស័យ និងថវិកានៅក្នុងវិស័យសុខាភិបាលមានលក្ខណៈលម្អិតខ្លាំង ជាពិសេសបើគេអាចទទួលបាននូវរបាយការណ៍ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ដែលត្រូវបានរៀបចំនៅក្នុងវិស័យសុខាភិបាលខ្លួនឯង ប៉ុន្តែតាមវិធាន ព័ត៌មានលម្អិតទាំងនោះអាចផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាលបានលុះត្រាតែមានការយល់ព្រមជាផ្លូវការពីថ្នាក់លើប៉ុណ្ណោះ (ពោលគឺក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។ យ៉ាងនេះក្តី ក្នុងគោលបំណងកែលម្អភាពជាដៃគូជាមួយម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល រាជរដ្ឋាភិបាលបានប្តេជ្ញាចែករំលែកព័ត៌មានស្តីពីថវិកា ដោយប្រើយន្តការក្រុមការងារបច្ចេកទេសរួមថ្នាក់ជាតិ និងក្រុមការងារបច្ចេកទេសរួមថ្នាក់ខេត្ត។ ជាផ្នែកមួយនៃវិមជ្ឈការយ៉ាងទូលំទូលាយ ក៏មានការជម្រុញផងដែរឲ្យមានការចែករំលែកព័ត៌មានជាមួយអាជ្ញាធរឃុំ តាមរយៈវេទិកាគណៈកម្មាធិការគាំទ្រមណ្ឌលសុខភាព។ អង្គការម៉េឌីខាំត្រូវបានគេដឹងថាបានតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងយន្តការក្រុមការងារបច្ចេកទេសរួម និងដោយហេតុនេះហើយ ក៏ទទួលបានព័ត៌មានបច្ចុប្បន្នភាពស្តីពីការអនុវត្តថវិការដ្ឋ និងព័ត៌មានផ្សេងទៀត។ ម្យ៉ាងទៀត ក្នុងឋានៈជាអង្គការមិនមែនរដ្ឋាភិបាលឈានមុខគេនៅក្នុងវិស័យសុខាភិបាល អង្គការម៉េឌីខាំក៏មានព័ត៌មានជាច្រើនស្តីពីសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលដៃគូ។ ហេតុដូច្នេះ សម្រាប់រយៈពេលមធ្យម ដើម្បីធានាបាននូវការទទួលព័ត៌មានស្តីពីថវិកាជាតិ និងការជួយគាំទ្ររបស់ម្ចាស់ជំនួយឬអង្គការមិនមែនរដ្ឋាភិបាលឱ្យបានកាន់តែប្រសើរឡើង អង្គការមិនមែនរដ្ឋាភិបាលគប្បីគួរសម្របសម្រួលគ្នាឱ្យបានកាន់តែខ្លាំងឡើង ហើយប្រើប្រាស់យន្តការក្រុមការងារបច្ចេកទេសរួមដែលមានស្រាប់ឱ្យបានកាន់តែប្រសើរ។

កសាងទំនាក់ទំនងផ្លូវការជាមួយក្រសួងសុខាភិបាលៈ ដើម្បីបំពេញបន្ថែមលើយន្តការក្រុមការងារបច្ចេកទេសរួម អង្គការមិនមែនរដ្ឋាភិបាលគប្បីគួរសម្របសម្រួល និងឯកភាពគ្នាលើការកសាងទំនាក់ទំនងផ្លូវការជាមួយក្រសួងសុខាភិបាល ដើម្បីទទួលព័ត៌មានស្តីពីថវិកាឱ្យបានទៀងទាត់។ ដូចដែលបទពិសោធន៍បានបង្ហាញស្រាប់ ឋានានុក្រមការិយាធិបតេយ្យនៅក្រសួងសុខាភិបាលអាចមានលក្ខណៈវែងអន្លាយពេក និងត្រូវចំណាយពេលដ៏ច្រើន ប្រសិនបើលិខិតស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីឬរដ្ឋលេខាធិការត្រូវដាក់ជូនរាល់ពេលដែលអង្គការមិនមែនរដ្ឋាភិបាលមួយចង់បានព័ត៌មានស្តីពីថវិកាសុខាភិបាល។ វាអាចមានប្រសិទ្ធភាពជាង ប្រសិនទំនាក់ទំនងដូចជាអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាដើម ត្រូវបានបង្កើតឡើងរវាងក្រុមអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងសុខាភិបាល ទាក់ទិននឹងបញ្ហាទទួលព័ត៌មានស្តីពីថវិកានេះ។

## ៨.២. សម្រាប់រយៈពេលមធ្យម និងវែង

ចំពោះមុខការប្រែប្រួលជាប្រចាំនៃការធ្វើផែនការនិងការធ្វើថវិកានៅក្នុងវិស័យសុខាភិបាល ក៏ដូចជាដំណើរការទៅមុខនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ អង្គការមិនមែនរដ្ឋាភិបាល ដែលព្យាយាមទទួលព័ត៌មានអំពី និងចូលរួមក្នុងបញ្ហាថវិកានៅក្នុងវិស័យសុខាភិបាលចាំបាច់ត្រូវពិចារណាចំណុចខាងក្រោមៈ

ទទួលព័តមានបច្ចុប្បន្នភាពទៀងទាត់អំពីកំណែទម្រង់សំខាន់ៗទាំងនៅក្នុងវិស័យសុខាភិបាល និងអន្តរវិស័យ។ នៅក្នុងរយៈពេលពីបីទៅប្រាំឆ្នាំខាងមុខ អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធគប្បីជានាឱ្យបាននូវព័ត៌មានបច្ចុប្បន្នភាពទៀងទាត់ និងសមស្របស្តីពីការកែលម្អផែនការប្រតិបត្តិការប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយពាក់កណ្តាលអាណត្តិ និងការប្រើប្រាស់ទីភ្នាក់ងារប្រតិបត្តិការពិសេសនៅក្នុងវិស័យសុខាភិបាល។ កំណែទម្រង់ទាំងនេះនឹងនាំមកនូវការផ្លាស់ប្តូរដល់របៀបដែលសេវាសុខភាពត្រូវបានផ្តល់ និងហេតុដូច្នេះហើយរបៀបដែលថវិកាត្រូវបានរៀបចំ និងរាយការណ៍។ របៀបដែលថវិកាតាមកម្មវិធីត្រូវបានពង្រីក និងដែលការគ្រប់គ្រងរបស់វាបានផ្លាស់ប្តូរក៏គប្បីគួរត្រូវតាមដានផងដែរ ហើយទន្ទឹមនឹងនេះ សកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើការកែលម្អគណនេយ្យសាធារណៈ គប្បីគួរត្រូវបានសង្កេតឱ្យបានទៀងទាត់។ ទំនាក់ទំនងជាប្រចាំជាមួយនឹងម្ចាស់ជំនួយសំខាន់ៗដល់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមានធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងជាមួយសមាជិកនៃក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏នឹងអាចជាជំនួយក្នុងការទទួលព័ត៌មានបច្ចុប្បន្នភាពបានដែរ។

កសាងលើបញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ស្តីពីភាពចាំបាច់ត្រូវផ្សព្វផ្សាយព័ត៌មានស្តីពីថវិកាជាសាធារណៈ។ ច្បាប់នេះចែងថាព័ត៌មានស្តីពីថវិកាចាំបាច់ត្រូវផ្សព្វផ្សាយជាសាធារណៈ។ ចំណុចនេះគឺផ្ទុយស្រលះទៅនឹងច្បាប់ឆ្នាំ១៩៩៣ ដែលមិនមានចែងអ្វីសោះអំពីតួនាទីរបស់សាធារណជននៅក្នុងកិច្ចការធ្វើថវិកា ប៉ុន្តែយ៉ាងនេះក្តី ក៏នៅមានកិច្ចការច្រើនទៀតដែលត្រូវធ្វើដើម្បីអនុវត្តច្បាប់ឆ្នាំ២០០៨នេះ។ បញ្ញត្តិនៃច្បាប់នេះគឺជាចំណុចចាប់ផ្តើម សម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលខិតខំជម្រុញការទទួលបានព័ត៌មានសាធារណៈ ហើយប្រធានបទនេះគប្បីគួរត្រូវបានលើកឡើងនៅក្នុងវេទិការាជរដ្ឋាភិបាល-ម្ចាស់ជំនួយ-អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដូចជា ក្រុមការងារបច្ចេកទេសរួម ក្រុមពិគ្រោះយោបល់ឬវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា និងវេទិកាផ្សេងៗទៀត។

យកចិត្តទុកដាក់បន្ថែមលើវិមជ្ឈការនិងវិសហមជ្ឈការ។ ដោយមានការចេញច្បាប់អង្គការក្នុងពាក់កណ្តាលឆ្នាំ២០០៨ វិមជ្ឈការនិងវិសហមជ្ឈការកំពុងដាក់ឱ្យដំណើរការនូវកំណែទម្រង់ស៊ីជម្រៅមួយ ដែល

មានលក្ខណៈសន្សឹមៗ លើរបៀបដែលសេវាសាធារណៈត្រូវបានផ្តល់ និងរបៀបដែលធនធានត្រូវបានវិភាជ និងគ្រប់គ្រង។ គេនឹងឃើញមានវត្តមានក្រុមប្រឹក្សាខេត្តនិងស្រុកក្នុងខែឧសភា ឆ្នាំ២០០៩ ដែលក្រុមប្រឹក្សាទាំងនេះ នឹងបំពេញមុខងារជាតំណាងមួយនៃមន្ទីរខ្សែបណ្តោយវិមជ្ឈការទាំងអស់។ ថ្វីបើថវិកា នឹងត្រូវបានផ្ទេរបន្តិចម្តងៗ ទៅឱ្យថ្នាក់ក្រោមជាតិក្តី ក៏ជាមួយកំណែទម្រង់នេះ ប្រព័ន្ធថវិកានឹងមានលក្ខណៈមជ្ឈការកាន់តែតិចទៅៗ។ ច្បាប់អង្គការ និងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ថ្នាក់ក្រោមជាតិចែងថាថវិកាក្រុមប្រឹក្សាចាំបាច់ត្រូវផ្សព្វផ្សាយជាសាធារណៈ ដែលប្រការនេះអាចមានន័យថា ក្នុងការទទួលបានព័ត៌មានស្តីពីថវិកា អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាប្រជាជន ចាំបាច់គ្រាន់តែត្រូវទាក់ទងជាមួយនឹងក្រុមប្រឹក្សានីមួយៗប៉ុណ្ណោះ។ ប្រការនេះគឺមានលក្ខណៈងាយស្រួលច្រើនជាងប្រការដែលត្រូវដាក់សំណើផ្លូវការមួយតាមរយៈឋានានុក្រមក្រសួងថ្នាក់កណ្តាល។ ក្រុមប្រឹក្សាក៏នឹងប្រមែប្រមូលគម្រោងទាំងឡាយរបស់អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយមកដាក់ក្រោមដំបូលតែមួយ ថ្វីបើកិច្ចការនេះត្រូវការពេលវេលាបន្តិចក្តី។

ជាចុងក្រោយ របាយការណ៍បានបង្ហាញថាកាធានាឱ្យបាន និងការជម្រុញការទទួលព័ត៌មានស្តីពីថវិកានៅក្នុងវិស័យសុខាភិបាល (និងនៅក្នុងវិស័យឯទៀត) មិនមែនកំណត់តែនៅក្នុងវិស័យនេះតែមួយប៉ុណ្ណោះទេ ហើយក៏មិនមែនជាសកម្មភាពតែមួយដងចប់នោះដែរ។ វាគឺជាការងារអន្តរវិស័យ ដែលតម្រូវឱ្យមានការយល់ដឹង ការធ្វើបច្ចុប្បន្នកម្មទៀងទាត់ និងភាពជាដៃគូជាមួយស្ថាប័នផ្សេងៗ និងយន្តការមួយចំនួន។ ម៉្យាងទៀត គេមិនចាំបាច់ "បង្កើតថ្មីឡើងវិញទេ" ឧទាហរណ៍ដូចជាបង្កើតយន្តការថ្មីៗល។ ប៉ុន្តែផ្ទុយទៅវិញ គេគប្បីគួរខិតខំពង្រឹង និងបំពេញបន្ថែមលើអ្វីដែលមានរួចជាស្រេច។ ដោយសម្លឹងមើលទៅអនាគតដ៏ខ្លី លទ្ធភាពទទួលបានព័ត៌មានស្តីពីថវិកានៅក្នុងវិស័យនេះមានលក្ខណៈកាន់តែល្អប្រសើរ ពោលគឺមានមូលដ្ឋានច្បាប់រឹងមាំដើម្បីជម្រុញរបៀបវារៈនេះទៅមុខ និងការប្តេជ្ញាចិត្តជាច្រើនពីរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងការខិតខំធ្វើឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរឡើង។

# ឯកសារយោង


Lienert, I. J. Helis និងអ្នកផ្សេងទៀត។ (ឆ្នាំ២០០៨)។ កម្ពុជា៖ កែលម្អគណនេយ្យ របស់រាជរដ្ឋាភិបាល។ ភ្នំពេញ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

ក្រសួងសុខាភិបាល (ឆ្នាំ២០០៨)។ ផែនការយុទ្ធសាស្ត្រប្រព័ន្ធព័ត៌មានសុខាភិបាលឆ្នាំ២០០៨-១៥។ រាជធានីភ្នំពេញ ក្រសួងសុខាភិបាល។

ក្រសួងសុខាភិបាល (ឆ្នាំ២០០៨)។ ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល២ (ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលទី២)។

ក្រសួងសុខាភិបាល (ឆ្នាំ២០០៨)។ របាយការណ៍ស្តីពីជំនួយពីក្រៅចំពោះវិស័យសុខាភិបាលឆ្នាំ២០០៧-០៩។

ក្រសួងសុខាភិបាល (ឆ្នាំ២០០៨)។ ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានសុខាភិបាលឆ្នាំ២០០៨-១៥។ រាជធានីភ្នំពេញ ក្រសួងសុខាភិបាល។

Ortendahl Donoghue និងអ្នកផ្សេងទៀត។ (ឆ្នាំ២០០៧)។ ការពិនិត្យវាយតម្លៃវិស័យសុខាភិបាល (ឆ្នាំ២០០៣-០៧)។ រាជាធានីភ្នំពេញ ក្រសួងសុខាភិបាល/hlsp។

រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ១៩៩៣)។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០០៨)។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ធនាគារពិភពលោក (ឆ្នាំ២០០៨)។ ការវាយតម្លៃកម្មវិធីសម្រាប់កម្មវិធីគាំទ្រវិស័យសុខាភិបាលទីពីរ។ រាជធានីភ្នំពេញ ធនាគារពិភពលោក។

# ឧបសម្ព័ន្ធ១៖ លំហូរព័ត៌មាននិងឯកសារដែលផលិតដោយកម្រិតនិងស្ថាប័នផ្សេងៗគ្នា



## ឧបសម្ព័ន្ធ២៖ ការមានឯកសារថវិកានៅថ្នាក់ជាតិ

| ស្ថាប័ន | ឯកសារ និងពេលវេលានៃការបោះផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការមាន |
|---|---|---|---|
| ១. ស្តីពីថវិកាជាតិ | | | |
| រាជរដ្ឋាភិបាលកម្ពុជា | ច្បាប់ស្តីពីហិរញ្ញវត្ថុ៖ មានជាប្រចាំឆ្នាំ រកបានមុនដំណាច់ខែធ្នូនៃឆ្នាំមុនឆ្នាំថវិកា | – សនិទានភាពគាំទ្រថវិកា<br>– បទប្បញ្ញត្តិថវិកាសំខាន់ៗ ដែលត្រូវបានចេញក្នុងឆ្នាំ<br>– វិភាជន៍ចំណូលនិងចំណាយ ដែលត្រូវបានអនុម័ត (ចរន្ត កម្មវិធី និងរាជធានី) និង គិតតាមថ្នាក់កណ្តាល និង ថ្នាក់ខេត្ត | – មាន និងមិនចាំបាច់ មានសំណើផ្លូវការ មិនចំណាយពេលច្រើន<br>– ទាក់ទងរដ្ឋសភា ព្រឹទ្ធសភា ឬ ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | ច្បាប់ទូទាត់ថវិកា៖ មិនបានអនុម័តទៀងទាត់ អាចយឺតដល់ទៅពីរឆ្នាំ | - ការអនុវត្តថវិកាដែលត្រូវបានអនុម័តសម្រាប់រាល់ចំណូល និងចំណាយ ដែលបានអនុម័ត | – មាន និងមិនចាំបាច់ មានសំណើផ្លូវការ មិនចំណាយពេលច្រើន<br>– ទាក់ទងរដ្ឋសភា ព្រឹទ្ធសភា ឬ ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សៀវភៅគ្រប់គ្រងថវិកា៤ ក្បាលស្តីពីច្បាប់ថវិកាជាតិ ដែលរួមមាន៖<br>– សៀវភៅទី១៖ ច្បាប់ស្តីពី ថវិកាជាតិ<br>– សៀវភៅទី២៖ ថវិកា សម្រាប់ក្រសួងថ្នាក់ជាតិ<br>– សៀវភៅទី៣៖ ថវិកា សម្រាប់មន្ទីរខេត្ត<br>– សៀវភៅទី៤៖ ថវិកា សម្រាប់សាលាខេត្ត មានជាប្រចាំឆ្នាំ | – ព័ត៌មានទាំងអស់ដែលមាន នៅក្នុងច្បាប់ថវិកាជាតិ (ខាងលើ)<br>– ព័ត៌មានលម្អិតស្តីពីការ វិភាជថវិកាក្រសួងតាម មុខងារសេដ្ឋកិច្ច តាមខេត្ត និងព័ត៌មានលម្អិតអំពីខេត្ត នីមួយៗ | – មាន និងមិនចាំបាច់ មានសំណើផ្លូវការ មិនចំណាយពេលច្រើន ប៉ុន្តែអាចត្រូវទិញ<br>– ទាក់ទងនាយកដ្ឋាន ថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| | ការអនុវត្តថវិការដ្ឋ (តារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ)៖ មានប្រចាំខែ និង ប្រចាំឆ្នាំ និងអាចយឺតរហូតដល់លើសមួយខែ | - បង្ហាញការអនុវត្តថវិកាតាមខែ តាមវិស័យ និងតាមគម្រោង | - មានជាសាធារណៈ និង មិនចាំបាច់មានសំណើ ផ្លូវការ មិនចំណាយពេលច្រើន ប៉ុន្តែអាចត្រូវទិញពីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក្រសួងផែនការ | ផែនការអភិវឌ្ឍន៍ | – បង្ហាញអាទិភាពវិស័យ | - មានជាសាធារណៈពី |

| | | | |
|---|---|---|---|
| | យុទ្ធសាស្ត្រជាតិ (NSDP) ឆ្នាំ២០០៦-២០១០ | សូចនាករ និង តម្រូវការធនធានសម្រាប់រយៈពេលនោះ។ | ក្រសួងផែនការ |
| | កម្មវិធីវិនិយោគ សាធារណៈ (PIP)៖ មានជាប្រចាំឆ្នាំ | – ផែនការ៣ឆ្នាំរំកិលនៃការវិនិយោគសាធារណៈដែលផ្តល់ព័ត៌មានលម្អិតអំពីគម្រោងតាមវិស័យ និងតាមឆ្នាំ | – មានជាសាធារណៈ និងមិនចាំបាច់មានសំណើផ្លូវការទេ ប៉ុន្តែអាចត្រូវទិញ |
| ក្រសួងសុខាភិបាល នាយកដ្ឋានផែនការ | ស្ថិតិសុខាភិបាលប្រចាំឆ្នាំ៖ មានជាប្រចាំឆ្នាំ | – ព័ត៌មានលម្អិតស្តីពីវឌ្ឍន-ភាពលើសូចនាករសំខាន់ៗក្នុងវិស័យសុខាភិបាល | – មានជាសាធារណៈ និងមិនចាំបាច់ត្រូវមានការយល់ព្រមជាផ្លូវការទេ |
| | ផែនការប្រតិបត្តិការណ៍ និងផែនការ៣ឆ្នាំរំកិល | – ព័ត៌មានសរុបថ្នាក់ជាតិស្តីពីកម្មវិធី និងមិនមែនកម្មវិធី | – មានជាសាធារណៈ និងមិនចាំបាច់ត្រូវមានការយល់ព្រមជាផ្លូវការទេ |
| | របាយការណ៍វាយតម្លៃរួមលើវិស័យសុខាភិបាល មានជាប្រចាំឆ្នាំ | – ការពិនិត្យវាយតម្លៃប្រចាំឆ្នាំប្រៀបធៀបនឹងសូចនាករទាំងឡាយ ដែលត្រូវបានកំណត់នៅក្នុងផែនការប្រតិបត្តិការប្រចាំឆ្នាំ | – មានជាសាធារណៈ និងមិនចាំបាច់ត្រូវ មានការយល់ព្រមជាផ្លូវការទេ |
| ក្រសួងសុខាភិបាល នាយកដ្ឋានហិរញ្ញវត្ថុ | សៀវភៅថវិកាប្រចាំឆ្នាំ មានជាប្រចាំឆ្នាំ | – ថវិកាជាតិចែកតាមកម្មវិធី កម្មវិធីរង និងតាមជំពូក និងជំពូករងថវិកា | |
| | របាយការណ៍ស្តីពីស្ថានភាពចំណាយប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ មានជាប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ | – ព័ត៌មានលម្អិតស្តីពីមូលនិធិសមធម៌សុខភាពថ្នាក់ជាតិ និងថ្នាក់ខេត្ត ការធ្វើថវិកាតាមកម្មវិធី ថ្លៃសេវា | – អាចផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាល តាមរយៈក្រុមការងារបច្ចេកទេសរួម |
| ក្រសួងសុខាភិបាល ឃ្លាំងបរិក្ខារពេទ្យកណ្តាល | តារាងសរុបចំណូលចំណាយឱសថប្រចាំខែ និងប្រចាំឆ្នាំ<br>មានជាប្រចាំត្រីមាស និងឆ្នាំ | – ព័ត៌មានលម្អិតស្តីពីការផ្ទេរចូលផ្ទេរចេញប្រភេទឱសថ/បរិក្ខារ ប្រភពនៃការផ្ទេរនិងទិសដៅនៃការផ្ទេរ | |
| ២. ស្តីពីហិរញ្ញប្បទាន និង ការជួយគាំទ្រពីម្ចាស់ជំនួយ និង អង្គការមិនមែនរដ្ឋាភិបាល | | | |
| ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា | មូលដ្ឋានទិន្នន័យជំនួយបរទេស<br>ពុំមានពេល កំណត់ទេ | – ការជួយគាំទ្ររបស់ម្ចាស់ជំនួយទាំងអស់ តាមវិស័យ ឆ្នាំ និងខេត្ត និងការផ្តល់មូលនិធិចូលក្នុងគម្រោងនីមួយៗ (ប៉ុន្តែមិនមែនអ្វី | – មានជាសាធារណៈ និងមិនចាំបាច់មានសំណើផ្លូវការទេ<br>– ព័ត៌មានពីមូលដ្ឋានទិន្នន័យនេះត្រូវបានប្រើ |

| | | | |
|---|---|---|---|
| | | ដែលត្រូវបានចាយចេញពីគម្រោងទេ) | ដើម្បីរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយរៀងរាល់ឆ្នាំ |
| ក្រសួងសុខាភិបាល នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | មូលដ្ឋានទិន្នន័យស្តីពីជំនួយបរទេសចំពោះវិស័យសុខាភិបាល (ស្ថិតក្នុងការរៀបចំ) | -ចំនួននៃការជួយគាំទ្ររបស់ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល (សកម្មភាព ហិរញ្ញប្បទាន ទីកន្លែង ។ល។) និងព្យាករណ៍ចំណាយតាមផ្នែកនៃកម្មវិធី និងខ្ទង់ចំណាយទូលាយ (ជំនួយបច្ចេកទេស ថ្លៃចំណាយ មូលធន និងចរន្ត)[13] | – អាចផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាល តាមរយៈក្រុមការងារបច្ចេកទេសរួម |

[13] យោងតាមរបាយការណ៍របស់ក្រសួងសុខាភិបាលស្តីពីជំនួយបរទេសចំពោះវិស័យសុខាភិបាល (ឆ្នាំ ២០០៨)។

## ឧបសម្ព័ន្ធ៣៖ ការមានឯកសារថវិកានៅថ្នាក់ក្រោមជាតិ

| ប្រភេទព័ត៌មាន ការមានព័ត៌មាន | ឯកសារនិងពេលវេលានៃការបោះពុម្ពផ្សាយ | ព័ត៌មានពាក់ព័ន្ធ | ការមានព័ត៌មាន |
|---|---|---|---|
| មន្ទីរសុខាភិបាលខេត្ត និងស្រុកប្រតិបត្តិការ | | | |
| ស្នាដៃអនុវត្តប្រចាំវិស័យ | របាយការណ៍សកម្មភាពប្រចាំខែ និងប្រចាំឆ្នាំ មានជាប្រចាំខែ និងប្រចាំឆ្នាំ | – មានលក្ខណៈលម្អិតខ្លាំងស្ដីពីស្ថានភាពទូទៅ និងសូចនាករសុខភាពសំខាន់ៗសម្រាប់ខេត្ត ដែលត្រូវបំបែកលម្អិតតាមស្រុកប្រតិបត្តិការ | – អាចផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាល តាមរយៈក្រុមការងារបច្ចេកទេសរួមផ្នែកសុខាភិបាលថ្នាក់ខេត្ត និងអាជ្ញាធរថ្នាក់ក្រោមជាតិ |
| ផែនការប្រតិបត្តិការ និងថវិកា | ផែនការប្រតិបត្តិសុខាភិបាលប្រចាំឆ្នាំ | – ស្ថានភាពសុខភាពទូទៅនៅក្នុងខេត្ត និងរចនាសម្ព័ន្ធរដ្ឋបាល<br>– ផែនការបីឆ្នាំរំកិលសម្រាប់ខេត្ត<br>– ផែនការសកម្មភាពតាមកម្មវិធីទាំងបួន និងកម្មវិធីរងដោយបង្ហាញសូចនាករ និងស្ថាប័នអនុវត្ត<br>– ការរៀបចំថវិកាលម្អិតសម្រាប់កម្មវិធី និងកម្មវិធីរងនីមួយៗ ដោយបង្ហាញផែនការថវិកាសរុបជារៀល ដុល្លារអាមេរិក បដិភាគថវិកាជាតិ ថ្លៃបង់សេវានិងម្ចាស់ជំនួយ (ឧទាហរណ៍ កម្មវិធីគាំទ្រវិស័យសុខាភិបាល មូលនិធិសកល ពហុភាគី និងទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាល) | |

| | | | |
|---|---|---|---|
| ថវិកាជាតិ | – ផែនការថវិកា ដែលត្រូវបានដាក់បញ្ចូលរួចហើយនៅក្នុង ផែនការប្រតិបត្តិការប្រចាំឆ្នាំ (សូមមើលខាងលើ )។ សូមមើលសៀវភៅថវិកាបោះផ្សាយប្រចាំឆ្នាំ (សៀវភៅទី៣) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>– មានជាប្រចាំឆ្នាំ | – ផែនការថវិកាលម្អិតដែលត្រូវបានចែកចេញជាជំពូក និងជំពូករងនៃចំណាយនិង ដែលសម្រាប់កម្មវិធី ឬមិនមែនសកម្មភាព។ | |
| | ស្ថានភាពចំណូលចំណាយថវិកា ប្រចាំខែ និង ប្រចាំឆ្នាំ | – ចំណាយក្នុងខែ<br>– ចំនួនសរុបនិងភាគរយនៃការប្រេតិបត្តិថវិកាប្រចាំឆ្នាំ<br>– ចែកលម្អិតតាមស្រុកប្រតិបត្តិការ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព<br>– ចែកលម្អិតតាមជំពូកថវិការួមទាំងប្រាក់ចំណូល (ថ្លៃសេវា) និងចំណាយតាមជំពូក ៦០ (ទាំងតាមបុរេប្រទាន និងការផ្ទេរដោយផ្ទាល់) ជំពូក ៦១ ៦២ ៦៣ ៦៤ (រួមទាំងចំនួនបុគ្គលិកនិងថ្លៃចំណាយក្នុងមួយឯកតានិងគ្រឿងលើកទឹកចិត្តពិសេស) ជំពូក៦៥ និងជំពូករងនៃជំពូកទាំងនេះ។<br>– ព័ត៌មានស្តីពីការជួយគាំទ្ររបស់ម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាលក៏អាច | |

| | | | |
|---|---|---|---|
| | | ត្រូវបានដាក់បញ្ចូលនៅទីនេះដែរ អាស្រ័យលើការមានព័ត៌មាននេះពីអង្គការមិនមែនរដ្ឋាភិបាល | |
| មូលនិធិសមធម៌សុខភាព | របាយការណ៍ប្រចាំត្រីមាសស្តីពីការបង់ថ្លៃជូសដល់អ្នកជម្ងឺក្រីក្រ មានជាប្រចាំត្រីមាស | – ព័ត៌មានលម្អិតស្តីពីចំណាយមូលនិធិសមធម៌សុខភាព ដែលចែកលម្អិតតាមស្រុកប្រតិបត្តិការ ឈ្មោះអ្នកជម្ងឺ ការបង់ថ្លៃជំនួសអ្នកជម្ងឺទាំងនោះ កាលបរិច្ឆេទនៃការបង់ប្រាក់ ប្រភេទនៃសេវាដែលបានបង់ប្រាក់ | |
| ឱសថនិងបរិក្ខារពេទ្យ | របាយការណ៍ចំណូលចំណាយ ឱសថសំភារៈបរិក្ខារពេទ្យប្រចាំត្រីមាស និងប្រចាំឆ្នាំ | – ព័ត៌មានលម្អិតស្តីពីឱសថនិងបរិក្ខារពេទ្យដែលបានផ្ទេរចូល និងត្រូវបានប្រើប្រែងចែកលម្អិតតាមស្រុកប្រតិបត្តិការ។ សម្រាប់ស្រុកប្រតិបត្តិការនីមួយៗ មានបង្ហាញតាមប្រភេទឱសថ/បរិក្ខារពេទ្យ អ្វីដែលនៅសល់ពីការផ្ទេរចូលពីឃ្លាំងបរិក្ខារពេទ្យកណ្តាល និងដែលទិញក្នុង មូលដ្ឋាន ដែលត្រូវបានប្រើប្រាស់ និងដែលនៅសល់។ | |
| គម្រោងរបស់ម្ចាស់ជំនួយ/ អង្គការមិនមែនរដ្ឋាភិបាល | របាយការណ៍ប្រជុំក្រុមការងារ រួមថ្នាក់ខេត្ត ប្រចាំខែ និងប្រចាំត្រីមាស | – ចំនួននៃអង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមសកម្មភាពរបស់ពួកគេ និងជូនកាលមានព័ត៌មានស្តីពីថវិការបស់ពួកគេ | |

| មណ្ឌលសុខភាព / មន្ទីរពេទ្យបង្អែក | | | |
|---|---|---|---|
| ស្ថិតិទូទៅ | របាយការណ៍សកម្មភាពប្រចាំខែ/ឆ្នាំ | – ចំនួននិងប្រភេទនៃអ្នកជម្ងឺ ដែលបានព្យាបាល ឬដែលបានពិគ្រោះជម្ងឺ | – អាចផ្តល់ជូនអង្គការមិនមែនរដ្ឋាភិបាលតាមរយៈក្រុមការងារបច្ចេកទេសរួមផ្នែកសុខាភិបាលថ្នាក់ខេត្ត និងអាជ្ញាធរថ្នាក់ក្រោមជាតិ រួមទាំងក្រុមប្រឹក្សាឃុំ |
| ព័ត៌មានទូទៅស្តីពីថវិកា | របាយការណ៍វិភាគចំណូល-ចំណាយ<br>មានជាប្រចាំខែ និងប្រចាំឆ្នាំ | – ប្រាក់ចំណូលពីការផ្ទេរ និង ថ្លៃបង់សេវា<br>– ចំណាយលើបុគ្គលិក និងទំនិញនិងសេវា<br>– ចំណាយលើឱសថ និងបរិក្ខារពេទ្យ | |
| មូលនិធិសមធម៌សុខភាព និង កម្មវិធីធានារ៉ាប់រង | តារាងសម្រង់ព័ត៌មានហិរញ្ញប្បទានសុខាភិបាល | – ចំនួននិងប្រភេទនៃអ្នកមកពិគ្រោះជម្ងឺដែលត្រូវបានប្រើជាមូលដ្ឋានសម្រាប់ការគណនាមូលនិធិសមធម៌សុខភាព និងការធានារ៉ាប់រង ដែលត្រូវបង់ជាការបង់ថ្លៃ ជំនួសឱ្យអ្នកជម្ងឺទៅកាន់ មណ្ឌលសុខភាព/ មន្ទីរពេទ្យបង្អែក | |

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

អាសយដ្ឋានៈ ផ្ទះលេខ៩-១១ ផ្លូវលេខ៤៧៦ ទួលទំពូង១
ប្រអប់សំបុត្រលេខ២២៩៥ ភ្នំពេញ-៣
ទូរស័ព្ទៈ +៨៥៥ (២៣) ២១៤ ៤២៩
ទូរសារៈ +៨៥៥ (២៣) ៩៩៤ ០៦៣
អ៊ីម៉េលៈ ngoforum@ngoforum.org.kh
គេហទំព័រៈ www.ngoforum.org.kh